ក្រសួងសុខាភិបាល

កម្រងស្រាវជ្រាវ

# រុក្ខជាតិឱសថ

## LES PLANTES MÉDICINALES

ភាគ ១





1985

ការផ្សាយរបស់
មជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រ
និងឱសថសាស្ត្របុរាណ

៦១៥.
១

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

៦១៥.១
ឥ២៣

ក្រសួងសុខាភិបាល

កម្រងស្រាវជ្រាវ

# រុក្ខជាតិឱសថ

## LES PLANTES MÉDICINALES

ភាគ ១





បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
២៥៣៤/៩៦

ការផ្សាយរបស់
មជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រ
និងឱសថសាស្ត្របុរាណ

1985

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីផ្តើម

-អនុក្រឹត្យលេខ ០៨ អ.ន.ក្រ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការធ្វើការជីវកម្មឱសថ ។ជំនួញ និង ស្រាវជ្រាវឱសថបុរាណអោយបានសមស្របទៅតាមលក្ខណៈសេដ្ឋកិច្ចនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា យើង ។

-សារាចរ លេខ ៥៥ ស.ន.ម.ឃ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ១៩៨៥ របស់គណៈលេខាមជ្ឈិមបក្សស្តីពីការងារសុខាភិបាលក្នុងសភាពការណ៍ចំពោះមុខ និង ទៅអនាគត ។ភារកិច្ចចំបងរបស់ផ្នែកសុខាភិបាលក្នុងបណ្តាឆ្នាំខាងមុខ "ក្នុងការងារព្យាបាលជំងឺក៏ដូចជាការងារការពារជំងឺត្រូវយកចិត្តទុកដាក់គួបផ្សំវេជ្ជសាស្ត្រសម័យ និង វេជ្ជសាស្ត្របុរាណ ។

-សេចក្តីណែនាំអនុវត្តសារាចររបស់គណៈលេខាមជ្ឈិមបក្សស្តីពីការងារសុខាភិបាលក្នុងសភាពការណ៍ថ្មីលេខ ៥៨ ស.ម. ចុះថ្ងៃទី ខែ មិនា ឆ្នាំ ១៩៨៥ ។ សំណូមពរត្រូវសំរេចអោយបានលើកឡើង "យើងត្រូវចេះបន្តកេរ្តិ៍ដំណែលនោះថែមទៀត ត្រូវចេះគួបផ្សំយឿនវេជ្ជសាស្ត្របុរាណ និង [illegible]វេជ្ជសាស្ត្រសម័យដើម្បីកសាងយឿនវេជ្ជសាស្ត្រឈានមុខរបស់ប្រទេសយើងក្នុងវិស័យវេជ្ជសាស្ត្រក៏ដូចជាឱសថសាស្ត្រ ។ ក្នុងការងារឱសថយើងត្រូវខិតខំប្រើប្រាស់ប្រភពវត្ថុធាតុឱសថក្នុងប្រទេសអោយបានល្អ" ។

-ទឹកដីអង្គរដ៏បវរនៃយើងពោរពេញទៅដោយសម្បត្តិធម្មជាតិគ្រប់បែបយ៉ាង ក្នុងនោះក៏មានរុក្ខជាតិមានតំលៃជាច្រើនដែលគេអាចយកមកប្រើប្រាស់ជាឱសថសំរាប់ព្យាបាលជំងឺ ។ តាំងពីសម័យអង្គររហូតមកទល់បច្ចុប្បន្ន ឆ្លងកាត់ការប្រើប្រាស់រុក្ខជាតិឱសថដែលមានគ្រប់ទីកន្លែង ដូចជានៅលើភ្នំ ខ្ពង់រាប វាលរាប តំបន់លិចទឹក តាមដងទន្លេ តាមមាត់សមុទ្រ និង ក្នុងទឹកសមុទ្រប្រជាជនយើងមានបទពិសោធន៍ព្រមទាំងវិធីព្យាបាល ៣ [illegible] ព្យាបាលជំងឺដោយប្រើដើមថ្នាំ ។

-ទន្ទឹមនឹងបុគ្គលប្រើប្រាស់ដើមថ្នាំ ប្រជាជនយើងក៏ [illegible] ព្យាបាលជំងឺផងដែរ ។ដូចជា ស្នែងខ្ទីង ស្នែងប្រើស ពស់ថ្លាន់ ក្រូចអណ្តើក ចង្កូមប្រម៉ា តុកកែ គីង្គក់ ពង្រូល [illegible] ប្រម៉ា ថ្លើមខ្លាឃ្មុំ អន្សង ។ល។

ដើម្បីជាឯកសារសំរាប់បង្កើនការយល់ដឹង និង ក្នុងគោលបំណងចង់អោយប្រជាជនយើងចេះប្រើប្រាស់រុក្ខជាតិឱសថដែលស្ថិតនៅជុំវិញខ្លួន ដើម្បីជាឱសថសំរាប់ព្យាបាលជំងឺបានល្អប្រសើរផងនោះ មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រ និង ឱសថសាស្ត្របុរាណបានស្រាវជ្រាវចងក្រងជាសៀវភៅ និង ខិតខំស្រាវជ្រាវចងក្រងជាបណ្តើរៗថែមទៀត ។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងជាប្រយោជន៍ដល់មិត្តអ្នកអាន ដែលមានចំណាប់អារម្មណ៍ចំពោះរុក្ខជាតិឱសថ និង វេជ្ជសាស្ត្រ-ឱសថសាស្ត្របុរាណ ។

យើងខ្ញុំរង់ចាំទទួលការរិះគន់ និង សំណូមពរគ្រប់បែបយ៉ាងក្នុងបំណងជំរុញវិស័យឱសថជាតិយើងអោយទៅសំរេចបាន រាល់អនុក្រឹត្យ សារាចរ និង សេចក្តីណែនាំខាងលើ ដោយប្រសិទ្ធភាពខ្ពស់ក្នុងអនាគតដ៏ខ្លីខាងមុខនេះ ។

ឱសថការី ចេង ស៊ុន កាំង

មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រ និង ឱសថសាស្ត្របុរាណ

នៃ ក្រសួងសុខាភិបាល

www.budinst.gov.kh www.elibraryofcambodia.org

## គណៈកម្មការ ចងក្រង ស្រាវជ្រាវឯកសារ

១ - ឱសថការី ចេង ស៊ុន កាំង : ប្រធាន
២ - ឧញ្ញាយ សា ម៉ុន : អនុប្រធាន
៣ - ឱសថការី ថេង ម៉េង អាន : សមាជិក

ក្រុមបកប្រែ និង កត់ត្រា :

១ - ឧញ្ញាយ សា ម៉ុន : ប្រធាន
២ - ឱសថការី ទេព យ៉ា រី : អនុប្រធាន
៣ - ឱសថការី ឃួន វិ ឧញ្ញា វណ្ណ : សមាជិក
៤ - ថាច់ លឹង : សមាជិក
៥ - ម៉ឹង សុ ម នះ : លេខាកត់ត្រា

ក្រុមស្រាវជ្រាវ និង ប្រមូលផ្តុំបទពិសោធន៍ :

១ - ឱសថការី ចេង ស៊ុន កាំង : ប្រធាន
២ - ឱសថការី ថេង ម៉េង អាន : អនុប្រធាន
៣ - ឱសថការី ឃួន វិ ឧញ្ញា វណ្ណ : អនុប្រធាន
៤ - ឱសថការី សោ ស៊ុន ហ៊ិត : សមាជិក
៥ - ឱសថការី ឃាង បូ មិត្ត : សមាជិក
៦ - ឱសថការី ចេង លី បូ តា : សមាជិក
៧ - គ្រូបូរាណ ហួន នុំ : សមាជិក
៨ - គ្រូបូរាណ លេញ ជឹន : សមាជិក
៩ - គ្រូបូរាណ លី ប៊ុណ្ណា. រិទ្ធ : សមាជិក

ក្រុមត្រួតពិនិត្យ សំរួលកំណត់ :

១ - ឱសថការី ចេង ស៊ុន កាំង : ប្រធាន
២ - ឧញ្ញាយ សា ម៉ុន : អនុប្រធាន
៣ - ឱសថការី ទេព យ៉ា រី : អនុប្រធាន
៤ - ឱសថការី ឃួន វិ ឧញ្ញា វណ្ណ : សមាជិក
៥ - គ្រូបូរាណ ហួន នុំ : សមាជិក

ក្រុមរៀបចំ គូរ និង បោះពុម្ព :

១ - ឱសថការី ថេង ម៉េង អាន : វាយអង្គលីលេខ
២ - ឱសថការី ចេង ស៊ុន កាំង : គូរគំនូរ

www.budinst.gov.kh www.elibraryofcambodia.org

ក្រសួងសុខាភិបាល
មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រ
និង ឱសថសាស្ត្របុរាណ

សាធារណរដ្ឋប្រជាមានិតកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

## 1- ដើមដង្ហិត

ឈ្មោះ កម្ពុជា : ដើមដង្ហិត

ឈ្មោះ ជាភាសាបារាំង: Dartrier

ឈ្មោះ ជាឡាតាំង: Cassia alata L. Famille: Caesalpiniaceae

១ លក្ខណៈបូតានិក និង ភូមិសាស្ត្រដំដុះ - ដង្ហិតគឺជាដើមឈើតូចខ្ទម ដែលមានកំពស់ប្រហែល ១,៥០មហើយ មានដើមដែលមានវិជ្ឈមាត្រពី ១០ ទៅ ១២ស-ម។ ស្លឹកវាមានទំហំធំ ដែលផ្សំឡើងដោយទងរាងត្រីកោណ ដែលមានប្រវែងពី ៣០ទៅ ៥០ ស-ម និង មានស្លឹកទល់ទងពី ៨ ទៅ ១៤ គូ ក្នុងនេះ ស្លឹកទល់ទងមួយគូនៅដើមទង មានទំហំតូចជាងគេ ។



ផ្កាវាដុះជាកញ្ចុំ នៅចន្លោះដើម និងមែក កញ្ចុំផ្កានេះពណ៌លឿងមានសភាពវែង ដែលមានបណ្ដោយប្រវែងពី ៣០ ទៅ ៤០ ស-ម និង មានទទឹងប្រវែងពី ៣ ទៅ ៤ ស-ម ។

គ្រាប់ផ្លែវាមានរហូតទៅដល់ចំនួន ៦០ មានរាងជាបួនជ្រុងក្លាយស្រប ហើយដុះទទឹងកែងទៅនឹងផ្លែ ។ផ្លែវាគួរវែង ប្រវែងពី ៨ ទៅ ១៦ ស-ម ទំហំពី ១៥ -១៧ ម.ម ហើយមានក្រទនុងពីរអមបណ្ដោយផ្លែ ។

គេសង្កេតឃើញដើមដង្ហិតនេះ មានដុះច្រើននៅក្នុងប្រទេសក្ដៅជាពិសេសនៅក្នុងប្រទេសទាំង៣ នៃជ្រោយឥណ្ឌូចិន គឺ កម្ពុជា ,វៀតណាម ,និង ឡាវ ហើយច្រើនតែដុះនៅក្នុងព្រៃវាលទំនាប ។

២ សមាសភាពគីមី : -នៅក្នុងផ្លែ ,គ្រាប់ផ្លែ ដើម ជាពិសេសស្លឹក មានពួក "ដេរីវេអង់ត្រាសេនិក" dérivés anthracéniques ដោយភ្ជាប់ជាមួយនូវជាតិ "គ្រីស៊ូផាណុល" chrysophanol ក្នុងចំណោមពួកដេរីវេនេះ គេសង្កេតឃើញមានជាអាទិ៍ :

-រេអ៊ីនលីប និង គ្លុយកូស៊ីឌីក ( Rhéine libre et glucosidique )

-និង រេអ៊ីនអង់ត្រូន គ្លុយកូស៊ីត( Anthrone glucoside )



www.budinst.gov.kh www.elibraryofcambodia.org

៣-របៀបប្រើ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាលជម្ងឺ :

ប្រជាជនយើង ច្រើនប្រើស្លឹកដង្ហិតសំរាប់ព្យាបាលជម្ងឺ ស្រែង ព្យាបាលជម្ងឺភ្លឺ ជម្ងឺកន្ទួលលើស្បែក ។ នៅក្នុងករណីយជាច្រើន គេប្រើជាថ្នាំលាប (Pommade chrysophanique) ឬមួយជា " គ្រីសារ៉ូប៊ាំង "។ គេអាចយកស្លឹកទៅព្យាបាលជម្ងឺកមរមាស់ របស់ពួកសត្វចតុប្បាទ ។

ស្លឹក ផ្លែ សាច់ដើម ប្រើធ្វើជាថ្នាំបន្ទន់លាមក ។ ប្រើលើជម្ងឺលើស្បែកគ្មានកំរិតទេ ។តែបើផឹកឬលេបវិញ ត្រូវប្រើក្នុងកំរិតពី ៤-៨ ក្រាម ។

បំរាម : ហាមប្រើថ្នាំដែលមានជាតិ "អង់ត្រាគ្លុយកូស៊ីត" ( Anthraglucoside) ផ្សេងពុំទៀត ក្នុងពេលដែលប្រើស្លឹកដង្ហិតក្នុងការព្យាបាល ។

រូបមន្តព្យាបាលស្រែង : លាងកន្លែងកើតស្រែងអោយស្អាត ។បុកស្លឹកដង្ហិតហើយលាបពីលើស្រែងម្តង ឬ ពីរដងក្នុងមួយថ្ងៃ ។

គេអាចច្នៃប្រឌិតទៅជាថ្នាំតាមរបៀបខាងក្រោមនេះ :

គេយកស្លឹកស្រស់ទៅបុកអោយម៉ត់ ហើយយកទឹកពុះចាក់ឆុង រួចលាយកំបិល "សូដ្យូមភ្លុយអរ" (NaF) ។ ទុកអោយនៅស្ងៀមក្នុងកំឡុងពេល ២៤ ម៉ោង ហើយច្រោះនឹងក្រណាត់ ។រួចបន្ថែមចូលក្នុងកាកនូវ អាកុល ៩០ អង្សា ។ទុកអោយនៅស្ងៀមចំនួន ២៤ ម៉ោង ។ ព្រួតយកអាកុលមកវិញ រួចលាយទឹក ។គេបាន :

$L_1$ : ទឹកដែលបានក្រោយពីច្រោះ និង ក្រណាត់

$L_2$ : ទឹកដែលបានពីការត្រាំកាក និង អាកុល ៩០ អង្សា

បន្ទាប់មកទៀតយើងលាយទឹក $L_1$ ជាមួយទឹក $L_2$ រួចដំឡាស់អោយអាច់ រហូតដល់បានជាតិការ៉ ។ ធ្វើរបៀបនេះ គេអាចទុក [illegible] ជាកំបិល "សូដ្យូមភ្លុយអរ" (NaF) នៅទីបញ្ចប់គេយក ជាតិការ៉នេះទៅធ្វើថ្នាំលាប ( Pommade 1/5 ) ។

[illegible] គេយកស្លឹកស្រស់បុកលាយជាមួយទឹកក្រូចឆ្មារ លាយកំបិលបន្តិច រួចយកទៅលាបលើស្រែង។

របៀបយកផលលើដើមដង្ហិត :-

គេយកផលពីខែ ១០ ទៅខែ ១២ គេបេះស្លឹក និង ដើមនៅក្នុងរដូវទំហើយ និង រដូវរងាមុនពេលដើមមានផ្កា ប្រើស្រស់ ឬ យកទៅហាលអោយស្ងួត ។

បន្ទន់លាមក : ប្រើក្នុងកំរិតពី ៤-៨ ក្រាម

បញ្ចុះលាមក : ប្រើក្នុងកំរិតពី ១០-២០ ក្រាម "មេស្លាស្លឹក ឬ មេស្លាដើម" ផឹករាល់ថ្ងៃ ។



www.budinst.gov.kh www.elibraryofcambodia.org

៣-របៀបប្រើ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាលជំងឺ :

ប្រជាជនយើង ច្រើនប្រើស្លឹកដង្ហិតសំរាប់ព្យាបាលជំងឺ ស្រែង ព្យាបាលជំងឺភ្លឺ, ជំងឺកន្ទួលលើស្បែក ។ នៅក្នុងករណីយជាច្រើន គេប្រើជាថ្នាំលាប (Pommade chrysophanique) ឬមួយជា " គ្រីសារ៉ូប៊ីង " ។ គេអាចយកស្លឹកទៅព្យាបាលជំងឺកមរមាស់ របស់ពួកសត្វចតុប្បាទ ។

ស្លឹក, ផ្លែ, សាច់ដើម ប្រើធ្វើជាថ្នាំបន្ទន់លាមក ។ ប្រើលើជំងឺលើស្បែកគ្មានកំរិតទេ ។តែបើផឹកឬលេបវិញ ត្រូវប្រើក្នុងកំរិតពី ៤-៨ ក្រាម ។

បំរាម : ហាមប្រើថ្នាំដែលមានជាតិ "អង់ត្រាគ្លុយកូស៊ីត" ( Anthraglucoside) ផ្សេងៗទៀត ក្នុងពេលដែលប្រើស្លឹកដង្ហិតក្នុងការព្យាបាល ។

រូបមន្តព្យាបាលស្រែង : លាងកន្លែងកើតស្រែងអោយស្អាត ។បុកស្លឹកដង្ហិតហើយលាបពីលើស្រែងម្តង ឬ ពីរដងក្នុងមួយថ្ងៃ ។

គេអាចច្នៃប្រឌិតទៅជាថ្នាំតាមរបៀបខាងក្រោមនេះ :

គេយកស្លឹកស្រស់ទៅបុកអោយម៉ត់ ហើយយកទឹកពុះចាក់ស្ងោរ រួចលាយអំបិល "សូដ្យូមភ្លុយអរ" (NaF) ។ ទុកអោយនៅស្ងៀមក្នុងកំឡុងពេល ២៤ ម៉ោង ហើយច្របាច់នឹងក្រណាត់ ។រួចបន្ថែមចូលក្នុងកាកនូវ អាកុល ៩០ អង្សា ។ទុកអោយនៅស្ងៀមចំនួន ២៤ ម៉ោង ។ ពួតយកអាកុលមកវិញ រួចលាយទឹក ។គេបាន :

$L_1$ : ទឹកដែលបានក្រោយពីច្របាច់ និង ក្រណាត់

$L_2$ : ទឹកដែលបានពីការច្រាំកាក និង អាកុល ៩០ អង្សា

បន្ទាប់មកគេរំងាស់លាយទឹក $L_1$ ជាមួយទឹក $L_2$ រួចរំងាស់អោយអាប់ រហូតដល់បានជាតិកាវ ។ ក្នុងរបៀបនេះ គេអាចទុក[illegible] អំបិល "សូដ្យូមភ្លុយអរ" (NaF) នៅទីបញ្ចប់គេយកជាតិកាវនេះទៅធ្វើថ្នាំលាប ( Pommade 1/5 ) ។

[illegible] គេយកស្លឹកស្រស់បុកលាយជាមួយទឹកក្រូចឆ្មារ លាយអំបិលបន្តិច រួចយកទៅលាបលើស្រែង ។

របៀបយកផលលើដើមដង្ហិត :-

គេយកផលពីខែ ១០ ទៅខែ ១២ គេបេះស្លឹក និង ដើមនៅក្នុងរដូវទំហើយ និង រដូវរងាមុនពេលដើមមានផ្កា ប្រើស្រស់ ឬ យកទៅហាលអោយស្ងួត ។

- បន្ទន់លាមក : ប្រើក្នុងកំរិតពី ៤-៨ ក្រាម
- បញ្ចុះលាមក : ប្រើក្នុងកំរិតពី ១០-២០ ក្រាម "ម្សៅស្លឹក ឬ ម្សៅដើម" ផឹករាល់ថ្ងៃ ។



www.budinst.gov.kh www.elibraryofcambodia.org

## ២- ផ្កាកំពីងពួយគោក

ឈ្មោះកម្ពុជា : ផ្កាកំពីងពួយគោក

ឈ្មោះជាបារាំង : Pervenche de Madagascar

ឈ្មោះជាវិទ្យាសាស្ត្រ : Catharanthus roseus

Famille : Apocynaceae

១-លក្ខណៈរុក្ខសាស្ត្រ និង ភូមិសាស្ត្រ៖ -កំពីងពួយគោកគឺជារុក្ខជាតិតូចៗ ដែលមានកំពស់ពី ៣-៥ ឌ-ម ។ស្លឹកវាដុះទល់ទង្គា ហើយមានរាងមូលទ្រវែង ។



ផ្កាវាមានពណ៌ស ឬ ផ្កាឈូក ដុះចេញពីទងស្លឹកៗ ដែលវាមានចំនួនពីរនួមទងតែមួយ ។ដើមរុក្ខជាតិនេះមានពណ៌ស ជួរបន្តិច លាយលឿង និង ក្លិនក្រពុល ។

ដើមផ្កានេះមានប្រភពចេញមកពីប្រទេសម៉ាដាហ្គាស្កា (Madagascar) តែគេអាចរកឃើញមាននៅក្នុងប្រទេសក្តៅដែលគេដាំសំរាប់លំអផ្ទះ ឬ សួនច្បារ ។

២-លក្ខណៈគីមី និង ឥទ្ធិពលថ្នាំ :

គេបានស្រាវជ្រាវជាច្រើនអំពីដើមកំពីងពួយគោកនេះ ហើយនាបច្ចុប្បន្ន គេបានកំណត់ថាមានជាតិអាល់កាឡូអ៊ីត ( Alcaloïde ) ប្រើសំរាប់បញ្ចុះការឡើងឈាមឡើងស (Hypertension artérielle)ដូចជាអាល់កាឡូអ៊ីត( Alcaloïde )នៅក្នុងដើម រ៉ូវ៉ុលហ្វីយ៉ា ស៊ែកប៉ង់ទីណា បិនតិ៍( Rauwolfia serpentina Benth)ដែរ ។

ក.-យោងតាមការពិសោធន៍របស់មហាជន ជាតិថ្នាំមានឥទ្ធិពលព្យាបាលជម្ងឺទឹកនោមផ្អែម " Diabête "។ នៅក្នុងឆ្នាំ ១៩៣២ លោក វ៉ាត់ និង ប្រ៊ែយរ័( Watt et Breyer ) បានរកឃើញសារជាតិសកម្មមួយឈ្មោះ ឌីស៊ីតាលីន(Digitaline)និងក្នុងឆ្នាំ ១៩៤៤ លោក ហ្គាកស៊ីយ៉ា អែហ្វ ( Garcia F ) បានរកឃើញសារជាតិមួយប្រហាក់ប្រហែលទៅនឹង អាំងស៊ុយលីន ( Insuline ) ។

ខ.-នៅក្នុងឆ្នាំ ១៩៥៣ អ្នកស្រាវជ្រាវឈ្មោះ ប៉ារីសអែរ និង ម៉ូយ មីញ៉ុង អ្នកស្រីហាស់ ( Paris R et Moyse Mignon, $M^{me}$ H ) បានចំរាញ់ទូទាំងដើម និង ដាពីរលេខពីសំបករបស់ឫសយកជាតិ អាល់កាឡូអ៊ីត ( Alcaloïde )មួយដែលមានឈ្មោះថា វ៉ាំងសេអ៊ីន ( Vincéine ) ដែលមានឥទ្ធិពលសំរាប់ព្យាបាលជម្ងឺស្លាក សរសៃប្រសាទដោយសារប្រតិកម្មរបស់ស្នូល អាំងដូលិក( Noyau indolique ) ។

គ.-តាមលក្ខណៈវិទ្យាសាស្ត្រ និង តាមការបណ្តុះបណ្តាលរកមេរោគ អ្នកវិទ្យាសាស្ត្រ



www.budinst.gov.kh www.elibraryofcambodia.org

ណ្ឌាបានរកឃើញលើដើមនេះនូវអាល់កាឡូអ៊ីត ( Alcaloïde ) មួយដែលមានឥទ្ធិពលសំរាប់ព្យាបាលជម្ងឺបញ្ហាកទិកឈាមលើសដូចគ្នាទៅនឹង អាល់កាឡូអ៊ីតនៅក្នុងដើម រ៉ូវ៉ុលហ្វីយ៉ា ស៊ែរប៉ង់ទីណា មិនតិចដែរ ។ក្រៅពីពួកអាល់កាឡូអ៊ីតគេឃើញមាន :

- រេស៊ែរពីន ( Réserpine )
- ស៊ែរប៉ង់ទីន ( Serpentine )
- អាយ៉ាម៉ាលីស៊ីន ( Ajmalicine )

គេបានរកឃើញអាល់កាឡូអ៊ីត ៧ មុខទៀតដែលមិនសូវសំខាន់ ក្នុងការព្យាបាលទេ ។

៣-ការប្រើប្រាស់ និង គំរិតប្រើក្នុងការព្យាបាលជម្ងឺ :

-នៅប្រទេស វៀតណាម និង នៅប្រទេសចិនមានកន្លែងខ្លះគេយកដើម និង ស្លឹកហាលអោយស្ងួតផ្សាំទឹកផឹកសំរាប់បញ្ហាទឹកនោម ,បញ្ហាលាមក ,ជម្ងឺនោមឈាម ( Hématurie ) និងធ្វើអោយនូវទៀង ។នៅប្រទេស អាហ្វ្រិក ប្រជាជនច្រើនប្រើដើមកំពីងពួយនេះសំរាប់ព្យាបាលជម្ងឺទឹកនោមផ្អែម ,ជម្ងឺចេញញើសច្រើនជំនួយការរំលាយអាហារ និង ជម្ងឺរាគមួល ។

-ជាតិវ៉ាំងកាឡឺកូប្លាស្ទីន ( Vincaleucoblastine សំរាប់ព្យាបាលរោគមហារីកឈាម ( Leucémie )។

-ឫស សំរាប់ព្យាបាលជម្ងឺលើសឈាម ,បញ្ហាលាមក ,បំបាត់គ្រុនក្តៅ ។

-ស្លឹក និង ដើមសំរាប់ព្យាបាលរោគស្រែស្បែក ,បន្ទោរឈាម និង ទឹកនោមផ្អែម ។

ប្រយ័ត្ន : -ជាតិវ៉ាំងកាឡឺកូប្លាស្ទីនជាជាតិពុល ( Tableau A) ដូចេះការប្រើប្រាស់ដើមថ្នាំនេះ ត្រូវមានការប្រុងប្រយ័ត្នជាខ្លាំងដោយធ្វើការត្រួតពិនិត្យ គ្រាប់ឈាមក្រហម ជាប់ជានិច្ច ។



3- ផ្កា រំ យោ ល

ឈ្មោះកម្ពុជា : ផ្ការំយោល

ឈ្មោះជាបារាំង : Rose de Chine, Hibiscus .

ឈ្មោះជាឡាតាំង: Hibiscus rosa- sinensis L.

Famille : Malvaceae

១-លក្ខណៈបុតានិក និង ទីកន្លែងដាំដុះ

-ផ្ការំយោលគឺជាដើមផ្កាមួយតូច ។ស្លឹកវារាងមូលដូចពងក្រពើគ្មានរោម ហើយរាងមូលបន្តិចនៅខាងគល់ ។តែមស្លឹកមានរាងជាធ្មេញរណារ ។ស្លឹកនេះមានបណ្តោយប្រវែងពី ៥-៨ ស-ម និង មានទទឹងប្រវែងពី ៣-៦ ស-ម ។

-ផ្កាវាពណ៌ក្រហម ,ធំ ,មូល ហើយដុះចេញពីចន្លោះស្លឹក និង ដើមផ្កានេះសំបូរទៅដោយគ្រាប់មូលពុះច្រើនណាស់ ។ គេសង្កេតឃើញដើមផ្ការំយោលនេះ ច្រើនដុះនៅក្នុងប្រទេសឥណ្ឌូចិនដោយគេដាំធ្វើជា



www.budinst.gov.kh www.elibraryofcambodia.org

របងលំអជុំវិញគេហដ្ឋាន ។

២-សមាសភាពគីមី :

នៅក្នុងផ្កាមានជាតិ អង់តូស៊ីយ៉ាណូស៊ីត ( Anthocyanoside ) ។ក្រៅពីនេះ គ្មានសារជាតិសកម្មណាមួយគួរអោយកត់សំគាល់នៅក្នុងដើមផ្កាទំយោលឡើយ ។

៣-របៀបប្រើ និង ករិតប្រើក្នុងការព្យាបាល :

-គេប្រើស្លឹក និង ផ្កាទំយោល ដើម្បីបុកលាបសំរាប់ព្យាបាលដំបៅព្រងបែកហៀរទឹករងៃ ហើម ប្រូសខ្ទុះ និង រលាកគ្រប់ប្រភេទ ។

-ក្នុងន័យនេះគេយកស្លឹក និង ផ្កាស្រស់បុកលាយអំបិលបន្តិចដំពោកបូស ។នៅពេលស្ងួតគេផ្លាស់សារជាថ្មីទៀត ។ ធ្វើបែបនេះ បូសនោះឆាប់ស្រកហើយមិនសូវឈឺទៀតផង ។

-គេប្រើសំបកសំរាប់ព្យាបាលជម្ងឺរដូវមិនទៀង ឬ រាំងរដូវ និង ជម្ងឺនោមទាស់ ។

-សំបករបស់ឫស គេយកដាំទឹកផឹក សំរាប់ព្យាបាលជម្ងឺរាគមួល ។

-ជួនកាលគេយកផ្កា សំរាប់បញ្ចុះលាមក និង ធ្វើអោយរលូតកូន ។

-នៅប្រទេសចិន គេយកសំបករបស់ឫសធ្វើជាថ្នាំសំរាប់ព្យាបាលជម្ងឺ រដូវមិនទៀង ឬ រាំងរដូវ ។

កំណត់សំគាល់: -នៅប្រទេសចិន និង នៅក្នុងប្រទេសឥណ្ឌូចិន គេប្រើដើមឈើប្រហាក់ប្រហែលគ្នានេះដូចជា:

- Hibiscus syriacus L.
- Hibiscus chinensis DC

នៅក្នុងប្រទេស ម៉ាឡាយូ គេយកផ្កាទំយោល លាយទឹកក្តៅនិងផឹកដូចតែ ដើម្បីបញ្ចុះលាមក និង សំរាប់ព្យាបាលរោគលើស្បែក និង រមាស់លើស្បែក ។



## 4 - ដើមស្លា

ឈ្មោះកម្ពុជា : ដើមស្លា

ឈ្មោះជាបារាំង : Aréquier

ឈ្មោះជាឡាតាំង :Areca catechu Lin.

Famille : Palmae

១-លក្ខណៈបូតានិក និង ទីកន្លែងដាំដុះ

ស្លាគឺជាដើមឈើមួយដែលមានកំពស់ពី ១០-២០ ម ។ ស្លឹកវាផ្គុំជាកញ្ចុំៗ ហើយវែងៗ ។ផ្កាវាផ្គុំគ្នាជាកញ្ចុំ ហើយក្តោបទៅដោយស្រទបផ្កា ។

ផ្លែស្លារាងប៉ុនពងមាន់ ។នៅពេលខ្ចី វាមានពណ៌បៃតង លុះដល់ពេលទុំពណ៌នេះក្លាយទៅជាពណ៌លឿងទុំ ។គេសង្កេតឃើញមានគ្រាប់តែមួយទេ ចំពោះផ្លែស្លាមួយ ។គេយកផ្លែស្លាបេះហើយ មកបកសំបកចេញបន្ទាប់



www.budinst.gov.kh www.elibraryofcambodia.org

មកគេយកទៅស្ងោរនឹងទឹកកំបោរ ហើយនៅទីបញ្ចប់គេស្រង់យកទៅហាលថ្ងៃតែម្តង ។

ដើមស្លាមានប្រភពចេញមកពីប្រទេស ម៉ា ឡេ យូ និង បន្ទាប់មកគេបានដាំដើមនេះ ជាច្រើននៅក្នុងប្រទេសឥណ្ឌា, ឥណ្ឌូណេស៊ី, ហ្វីលីពីន និង ក្នុងប្រទេសឥណ្ឌូចិន ។

១-សមាសភាពគីមី :

គេអាចរកឃើញនៅក្នុងគ្រាប់ស្លានូវសមាសភាពគីមីដូចតទៅ :

-ទឹក : 3-5 %
-អំបិលខនិជ : 1-2 % ( Matières minérales)
-ជាតិគ្លុយស៊ីត : 50-60% ( Glucides )
-ជាតិប្រូទីត : 5-10% ( Protides )
-ជាតិលីពីត : 10-15% ( Lipides )
-ជាតិតាណូអ៊ីត : ( Tanoïdes )
-ជាតិអាល់កាឡូអ៊ីត : ដូចជា :
  -គុយវ៉ាស៊ីន : ( Guvacine )
  -អារេកាអ៊ីឌីន : ( Arécaïdine )
  -អារេកាអ៊ីន : ( Arécaïne )
  -អារេកូលីន : ( Aréoline)

២-ការប្រើប្រាស់ និង កម្រិតប្រើក្នុងការព្យាបាលជម្ងឺ :

ក.-ផ្លែស្លា គេច្រើនយកទៅប្រើជាថ្នាំទំលាក់ព្រូន សំរាប់សត្វពាហនៈ ដោយប្រើកំរិត ៤ ក្រាម ។ បើគេប្រើ អារេកូលីនវិញ គេប្រើក្នុងលក្ខណៈជាប្រូមីដ្រាតក្នុងកំរិតពី ០,៥-១ ម.ក្រ
ខ.-ប្រើបញ្ចុះព្រូនគោយនុស្ស ដោយលាយស្ករ និង គ្រាប់ល្ពៅ ។
គ.-គេប្រើគ្រាប់ស្លាទុំជាថ្នាំជំនួយដល់ការរំលាយអាហារ សំរាប់ព្យាបាលរបួស រលាកពោះវៀន និង មួល ដោយប្រើកំរិតស្លាទុំ ពី ០,៥-៤ ក្រាមក្នុងមួយថ្ងៃ ។
ឃ.-គេអាចប្រើក្នុងការព្យាបាលកមរមាស់ ឬលលើក្បាលក្មេង ដោយយកផ្លែស្លាបុកគោយទៅជាម្សៅ ហាលអោយស្ងួតរួចលាយជាមួយនឹងប្រេងដូង លាបតែម្តង ។ធ្វើរបៀបនេះត្រូវមានការប្រុងតពិនិត្យក្នុងការព្យាបាល ពីព្រោះមានជាតិពុល ។

គេអាចផ្សំផ្លែស្លានឹងឈើផ្សេងទៀត ដើម្បីព្យាបាលជម្ងឺគ្រុនចាញ់ ។

កំណត់សំគាល់ : ១-គេយកសំបកផ្លែស្លា សំរាប់បញ្ចុះនោម
២-ស្លាព្រៃ ( Areca labensis L. ) ប្រើដូចគ្នានឹងស្លាស្រុកដែរ ( Areca catechu) ប៉ុន្តែ ស្លាព្រៃមួយប្រភេទទៀតឈ្មោះ (Pinanga baniensis ) គេមិនសូវប្រើទេ ។



www.budinst.gov.kh www.elibraryofcambodia.org

## 5- វល្លិកន្ទ្រំធារី

ឈ្មោះកម្ពុជា : វល្លិកន្ទ្រំធារី

ឈ្មោះជាឡាតាំង : Stephania pierrei

Famille : Menispermaceae

### ១.លក្ខណៈរុក្ខសាស្ត្រ និង ទីកន្លែងដុះ

កន្ទ្រំធារីគឺជាវល្លិ មានប្រវែងជារាប់ម៉ែត្រ ។ ឫសវាសម្បូរជាមើមធំមានទំហំខ្លះ គេឃើញមានមើមទម្ងន់ពី ៤០-៥០ គ.ក្រ ។ វល្លិនេះមានពណ៌បៃតងចាស់ៗនៅពេលចាស់វល្លិនេះមានឫសជំនួយ ។ ស្លឹកវាស្តើងរាងមូលហើយដុះឆ្លាស់គ្នា ។ ផ្កាវាតូចៗពណ៌ក្រម៉ៅ ។ ផ្លែវារាងមូលពណ៌ក្រហមស្រស់ ។ គ្រាប់មានរាងដូចក្រចកសេះ ។ មើមវាដុះនៅក្នុងដីដូចមើមក្តួច ។ នៅប្រទេសកម្ពុជា គេឃើញវល្លិកន្ទ្រំធារីមានដុះនៅនឹងវាលទំនាបជាពិសេសកន្លែងដីដំបូក ។



វាដុះផ្កាគឺពីខែ ៤ ទៅដល់ខែ ៦ ហើយផ្លែពីខែ ៨ដល់ខែ ១០ ។

### ២.សមាសភាពគីមី :

សារធាតុសំខាន់នៅក្នុងមើមកន្ទ្រំធារី មានដូចតទៅ :

-រ៉ូតុងឌីន ( Rotundine ) ឬ តេត្រាអ៊ីដ្រូប៉ាល់ម៉ាទីន (Tétrahydropalmatine) ដែលមានអត្រាពី 1,2 - 1,5 % នៃមើមស្រស់ ។ ឯរូបមន្តមានដូចខាងក្រោមនេះ : $C_{13} H_{19} ( OCH_3)_3 CH_3N$

-ហ៊ីនដារីន ( Hyndarine ) ឬ ដេ-អ៊ែលតេត្រាអ៊ីដ្រូប៉ាល់ម៉ាទីន ( D.L Tétrahydropalmatine ) ។

-រ៉ូមែរស៊ីន ( Rœmersine ) ។

### ឥទ្ធិពលថ្នាំនៃជាតិរ៉ូតុងឌីន :

ឥទ្ធិពលនៃជាតិថ្នាំ រ៉ូ តុង ឌីន( Rotundine ) ដែលបានស្រាវជ្រាវក្នុងប្រទេសវៀតណាម ( Revue médicale française d'Extrême Orient) នៅប្រទេស សូវៀត "នៅវិទ្យាស្ថានឥទ្ធិពលថ្នាំ និង ជាតិពុលខែ ៣-១៩៦១" នៅប្រទេស រូម៉ានី "១៩៦៣" និង នៅប្រទេសចិន "ខាងវិទ្យាស្ថានរាយការណ៍ឱសថ" គេបានទទួលលទ្ធផលដូចខាងក្រោមនេះ :

ក-រ៉ូតុងឌីនមានជាតិពុលតិច : គេអាចចាក់តាមសរសៃឈាមខ្មៅក្នុងទន្សាយ និង កំរិតខ្ពស់បំផុត "៣០ ម.ក្រ/1 Kg" ទន្សាយគ្រាន់តែវេទនាពីមួយថ្ងៃទៅ ២ ថ្ងៃ ប៉ុណ្ណោះ ។

ខ-ធ្វើអោយបន្ថយការកន្ត្រាក់ពោះវៀន (Diminution du péristaltisme )

គ-ធ្វើអោយចង្វាក់បេះដូងដើរទៀង ( Régularisation du rythme cardiaque )

ឃ-ធ្វើអោយដកដង្ហើមធូរ ( Broncho - dilatateur )

ង-បញ្ចុះកំរិតឈាមលើស



www.budinst.gov.kh www.elibraryofcambodia.org

៣_ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាលជំងឺ: _ក្នុងចំណោមប្រជាជន គេយកមើម ក្រន្ធំាធាទី ចិតអោយស្តើង រួចហាលថ្ងៃអោយស្ងួតសំរាប់ដាំទឹកផឹក និង ត្រាំស្រាដើម្បីព្យាបាលជំងឺ ពិត ក្អករបេង រាគមួល គ្រុនក្តៅ ឈឺពោះ ដោយផឹកពី ៣ ៨ល់ ៦ក្រាមក្នុង១ថ្ងៃ ។ គេអាចបុកកំទេចទៅ ជាមេម្សៅរួចត្រាំស្រា ៤០ អង្សាដោយលាយមេម្សៅ ១ភាគ និង ស្រា ៥ ភាគ ឯកំរិតប្រើគឺពី ៥ ទៅ ១៥ម.លស្រាក្នុង ១ ថ្ងៃ ។ គេអាចដាក់ថ្នាំបន្តុះដើម្បីអោយជាឈឺក ។

Rotundine chlorhydrate ប្រើសម្រាប់ថ្នាំសំរាប់ព្យាបាល គ្រុនក្តៅខ្លាំង ឈឺក្បាល ឈឺពោះ ផ្ទង ធ្វើអោយស្ងប់ស្ងៀមដោយប្រើកំរិតពី ០,០៥ ទៅ ០,១០ ក្រាមក្នុងមួយថ្ងៃជាមេម្សៅ ឬ ថ្នាំគ្រាប់ ។

គេអាចចំរាញ់ធ្វើជាថ្នាំចាក់ក្នុងលក្ខណៈជា គ្លរីប្រាត ឬ ស៊ុលហ្វាត · រ៉ូតុងឌីន (Rotundine chlorhydrate-sulfate) ដាក់ក្នុងអំពូល ៥ម.ល ក្នុងកំរិតមេម្សៅ ០,០៥ក្រាម ។ ពីព្រោះគេបិល រ៉ូតុង ឌីនមិន សូវរលាយទៅក្នុងទឹកទេ ។

កំរិតប្រើ : _កូនក្មេង អាយុពី ១ ទៅ ៥ ឆ្នាំ

_០,០២ ក្រ - ០,០២៥ ក្រ ក្នុង ១ ថ្ងៃ

_កូនក្មេងអាយុពី ៥ ទៅ ១០ ឆ្នាំ

_០,០៣ ក្រ - ០,០៥ ក្រ ក្នុង ១ ថ្ងៃ

## ស្លឹង

_ឈ្មោះជាកូដជាំ : ដើមស្លែង

_ឈ្មោះជាបារាំង : Vomiquier-Fausse Angusture

_ឈ្មោះវិទ្យាសាស្ត្រ : Strychnos-nux-Vomica Lin

_Famille : Loganiaceae

១_លក្ខណៈរុក្ខសាស្ត្រ និង ភូមិសាស្ត្រដាំដុះ : ក_ប្រភព : _ដើមស្លែងគឺជាដើមឈើមួយដែលប្រើនដុះ នៅតំបន់អាស៊ីត្រូពិកក្តៅហើយសើម ។ គេអាចរកឃើញ ដើមស្លែងនៅក្នុងប្រទេសឥណ្ឌា ជាពិសេសនៅតំបន់ឆ្នេរសមុទ្រ Coromandel et Malabar ។ ដើមប្រភេទនេះ គេឃើញដុះផងដែរនៅប្រទេសសៀមរាម ភូមា ចិន នៅកូសាំងស៊ីន និង នៅក្នុងភាគខាងជើងនៃប្រទេសអូស្ត្រាលី ។ គេយកផលវាដែរនៅ Cameroun ។ គ្រប់ផ្នែកទាំងអស់របស់រុក្ខជាតិនេះសុទ្ធតែពុលជាពិសេសគឺ គ្រាប់ស្លែង និង សំបក សំបកដើមស្លែងមានជាតិ Strychnine បន្តិចបន្តួច រីឯគ្រាប់មានជាតិ Brucine ។



ខ_ប្រវត្តិ : _ជាយូរយារណាស់មកហើយ ដែលស្លែងគេប្រើសំរាប់ពុលសត្វ ឆ្កែ និង ពួកសត្វពាហនៈចម្រៀង។ គេប្រើវាក្នុងវេជ្ជសាស្ត្រជាថ្នាំដោយសារជាតិពុលរបស់វា។ គេប្រើវាក្នុងការព្យាបាល និង សំគាល់ជាតិ ក្រោយពីការសិក្សា និង រកឃើញការជាតិសកម្មគឺ STRYCHNINE ។

គ. ការយកផល - ការយកផលគឺប្រព្រឹត្តទៅដោយងាយ គេយកគ្រាប់ផ្លែចេញពីសាច់ដោយសារការលាងផ្លែ នឹងទឹក រួចយកវាទៅហាលអោយស្ងួត នឹង កំដៅព្រះអាទិត្យ ។ បន្ទាប់មកគេរើសយកសុទ្ធតែគ្រាប់ល្អ រួចច្រកចូលក្នុងស្បោង និង នាំចេញពីប្រទេសឥណ្ឌា ទៅ ទ្វីបអឺរ៉ុបតែម្តង ។

ឃ. ការពិពណ៌នាអំពីដើម និង ផ្លែស្លែង

ស្លែងគឺជារុក្ខជាតិមួយមានកំពស់ពី ១២ ទៅ ១៣ ម គ្មានរោមមានសំបកពណ៌ប្រផេះ ។ ស្លឹកវានៅទល់មុខគ្នា រាងមូលទ្រវែង ស្រួចចុង គ្មានរោម រលោងហើយមានប្រវែងពី ៥-១០ ស-ម និង មាន ទទឹងពី ៣-៩ ស-ម ព្រមទាំងមានទ្រនុងតូចៗចំនួនពី ៣-៥ ។ទ្រនុងស្លឹកកណ្តាល មានបណ្តោយប្រវែងរហូតទៅដល់ចុងស្លឹក ។

ផ្កាវាតូចពណ៌ស ឬ ពណ៌ខៀវស្រាលបៃតងបន្តិច ។

ផ្លែវារាងមូលហើយមានពណ៌ និង ទំហំដូចផ្លែក្រូចតូចមួយ ។ នៅពេលខ្ចី ផ្លែនេះមានពណ៌បៃតង លុះដល់ពេលទុំ ពណ៌នេះក្លាយទៅជាពណ៌លឿង ហើយមានវិជ្ជមាត្រប្រែប្រួលពី ៣,៥-៧ ស-ម ។ ផ្លែនោះផ្ទុកទៅដោយសាច់គ្រាប់ពណ៌ស អន្លាយៗ ព្រមទាំងមានរសជាតិល្វីងផង ។ ផ្លែនេះជួនកាលធំ ឬ តូចទៅតាមតំបន់ដែលវាដុះ ។

ចំណែកគ្រាប់ផ្លែមានចំនួនច្រើន និង មានទំហំមិនទៀងទាត់ ដុះនៅបញ្ច្រាស និង គ្មានរបៀបក្នុងផ្លែ ។ គ្រាប់ផ្លែស្លែងនេះ គឺជាគ្រាប់មួយរាងដូចថាសរំប៉ែត ពណ៌ប្រផេះ ហើយមានរោមក្រាស់បន្តិច ។ វាមានវិជ្ជមាត្រពី ២ ទៅ ២,៥ ស-ម និង មានកំពស់ពី ៤ ទៅ ៦ ម.ម ។ រោមគ្រាប់វាតូចឆ្មារ ហើយញៀកខ្លាំងរុំពទ្ធ័ជុំវិញផ្ចិត ដែលធ្វើអោយក្រឡាផ្ទៃវាចាំងដូចក្រណាត់សូត ។ សាច់គ្រាប់វាជាមព្រាលៗ បង្កើតបានជាផ្នែកមួយធំជាងគេរបស់គ្រាប់ បង្កើតបានជា ២ ផ្នែករាងដូចថាស និង ភ្ជាប់គ្នា និងមានប្រហោងតូចមួយសំរាប់ដាក់ពន្លកដុះ ។

២ សមាសភាពគីមី :

សាច់គ្រាប់មានជាពិសេសជាតិ Mannane និង Galactane ច្រើន ។

-ក្រៅពីនេះ គ្រាប់ស្លែងមាន :

- Protides
- ជាតិប្រេង ( 4% )
- Hétéroside - Loganoside
- និង មាន alcaloïdes ជាច្រើននៅលាយចំរុះជាមួយនឹង Acide igasurique ជាពិសេសមាន alcaloïde ពីរដែលសំខាន់គឺ Strychnine និង Brucine ។

ក្រៅពីនេះមាន :

- Base ពីរយ៉ាងគឺ Colubrine α & β
- Vomicine និង
- Struxine ដែលមិនប្រាកដជាមានទៀងទាត់នៅក្នុងផ្លែស្លែងទេ ។



www.budinst.gov.kh www.elibraryofcambodia.org

៣-ការប្រើប្រាស់ក្នុងការព្យាបាល -សារធាតុសំខាន់ដែលប្រើក្នុងការព្យាបាលគឺ (STRYCHNINE)

-គេប្រើ STRYCHNINE ក្នុងការព្យាបាលជំងឺ "អស់កម្លាំងល្ហិតល្ហៃ"

-ប្រជាជន វៀតណាមប្រើផ្លែស្លែងដែលគាត់ស្គាល់ថាជាផ្លែឈើមួយមានគ្រោះថ្នាក់នោះដើម្បីព្យាបាលរោគសើស្បែក ដោយធ្វើអោយទៅជាម្សៅលាយជាមួយប្រេង និង ប្រើសំរាប់បំពុលសត្វកណ្ដុរ ។

-ប្រជាជនកម្ពុជាយើង ច្រើនប្រើគ្រាប់ស្លែង និង សំបកស្លែងក្នុងការការព្យាបាលជំងឺច្រើនមុខ :

-គ្រាប់ស្លែងប្រើសំរាប់ ធ្វើអោយក្អួតដោយមានកំរិតត្រឹមតែលេប ១ គ្រាប់ប៉ុណ្ណោះ តែបើលេប ២ គ្រាប់វិញ នឹងធ្វើអោយមានគ្រោះថ្នាក់ ។

-សំបកគេប្រើសំរាប់ព្យាបាលផ្នែកខាងក្រៅសរីរាង្គ គេឆុងវានឹងទឹកក្ដៅដូចតែសំរាប់ព្យាបាលជំងឺប្រកាច់ឆ្កួតជ្រូក ហើយកំរិតថ្នាំក្នុងការប្រើវិញ ក៏ត្រូវចាប់ផ្ដើមពីកំរិតតិចទៅមុន ។

## ដើមត្របែក

-ឈ្មោះកម្ពុជា : ដើមត្របែក

-ឈ្មោះជាបារាំង : Goyavicr

-ឈ្មោះជាឡាតាំង : Psidium guajava

- Famille : Myrtaceae

១-លក្ខណៈរុក្ខជាតិ និង ទីកន្លែងដំណុះ : -ដើមត្របែកគឺជាដើមឈើមួយដែលមានមែកសាខា ។ ស្លឹកវាមានទងខ្លីហើយដុះទល់មុខគ្នា ។ស្លឹកនេះមានរាងមូលដូចពងក្រពើ គ្មានរោម ឬ ជួនកាលមានរោមបន្តិចពុំផង ។



ផ្កាវាពណ៌ស ដុះតែមួយពុំទេ ហើយមានស្លាកស្នាមរាងមូល តែកពុំនៅខាងចុងផ្លែ ។ ផ្លែនេះសំបូរណ៍ទៅដោយគ្រាប់ណាស់ ។ គ្រាប់វាច្រើននេះមានរាងដូចក្រលៀនជ្រូកលាយមូលបន្តិចពុំ ហើយមានទំហំមិនស្មើគ្នាទេ និង មានពណ៌ក្រហម ក្រៀងនៅពេលទុំ។

គេសង្កេតឃើញត្របែកមានដុះនៅពាសពេញក្នុងជួរកោះនៃប្រទេសអណ្ដា អូសេអានី និង នៅ ប្រទេសអាហ្វ្រិចជាពិសេស ដើមត្របែកប្រភេទនេះដុះនៅក្នុងប្រទេសទាំង ៣នៃឥណ្ឌូចិន ដុះនៅពាសពេញទីព្រៃ វាលទំនាប ឬ គេដាំធ្វើរបង និង លំអផ្ទះ។

២ សមាសភាពគីមី :

-ក្នុងផ្លែស្រស់ចកមាន :

-ប៉ិចទីន (Pectine)

-វីតាមីនសេ (Vitamine C )

បរិមាណវីតាមីនផ្លាស់ប្តូរទៅតាមបំណែកនៃផ្លែ និង ទៅតាមប្រភេទដើមស្រទ័ប ។ បរិមាណវីតាមីនប្រមូលផ្តុំច្រើនបំផុតនៅសំបកខាងក្រៅ និង បន្ទាប់មកនៅសាច់សំបក ។

-នៅក្នុងស្លឹក និង ក្នុងគ្រាប់ស្រទ័បមានជាតិចត់ ( Tannin ) ពី 7 ទៅ 10 %

-ជាតិជ័រប្រមាណ 3 %

-និង មានជាតិប្រេងតិចតួច ( 0, 36 % )

មានអ្នកស្រាវជ្រាវខ្លះ ឃើញក្នុងដើម និង ស្លឹកមានជាតិ Composé triterpénique 1 % ចំពោះស្លឹក និង មាន 0,3% ចំពោះសំបកដើម ។ នៅក្នុងគ្រាប់មានជាតិប្រេង 14 % "គ្លីនក្រអូប" ជាតិប្រូទីត Protide 15 % និងជាតិទឹកស្ករ 13 % ។

៣ ការប្រើប្រាស់ និង វិធីប្រើក្នុងការព្យាបាលជម្ងឺ :

- ... ផ្លែស្រទ័បនៅពេលខ្ចី មានជាតិចត់ធ្វើអោយលាមករឹង គេយកវាទៅព្យាបាលជម្ងឺរាគ ។ នៅពេលទុំ វាមានឥទ្ធិពលសំរាប់បន្ធូរលាមក ។ គេហូបផ្លែស្រទ័បទុំ ឬ ធ្វើជាដំណាប់ ។ ស្លឹកខ្ចី និង គ្រាប់មានជាតិថ្នាំសំរាប់ព្យាបាល ពោះ និង រាគ ។

តាមការពិសោធន៍របស់ប្រជាជន គេប្រើឱសថនេះទៅដាំទឹកផឹក ក្នុង ១ ថ្ងៃពី ១៥ ទៅ ២០ ស្លឹកខ្ចី និង ត្រូវគេប្រើដោយឡែក ឬ ក៏ផ្សំជាមួយជាតិថ្នាំផ្សេងទៀត ឬ ម្យ៉ាងទៀត ជាមួយតែ ឬ ជាមួយខ្ចី ។

សំបកឫស និង សំបកដើមប្រើសំរាប់ព្យាបាលជម្ងឺរាគ ឬលាងរបួសដែលរលេះរលួយ ។ គេអាចដាំទឹកផឹក ដោយយក ១៥ ក្រាម នៃសំបកឫស ឬ សំបកដើមជាមួយទឹក ២០០ ម.ល ។ គេធ្វើរបៀបនេះ រហូតដល់នៅសល់ទឹកប្រហែល ១០០ ម.លទើបគេផឹកតែម្តង ។។

៚៚៚៚៚៚៚៚៚៚៚៚៚៚៚

8 - ដើមស្រលៅ

ឈ្មោះកម្ពុជា :

ឈ្មោះជាបារាំង : Myrobolan de Commerce

ឈ្មោះជាឡាតាំង : Terminalia chebula Retz

Famille : Combretaceae

១ លក្ខណៈរុក្ខសាស្ត្រ និង ភូមិសាស្ត្រដាំដុះ

-ស្រលៅគឺជាដើមឈើមួយ ដែលមានកំពស់ពី ១៥ ទៅ ២០ ម ។ សំបកដើមវាពណ៌ខ្មៅ ហើយមានឆ្នូតពុតាមបណ្តោយសាច់វា ។ ស្លឹកទល់មុខ រាងពងក្រពើមូលៗ ខ្លីៗ ហើយរាងវែងទៅខាងគល់ស្លឹក និង រីកធំទៅខាងចុង ។



www.budinst.gov.kh www.elibraryofcambodia.org

ស្លឹកនេះមានបណ្ដោយប្រវែងពី ១៥ ទៅ ២០ ស-ម និង មានទទឹងប្រវែងពី ៧ ទៅ ១៥ ស-ម ព្រមទាំងមានរោមនៅសងខាងផង ។ ផ្កាវាតូចៗ មានពណ៌ស លាយលឿងហើយមានក្លិនក្រអូប ។ ផ្កានេះដុះចេញជាច្រើនទងនៅចន្លោះមែក និង ដើម ឬ ដុះនៅខាងចុងដើម ហើយមានរោមពណ៌ដូចស្លាន់ ។ ផ្លែវារាងមូលទ្រវែងដូចពងក្រពើហើយមានបណ្ដោយប្រវែងពី ៣ ទៅ ៤ ស-ម និង មានទទឹងប្រវែងពី ២២ ទៅ ២៥ ស-ម ។ ផ្លែនេះមានពណ៌លាចប្រផេះ លាយលឿងបន្តិច ។ លុះទុំវាពណ៌ខ្មៅ ហើយរលៀងរឹង និង តាន់ [illegible] វាល្អិត ។ គ្រាប់ផ្លែមានតែ ១ គត់ ហើយមានកំពស់ ៤ ម.ម ។



២-សមាសភាពគីមី :

-គេបានរកឃើញនៅក្នុងផ្លែ នូវជាតិអាស៊ីតមួយ ដែលគេអោយឈ្មោះថា អាស៊ីត សេ ប៊ុយ លី នីក Acide chébulinique ដែលមានរូបមន្ត : $C_{41} H_{34} O_{27}$ ( ពី 3 ទៅ 4 % ) អាស៊ីតនេះប្រហាក់ប្រហែលទៅនឹងអាស៊ីត ហ្គាលីក និង តានីក (Acides galliques et tanniques ។ គេបានរកឃើញនៅក្នុងផ្លែនូវជាតិពីរយ៉ាងទៀតគឺ :

-ជាតិ អូលេអូ-រេស៊ីនឹស (Matière oléo-résineuse ) ពណ៌បៃតង ។ ពណ៌នេះនឹងក្លាយទៅ លាយចំរុះជាមួយ អាស៊ីត នីទ្រិក ( Acide nitrique ) គឺក្លាយទៅជាពណ៌ក្រហម ។

-ជាតិចត់ ( Tannin ) ដែលមានពី 46 % ទៅ 51,3% នៅក្នុងផ្លែទុំល្អ ។

នៅក្នុងបណ្ដុំគ្រាប់ មានជាតិប្រេងប្រហែល 36,7% ពណ៌លឿងថ្លា ហើយល្វីងបន្តិច ។

៣-ការប្រើប្រាស់ និង កំរិតប្រើក្នុងការព្យាបាលជំងឺ : -គេប្រើ :

-ផ្លែស្រមៀមិនទាន់ទុំក្នុងការព្យាបាលជំងឺ "រាគធម្មតា និង រាគមួល" ដោយប្រើកំរិតពី ៣ ទៅ ៦ ក្រាម ២ ដងក្នុង ១ ថ្ងៃ សំរាប់ព្យាបាលជំងឺក្អកស្អកស្រលេង ដើម្បីហូរទឹកកាម ចេញញើសច្រើន ដើម្បីបូសផ្សងបាត ។ បើប្រើកំរិតខ្លាំងលើសពីខាងលើនេះ គឺសំរាប់បញ្ចុះលាមក ។ គេច្រើនប្រើផ្លែតូចៗ សំរាប់ផ្អករោគផ្ដាសាយ ។

-ផ្លែទុំសំរាប់បញ្ចុះលាមក ។ គេយកផ្លែស្រមៀទុំ ៦ បុកអោយម៉ត់ផាក់ស្ករជាមួយទឹកសំរាប់បញ្ចុះលាមក ។ ក្នុងករណីនេះ គេអាចប្រើតែផ្លែមួយ ក៏អាចគ្រប់គ្រាន់ហើយទៅ ហើយងាយការបញ្ចុះលាមក ។

-ផ្លែខ្ចីគេប្រើសំរាប់រំលាយអាហារ ជំនួយកម្លាំង និង បញ្ចុះលាមក ។ តាមការបញ្ជាក់របស់អ្នកស្រាវជ្រាវខ្លះបានអោយដឹងថា ផ្លែខ្ចីនេះគេប្រើសំរាប់ធ្វើអោយឃ្លានបាយ និង មានសារសំខាន់ណាស់ក្នុងការព្យាបាលជំងឺរបស់សរីរាង្គបំពង់រំលាយអាហារ ។ ចំណែកអ្នកស្រាវជ្រាវផ្សេងទៀតបានប្រើផ្លែស្រមៀខ្ចីនេះ សំរាប់ព្យាបាលជំងឺអាសកម្ម ធំទំនល់ពេង និង ប្រើសំរាប់ព្យាបាលជំងឺរាគធម្មតា និង រាគមួលដោយប្រើកំរិត ៨ ក្រាម ពីរដងក្នុង ១ ថ្ងៃ ។

ស្លឹកវា សំរាប់ប្រើក្នុងការព្យាបាលជំងឺរាគធម្មតា និង រាគមួលរបស់កូនក្មេងដោយប្រើកំរិត ៥ ស.ក្រ. ៣ ម៉ោងម្ដង ចំពោះក្មេងដែលមានអាយុ ១ ឆ្នាំ ។

រូបមន្តព្យាបាលជំងឺដោយប្រើផ្លែស្រមៀ : -ជំងឺរាគមួល : យកផ្លែស្រមៀ ១២ ផ្លែ, ៦ ផ្លែទុកអោយនៅស្រស់ ៦ ផ្លែទៀតយកទៅលីងអោយក្រៀម ឬ ខ្លោច យកគ្រាប់វាចេញ រួចបុកកំទេចអោយម៉ត់ ។ ក្នុងករណីនេះ ដែលមួល



www.budinst.gov.kh www.elibraryofcambodia.org

សំបោរលាយឃ្មុំបន្តិចៗ  គេផឹកទឹកដីកហើយលាយហើយ ៗ បើចូលសំបោរទទេគ្មានលាយឃ្មុំ  គេផឹកទឹកដីកតែម្តង ៗ

កំណត់ចំណាំ ៖ - ស្រម៉ និង ព្រះខ្នាទ្របីដូចគ្នា ៗ

## ១ - ដើមញរធំ

| | | |
|---|---|---|
| ឈ្មោះកម្ពុជា | : | ដើមញរធំ |
| ឈ្មោះជាបារាំង | : | Grand Morinda |
| ឈ្មោះជាឡាតាំង | : | Morinda citrifolia Lin. |
| Famille | : | Rubiaceae |

### ១ លក្ខណៈបូតានិក និង ភូមិសាស្ត្រដាំដុះ

ញរធំគឺជាដើមឈើមួយគ្មានទេរាម ៗ ស្លឹកវាធំបន្តិចរាងពងក្រពើប្រកបទៅដោយចុងស្រួច ឬ ជួនកាលទាលបន្តិច ៗ ស្លឹកនេះមានបណ្តោយប្រវែងពី ១២ ទៅ ៣០ ស-ម និង មានទទឹងប្រវែងពី ៦ ទៅ ១៥ ស-ម ហើយភ្លឺរលោងបន្តិច ៗ ផ្កាវាពណ៌ស ហើយមានវិជ្ជមាត្រប្រវែងពី ២ ទៅ ៤ស-ម ផ្លែវាទទេ រួមផ្សំឡើងដោយផ្លែតូចៗជាច្រើនពណ៌បៃតងស្រអាប់ ដែលនៅផ្សារភ្ជាប់គ្នាទៅវិញទៅមក ៗ គ្រាប់ផ្លែវាមានសំបករឹងមាំ ៗ ផ្លែញរធំនេះ គេអាចពិសារបានពេលវាទុំ ៗ



Morinda citrifolia L.

គេច្រើនដាំដើមឈើនេះ នៅតំបន់ឥណ្ឌូចិន ដែលមានប្រភពមកពីប្រទេសឥណ្ឌា ហើយក្រោយមកទៀត គេសង្កេតឃើញនៅរាយប៉ាយពេញទូទាំងប្រទេស ដែលមានធាតុអាកាសក្តៅ ហើយសើម ៗ

### ២ សមាសភាពគីមី :

នៅក្នុងស្លឹក និង ក្នុងសំបកឫស គេបានរកឃើញសារជាតិមួយគឺគ្លុយកូស៊ីត អង់ត្រាគីណូនិក (Glucoside anthraquinonique ) ដែលមានឈ្មោះថា ម៉ូរាំងឌីន (Morindine) ដែលមានរូបមន្ត : $C_{28} H_{30} O_{15}$ មានពណ៌លឿង អាចរលាយក្នុងទឹកពុះ មិនសូវរលាយក្នុងទឹកត្រជាក់ ហើយមិនរលាយក្នុង អេទែរ Ether ទេ ៗ ឆ្នាំ ១៩៦១ អ្នកស្រាវជ្រាវមួយចំនួនបានកំណត់ក្នុងដើមញរធំ មិនមែនត្រឹមតែមានជាតិ ម៉ូរាំងឌីន ប៉ុណ្ណោះទេ តែនៅមានសារជាតិជាច្រើនទៀតដូចជា :

- ជាតិ អាលីសារីន ( Alizarine )
- ជាតិដំណាកង់តាល ( Damnacantal ) ឬ 1.méthoxy-2-formyl-3 oxyanthraquinone
- ជាតិ 1-méthoxy rubiazin ou 1-méthoxy-2 méthyl 3 oxyanthra-quinone
- ជាតិម៉ូរាំងដុង ឬ 1-5-6- trioxy-2-méthyl anthraquinone

និងជាតិ 1-oxy-2-3- diméthoxy anthraquinone .



www.budinst.gov.kh www.elibraryofcambodia.org

របៀបប្រើ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាលជម្ងឺ :

-ផ្លែញី :

• -ផ្លែទុំ -ប្រើសំរាប់ព្យាបាលជម្ងឺផ្លូវមិនទៀង អោយបត់ជើងធូរ ក្អកផ្តាសាយ ឈឺទ្រូង ទឹកនោមផ្អែម

• -ផ្លែស្រស់ -ស្ងោរអោយឆ្អិន សំរាប់ព្យាបាលជម្ងឺរាគមួល ។

ស្លឹក : -ប្រើសំរាប់ព្យាបាលអាចម៍មិនទៀង និង អោយបត់ជើងធូរ ។ បើចុកអោយម៉ត់វិញ សំរាប់ព្យាបាលបូស ជួយដុះសក់ថ្មី ។ បើគេយកស្លឹកចំនួនពី ៨ ទៅ ១០ ក្រាមលាយល្បាយជាមួយទឹកចំនួន ៥០០ ម.ល ហើយផឹក ២ ដងក្នុងមួយថ្ងៃសំរាប់ព្យាបាលជម្ងឺរីងមុខ រាគធម្មតា រាគមួល គ្រុនក្តៅ និង ធ្វើថ្នាំកម្លាំង ។

ឬស : -ស្ងោរផឹកសំរាប់ព្យាបាលជម្ងឺ តេតាណូស ( Tétanos ) ឬធ្វើទឹកធ្វើជាតែ ដោយយកឬសទម្ងន់ពី ៣០ ទៅ ៤០ ក្រាម ផឹកជំនួសតែជារៀងរាល់ថ្ងៃ រហូត ១៥ ថ្ងៃ សំរាប់ព្យាបាលជម្ងឺលើសកំរិតឈាម ហើយលទ្ធផលគឺបានទទួលនូវជាទីពេញចិត្ត ។ ប្រជាជនជួនកាលយកឬសមកត្រាំស្រាផឹក ដើម្បីព្យាបាលរោគឈឺក្បាល ឈឺខ្នង ។

សំបកដើម : -ស្ងោរផឹក សំរាប់ជំនួយកម្លាំង ចំពោះស្ត្រីក្រោយពេលសំរាលកូនរួច ។

## 10 - ដើមកន្ទំថេត

ឈ្មោះកម្ពុជា : ដើមកន្ទំថេត

ឈ្មោះជាបារាំង : Tamarin sauvage , Lamtoro ( Java )

ឈ្មោះជាឡាតាំង : Leucaena glauca

Famille : Mimosaceae

១ លក្ខណះបុតានិក និង ទីកន្លែងដាំដុះ កន្ទំថេត គឺជាដើមឈើតូចមួយ ដែលមានកំពស់ពី ២ ទៅ ៤ ម៉ែ ឬ អាចលើសពីនេះទៅទៀត ។ ស្លឹកវាទល់ទងមានចំនួនច្រើន ហើយរួមទងតែមួយ ដែលមានប្រវែងពី ១២ ទៅ ២០ ស-ម ។



គេសង្កេតឃើញដើមកន្ទំថេតនេះនៅដុះពាសពេញដោយធម្មជាតិ ឬគេដាំធ្វើជារបងពាសពេញក្នុងទឹកដីយើង ។ សត្វពាហនៈ ចូលចិត្តស៊ីស្លឹកវានេះណាស់ ។ ពេលផ្លែទុំ គេបេះយកមកហាលអោយស្ងួត ឬ មួយឆ្អិនអោយស្ងួត ។ ក្រៅពីយកធ្វើថ្នាំ គ្រាប់វាបានត្រូវគេយកទៅធ្វើចំណីអោយសត្វ ។

២ សមាសភាពគីមី -នៅក្នុងគ្រាប់

-គ្មានជាតិទម្បា

-មានជាតិមុយស៊ីឡា ( Mucilage) ពី 12 ទៅ 14 %

-មានជាតិស្ករ

-មានជាតិខ្ជះ 4 - 45 %

-មានជាតិសាច់ 21 %

-មានជាតិខ្លាញ់ 5,50 %

Leucaena glauca(L) Bonth

Mimesaceae



www.budinst.gov.kh www.elibraryofcambodia.org

និងមានជាតិ ឡឺសេនីន (Leucénine) ។ ជាតិនេះមានអត្រានៅក្នុងស្លឹកក្រៀមប្រហែល 3 % និងនៅក្នុងគ្រាប់ 5 % ។ ជាតិនេះ ដូចគ្នាទៅនឹងជាតិ មី មូ ស៊ីន ( Mimosine) ដែលមាននៅក្នុងដើម មី មូ ស៊ា ពុយឌីកា(Mimosa pudica) ។

៣ _ឥទ្ធិពលថ្នាំ :

ក _នៅក្នុងជំនាន់អាណានិគមបារាំង គេបានយកគ្រាប់កន្ធំថេតទៅពិសោធ ដើម្បីព្យាបាលព្រូនបន្ដែះ ដោយប្រើកម្រិត ៥០ ក្រាម ១ ថ្ងៃ ។

១ _គេយកគ្រាប់កន្ធំថេតទៅព្យាបាលជម្ងឺព្រូន អោយកូនក្មេង ។ របៀបធ្វើមានកម្រិតដូចខាងក្រោមនេះ គេយកគ្រាប់ទាំងទៅលីង អោយឆ្អិន ហើយបុកជាម្សៅ ។

- ក្មេងអាយុ : ពី ៣ ដល់ ៥ ឆ្នាំ លេប ៥ក្រក្នុងមួយថ្ងៃ លេបក្នុងរយៈពេល៣ថ្ងៃ ។
- ក្មេងអាយុ : ពី ៦ ដល់ ១០ ឆ្នាំ លេប ៧ក្រក្នុងមួយថ្ងៃ លេបក្នុងរយៈពេល៣ថ្ងៃ។
- ក្មេងអាយុ : ពី១១ ដល់ ១៥ ឆ្នាំ លេប១០ក្រក្នុងមួយថ្ងៃ លេបក្នុងរយៈពេល៣ថ្ងៃ។

នៅក្នុងបសុព្យាបាល ដោយបុព្វហេតុមានជាតិសាច់ច្រើន គេច្រើនយកគ្រាប់នេះ ទៅអោយសត្វស៊ី ប៉ុន្ដែលទ្ធផលដែលពិសោធជាមួយសត្វនោះ មិនបានឯកភាពគ្នាទេ ។

៤ _ការប្រើប្រាស់ និង កម្រិតដែលត្រូវប្រើ :

ប្រជាជនច្រើនយកគ្រាប់កន្ធំថេតទៅព្យាបាលជម្ងឺព្រូន ដោយប្រើកម្រិតពី ១០ ទៅ ១៥ ក្រាម ក្នុងមួយថ្ងៃ ចំពោះកូនក្មេងកម្រិតនេះអាចកើនពី ២៥ ទៅ ៥០ ក្រាម ក្នុងមួយថ្ងៃ ។

ចំពោះមនុស្សធំ .. គេប្រើក្នុងរយៈពេល ៣ ថ្ងៃ នៅពេលដែលពោះទទេមិនទាន់ហូបអ្វីសោះ

## 11 - ដើមត្រចៀកក្រាញ់ព្រៃ

ឈ្មោះជាកម្ពុជា : ដើមត្រចៀកក្រាញ់ព្រៃ

ឈ្មោះជាបារាំង : Bévilocque

ឈ្មោះជាឡាតាំង : Centella asiatica Urb.

Famille : Ombellifères

១ _លក្ខណៈដើមថ្នាំ និង ភូមិសាស្ត្រដាំដុះ

ដើមត្រចៀកក្រាញ់ព្រៃ ជាប្រភេទស្មៅដុះទាបពុំនឹងដី ហើយវារ ។ ស្លឹកមូលហើយមានធ្មេញនៅគែមស្លឹក ។ ទងស្លឹកមានប្រវែងពី ២ ទៅ ៤ ស.ម ។ ផ្កាវាដុះជាកញ្ចុំចេញពីថ្នាំងដើម ។ ដើមត្រចៀកក្រាញ់ព្រៃស្រស់មានរសជាតិហាង ល្វីងបន្ដិចហើយឆ្អួល ។ លុះដល់ស្ងួតក្លិនឆ្អួលនេះបាត់ទៅ ក្លិននេះនៅសល់តែក្លិនស្មៅប៉ុណ្ណោះ ។



គេសង្កេតឃើញដើមត្រចៀកក្រាញ់ព្រៃ ច្រើនដុះនៅតាមដីសើមនៃតំបន់ក្ដៅ ។

២ _សមាសភាពគីមី :

នៅក្នុងដើមត្រចៀកក្រាញ់ព្រៃ មានសារជាតិសកម្មច្រើនដូចជា :

www.budinst.gov.kh www.elibraryofcambodia.org

-ជាតិគ្លុយកូស៊ីត (Glucosides) ដែលនៅក្នុងនោះ មានជាតិផ្សេងៗដូចជា :

. -ជាតិអាស៊ីយ៉ាទីកូស៊ីត (Asiaticoside)

. -ជាតិ សង់តែលឡូស៊ីត(Centelloside)

គេឃើញថាជាតិ អាស៊ីយ៉ាទីកូស៊ីត (Asiaticoside) អាចបំប្លែងទៅជាជាតិ អុកស៊ីតាទីកូស៊ីត (Oxyaticoside)ដែលមានឥទ្ធិពលយ៉ាងសកម្មចំពោះមេរោគ របេង(Action antituberculeuse) ។

៣-ប្រើកបនឹងជម្ងឺ :

គេប្រើរុក្ខជាតិទាំងមូលសំរាប់ :

-ផ្លូវរបួស - បំបាត់ការធ្លាក់យាមពីប្រមុះ

-បញ្ហារនោម - រោគលើស្បែក

-បន្សុទ្ធឈាម - បំប៉នកំលាំង

-ជាតិ អាស៊ីយ៉ាទីកូស៊ីត សកម្មចំពោះ មេរោគឃ្លង់ (Bacille de Hensen ) និងចំពោះ មេរោគរបេង (antituberculeux) ។

-ជាតិសង់តែលឡូស៊ីត ក៏សកម្មចំពោះរោគខាងលើនោះដែរ ។

៤-ករិតប្រើក្នុងការព្យាបាល

-ប្រើស្លឹក -មើម -ឫស : ១ ថ្ងៃ ពី ៣០-៤០ ក្រ ពូតច្របាច់ដឹកស្រស់ លាយស្ករអោយផ្អែមបន្តិច ។

-ការប្រើលើសកំរិតអាចបណ្តាលអោយ ឈឺក្បាល -វិលមុខ -ស្ញឹ ស្ញើ ។

12 - វល្លិកុមារពេជ្រ ឬ វល្លិកន្ទ្រាំធាតុភ្នំ

ឈ្មោះកម្ពុជា : វល្លិកុមារពេជ្រ ឬ វល្លិកន្ទ្រាំធាតុភ្នំ

ឈ្មោះជាវិទ្យាសាស្ត្រ : Stephania sp.

Famille : Menispermaceae

១-លក្ខណៈរុក្ខសាស្ត្រ និងទីកន្លែងដាំដុះ -កុមារពេជ្រ គឺជាវល្លិវារឡើងទ្រើង ប្រវែងរាប់សិបម៉ែត្រ ។ ស្លឹកវា ទោលមូល ហើយមានរោមតិចៗ ទំហំធំជាងស្លឹកកន្ទ្រាំធាតុ ធម្មតា ។ ផ្កាវាដុះជាកញ្ចុំពណ៌លឿងស្លេក ។ វល្លិកុមារពេជ្រមានមើម តែមិនសូវមូលដូចមើមកន្ទ្រាំធាតុទេ។ មើមនេះច្រើនតែពងចេញ ឬ ក្រពិតតាមកន្លែងខ្លះ ដោយសារដុះតៀប នឹងថ្មភ្នំ ។

មើមកុមារពេជ្រ ច្រើនតែធំជាងមើមកន្ទ្រាំធាតុ អាចមានទំងន់ពី ១ ទៅ ២០ គ.ក្រ ឬ លើសពីនេះទៅទៀត ។

វល្លិកុមារពេជ្រ ច្រើនដុះនៅលើភ្នំ ដែលសំបូរទៅដោយជាតិកំបោរ ឬ អំបិលកាល់ស្យូម ( Sel calcaire)។

២-សមាសភាពគីមី : សារធាតុសកម្មដែលមាននៅក្នុងមើមកុមារពេជ្រ គឺ :

-រ៉ូតុងឌីន (Rotundine ) ឬ ជាតិតេត្រាអ៊ីដ្រូប៉ាល់ម៉ាទីន (Tétrahydropalmatine )

-ហ៊ីនដារីន (Hyndarine ) ឬ ជាតិឌេ-អិល តេត្រាអ៊ីដ្រូប៉ាល់ម៉ាទីន ( D.L tétrahydro palmatine )



www.budinst.gov.kh www.elibraryofcambodia.org

-រ៉ូម័រស៊ីន ( Rœm ersine )

៣. -ការព្យាបាលផ្សេងៗ:

-ប៉ូវកម្លាំង ( Tonique )

-បំបាត់ឈឺក្បាល

-ទាល់ភ្លឹត

-ឈឺពោះ -ឆ្អកពោះ -គ្រុនក្តៅ

៤. -វិធីប្រើក្នុងការព្យាបាល :

មើម : ពី ៣ក្រ -៦ក្រ ក្នុង ១ថ្ងៃ : ស្ងោរ ឬ ផុងទឹកក្តៅ ឬ ត្រាំស្រាផឹក ។

ជាតិរ៉ូតុងឌីន ( Rotundine chlorhydrate )

-មនុស្សចាស់ : ០,០៥ - ០,១ ក្រ ក្នុង ១ ថ្ងៃ

-ក្មេងអាយុ ពី ១-៥ឆ្នាំ : ០,០២ - ០,០២៥ក្រ ក្នុង ១ ថ្ងៃ

គេអាចប្រើជាថ្នាំ : គ្រាប់ ឬ ថ្នាំចាក់ ។

កំណត់ចំណាំ : -គេសង្កេតឃើញជាតិ រ៉ូតុងឌីន ( Rotundine ) នៅក្នុងមើមកុមារពេជ្រសំបូរជាង នៅក្នុងមើមក្រនាំធារី ។

13 - ក្តាតហោរា

ឈ្មោះកម្ពុជា : ក្តាតហោរា

ឈ្មោះជាវិទ្យាសាស្ត្រ: Alocasia macrorrhiza

Famille : Araceae

១. លក្ខណៈរុក្ខសាស្ត្រ និង ភូមិសាស្ត្រដាំដុះ -ក្តាតហោរា គឺដើមដែលមានមើម ហើយមានកំពស់ពី ០,៣០ -១,៤០ម ឬអាចមានកំពស់រហូតដល់ ៥ ម ។ ដើមវាមានសភាពត្រង់ទៅលើ ។ មើមចុះខាងក្រោមដីរាងមូល វែងរីកចំរើនជាបន្តបន្ទាប់ វិតវៃតវៃងទៅ ហើយមានថ្នាំង ៗ នៅលើថ្នាំងនីមួយៗមានពណ៌ លោមជ្រូក ។



ស្លឹកមានរាងរបេះដូងប្រវែងពី ១០-៨០ ស.ម ព្រមទាំងមានទំហំពី ៨ ទៅ ៤៥ ស.ម ។ ធាងវាប្រវែងពី ១៥-១២០ស.ម

ផ្កា រាងមូល ផ្កាញីនៅគល់ ឯផ្កាឈ្មោលនៅខាងចុង ។ ចំណែកខាងក្រោមមានផ្លែរាងមូល ដូចស៊ុតពណ៌ក្រហម ។

ក្តាតហោរាជាដើមមួយដុះពាសពេញក្នុងព្រៃ នៅកន្លែងក្តៅហើយសើម ។គេសង្កេតឃើញដើមប្រភេទនេះ មានដុះនៅឡាវ កម្ពុជា នៅភាគខាងត្បូងនៃប្រទេសចិន ហើយនិងនៅប្រទេសអូស្ត្រាលី ។



www.budinst.gov.kh www.elibraryofcambodia.org

២. ការយកផល និង ថែរក្សាប្រមិត : -គេច្រើនជីកយកមើមពីដើមដែលមានអាយុពី ២ ដល់ ៣ ឆ្នាំឡើងទៅ ។ គេលាងមើមអោយជ្រះដី រួចកាត់ឫសតូចៗចោល និង កោសសំបកក្រៅចោល ។ បន្ទាប់មកគេហាលអោយស្ងួត ឬ ប្រើនៅស្រស់ក៏បាន ។ ពេលគេយកទៅចំរាញ់មើមនេះច្រើនធ្វើអោយរមាស់ដៃ ត្រូវយកចិត្តទុកដាក់ និង ប្រយត្ន័នៅពេលធ្វើ ។

៣. សមាសភាពគីមី : -គេមិនទាន់មានឯកសារស្រាវជ្រាវអំពី សភាពគីមីនៅក្នុងដើមក្តាតហោរានៅឡើយទេ គេគ្រាន់តែដឹងថានៅក្នុងមើមវា មានជាតិម្សៅ ដែលធ្វើអោយរមាស់ ។

៤. ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាលជំងឺ : -បើសិនណា គេហូបចូលច្រើនទៅក្នុងមាត់ក្នុងបំពង់ក មើមក្តាតហោរាមានជាតិហាងៗ និង រមាស់ រួចធ្វើអោយពុលតែម្តង ។ ប្រជាជនច្រើនប្រើមើមក្តាតហោរាក្នុងការព្យាបាល ដោយបំពាកទៅលើបូស កម រមាស់ និង ហើមដៃ ជើង ។ នៅប្រទេសវៀតណាម គេស្ងោរមើមក្តាតហោរារួចផឹកដើម្បីព្យាបាលជំងឺគ្រុនចាញ់ ។ មួយថ្ងៃគេផឹកពី ១០-២០ ក្រ។

រូបមន្តដែលមានប្រើមើមក្តាតហោរា ធ្វើជាការដើម្បីបិទបូស :

-គេប្រើ :

-មើមក្តាតហោរាស្រស់ចំនួន .................... ៨០-១០០ក្រ

-មើមរមៀតចំនួន .......................... ៦០ក្រ

របៀបធ្វើ: -គេយកមើមក្តាតហោរាលាងអោយជ្រះដី រួចកោសសំបកក្រៅចេញអោយស្អាត ។ បន្ទាប់មកទៀត បុកបញ្ចូលនឹងមើមរមៀត ។ ក្រោយមកលាយជាមួយប្រេងសណ្តែក ឬ ល្ង ។ គេដាំអោយពុះដាច់ទឹកនៅខាប់ ។ តែចាក់ប្រេង យ៉ាំថុង និង ក្រមួនចូលហើយកូរអោយសព្វ ។ ទុកអោយត្រជាក់ហើយផ្តិតចូលក្រដាស នៅទីបញ្ចប់គេបានការសំរាប់បិទបូស ។

បើបូសទើបតែកកើត ការនេះអាចរលាយបាត់ភ្លាម ។ បើសិនជាបូសនោះធំវិញ វាអាចបឹតខ្ទុះចេញបាន ។

## 14 - ដើម ត្បាល់កិន



-ឈ្មោះកម្ពុជា : ដើមត្បាល់កិន

-ឈ្មោះឡាតាំង : Abutilon indicum

-FAMILLE : Malvaceae

១. លក្ខណៈបូតានិក និង ទីកន្លែងដាំដុះ : -ត្បាល់កិនគឺជាប្រភេទដើមរុក្ខជាតិដុះទាប ៗ ស្លឹកទន់ ស្រួចចុង មានបណ្តោយស្មើ និង ទទឹងប្រវែង ១០ ស-ម ។ ផ្កាពណ៌លឿង មានតែមួយដុះចន្លោះដើម និងស្លឹក ហើយមានទងប្រវែងស្មើនឹងទងស្លឹក ។ ផ្លែរាងមូលប្រវែង ១៨ ស-ម ។ ផ្លែនេះមានគ្រាប់ ៣ ហើយគ្រាប់និមួយៗមានរាងដូចក្រលៀនជ្រូក ។

គេសង្កេតឃើញដើមត្បាល់កិន នៅដុះ ឬ ដាំពាសពេញក្នុងប្រទេសឥណ្ឌូចិនជាពិសេសនៅក្នុងប្រទេសកម្ពុជា ។



www.budinst.gov.kh www.elibraryofcambodia.org

២. សមាសភាពគីមី : -នៅក្នុងស្លឹកមានជាតិរ៉ែស៊ីល ហើយនៅក្នុងចំណែកផ្សេងៗទៀត គេពុំទាន់មានឯកសារស្រាវជ្រាវនៅឡើយ ។

៣. -វិធីប្រើក្នុងការព្យាបាលជម្ងឺ : សំបករបស់ដើម បានត្រូវប្រជាជនយកទៅស្ងោរផឹក ដើម្បីអោយនោមធូរ ។ គេក៏ប្រើស្លឹកដើមត្បាល់កិន ធ្វើជាថ្នាំលាងសំរាប់ព្យាបាលជម្ងឺសន្លាក់ដៃជើង ។ ឯឫសវិញ យកទៅស្ងោរផឹកដើម្បីព្យាបាលជម្ងឺដូចគ្នា ។

គ្រាប់ផ្លែ គេប្រើសំរាប់បន្ទន់ និង បញ្ចុះលាមក ។នៅប្រទេសឥណ្ឌា គេប្រើសំរាប់ធ្វើអោយនោមធូរ ។

នៅប្រទេសវៀតណាម ត្បាល់កិនជាដើមថ្នាំមួយដែលប្រើប្រាស់ក្នុងចំណោមប្រជាជនក្នុងវិស័យថ្នាំបុរាណ ។ គេច្រើនយកស្លឹកបុកអោយម៉ត់ ដើម្បីព្យាបាលបូស ឬ ដាំទឹកផឹកដើម្បីបញ្ចុះទឹកនោម បញ្ចុះកំដៅ ជម្ងឺនោមល្មៀង ។ មានពេលខ្លះ គេយកទាំងឫសទាំងស្លឹកដែលស្ងួតមកប្រើ ។ គេប្រើកំរិតពី ៤-៦ ក្រ ដើម្បីដាំទឹកផឹក ។ បើគេប្រើលើសពីនេះវិញមិនគិតកំរិតទេ ។

15 - ដើមស្លាក់

ឈ្មោះកម្ពុជា : ដើមស្លាក់

ឈ្មោះជាបារាំង : Pomme épineuse - Datura indien

ឈ្មោះជាទូ[illegible]ង : Datura metel Lin.

FAMILLE : Solanaceae

១. លក្ខណៈដើមឈើ និង ភូមិសាស្ត្រដាំដុះ : -ដើមស្លាក់គឺជារុក្ខជាតិដែលមានកំពស់ពី ១-១,៥ម ។ ស្លឹកធំរាងកណ្ដាល និង ស្រួចចុង ដុះមិនឆ្លាស់គ្នាទេ ហើយមានបណ្ដោយប្រវែងពី ៦ ទៅ ៣០ ស-ម ,ទទឹងពី ៥ ទៅ ២០ស-ម ។ ស្លឹកនេះប្រកបទៅដោយទងស្លឹកវែងគួរសម ។



ផ្កាដុះចន្លោះស្លឹក និង ដើមប្រកបទៅដោយទងខ្លី ។ ស្រទាប់ផ្កាពណ៌ស ជួនកាលមានលាយស្វាយ ហើយរាងដូចជីទៀ ។ស្រទាប់ផ្កានេះ ហ៊ុំពទ្ធ័ទៅដោយត្របកដែកជា ៥ ពីខាងក្រៅ ។ ផ្កាទាំងមូលប្រវែងពី ១៥ ទៅ ២៥ ស-ម ។

ផ្លែវា រាងមូលមានបន្លាស្រួចពទ្ធ័ជុំវិញ ហើយមានវិជ្ជមាត្រ ៤ ម.ម ។

គេសង្កេតឃើញ ដើមស្លាក់នៅដុះពាសពេញក្នុងប្រដាយផ្លូចិន ។និយាយដោយឡែកនៅប្រទេសកម្ពុជា ដើមរុក្ខជាតិនេះច្រើនដុះនៅវាលទំនាបពាសវាលពាសកាល់គ្រប់ទីកន្លែងក្នុងប្រទេស។

២. សមាសភាពគីមី : -តាមការស្រាវជ្រាវបានបង្ហាញអោយឃើញថា : នៅក្នុងផ្កាស្លាក់ប្រភេទក្រម៉ៅមាន ០,៣៩ ភាគរយ សុទ្ធតែស្កូប៉ូឡាមីន (Scopolamine)



www.budinst.gov.kh www.elibraryofcambodia.org

-នៅក្នុងផ្កាស្លាក់ប្រភេទស មាន 21% នៃអាល់កាឡូអ៊ីតទាំងអស់ Alcaloïdes totaux ក្នុងនេះមានជាតិស្កូប៉ូឡាមីន ( Scopolamine ) ច្រើនជាង និង លើសលប់បំផុតជាង អ៊ីយ៉ូស៊ីយ៉ាមីន (Hyosciamine ) ។ ប៉ុន្តែតាមការស្រាវជ្រាវដែលគេបានធ្វើនៅទីក្រុង កាឡាលុមពួរ បានហុចលទ្ធផលផ្ទុយទៅវិញ :

-គឺនៅក្នុងផ្កាប្រភេទក្រម៉ៅមាន Alcaloïdes 0,25 %

-និង នៅក្នុងផ្កាប្រភេទ ស មាន អាល់កាឡូអ៊ីត Alcaloïdes 0,40%

៣.-ប្រើតបនឹងជម្ងឺ : -ជាតិសំខាន់ដែលកំចាត់ជម្ងឺ គឺ ស្កូប៉ូឡាមីន ( Scopolamine ) :

-ពុលស្រាហើយធ្វើអោយវវើរវវាយ

-ការចុះអន់ថយនៃសរសៃប្រសាទ

-វវើរវវាយផ្តេសផ្តាស

-ជម្ងឺ ប៉ាកឃីនសុន ( Maladie de Parkinson )

ស្លឹក : -បូលខ្ទរ - ដំបៅដៃ - បួសដូងបាត - ឈាមខាំនៃស្ត្រី - ជម្ងឺសើស្បែក - ជម្ងឺមុខមានខ្ទុះ - ហើមត្រចៀក - ហើមធ្មេញ

៤.-របៀបប្រើក្នុងការព្យាបាល : -គេប្រើស្កូប៉ូឡាមីន ( Scopolamine ) នៅក្នុងស្លឹក និង ផ្កា ដែលគេហាលអោយស្ងួតរួចហាន់អោយល្អិតលាយជាមួយថ្នាំជក់ សំរាប់ព្យាបាលជម្ងឺហឺត ក្នុងកំរិតមិនអោយលើសពី ១ ម៉ីក្រ ក្នុងមួយថ្ងៃ ។

-បើគេប្រើជាថ្នាំលាយស្រាវិញ ក្នុងកំរិតពី ៥ ទៅ ២០ ស.ក្រ ក្នុងមួយថ្ងៃ ។

៥.-ឥទ្ធិពលរបស់ អាត្រូពីន : សារជាតិសកម្ម អាត្រូពីន ( Atropine ) មានឥទ្ធិពលធ្វើអោយ :

-ប្រស្រីភ្នែករីកធំ

-បន្ថយការចេញនៃរសក្រពះ (Suc gastrique ) ញើស -ទឹកមាត់ និង ·រសប្រម៉ាត់

-ទងសួតរីក - បន្ថយភាពកន្ត្រាក់នៃពោះវៀន និង ប្រឆាំងនឹងការកន្ត្រាក់ផ្សេងៗ ដែលធ្វើអោយមានការឈឺចាប់ ។ល។

## 16 - វល្លិម្រះ

ឈ្មោះកម្ពុជា : វល្លិម្រះ

ឈ្មោះជាបារាំង : Margose à piquants

ឈ្មោះជាឡាតាំង: Momordica charantia

FAMILLE / Cucurbitaceae

១. លក្ខណៈបូតានិក និង ភូមិសាស្ត្រដាំដុះ : -គឺជាវល្លិវារឡើងទៅលើពត់ដែនដោយពឹងផ្អែកទៅលើដើម ឬ ម្រែងមួយផ្សេងទៀត ។ ស្លឹកផ្នែកខាងលើគ្មានរោមទេ បណ្តោយប្រវែងពី ៥-១០ ស.ម ទទឹងប្រវែងពី ៤-៨ ម.ម មានរាងជាធ្មេញរណារ ហើយមានពី ៥-៦ គន្លាក់រាងមូលតែស្រួច ។

ផ្កាស្ថិតនៅដាច់ដែលឯង នៅចន្លោះដើម និង ស្លឹក ។ ផ្លែដូនកាលវែង ដូនកាលតូច មានរលកខ្ទុតពុតាមបណ្ដោយផ្លែ ។



www.budinst.gov.kh www.elibraryofcambodia.org

ផ្លែនេះមានប្រវែងពី ៨-១៥ ស.ម ។ គ្រាប់ផ្លែមានបណ្ដោយប្រវែងពី ១៣-១៥ ម.ម និង មាន ទទឹងពី ៧-៨ម.ម ហើយមានរាងដូចធ្មេញរណារ ។



ម្រះគេធ្វើជាបន្លែ សំរាប់បរិភោគ និង មានដុះនៅពាសពេញ ព្រៃជាយផ្លូចិន ។

២. សមាសភាពគីមី : ក្នុងផ្លែមាន :

-ជាតិគ្លុយកូស៊ីតល្វីង ( Glucoside amer) ដែលគេអោយឈ្មោះថា ម៉ូម័រឌីស៊ីន ( Momordicine ) :

-ជីវជាតិ បេ១ ( Vitamine $B_1$ )

-ជីវជាតិសេ ( Vitamine C )

-អាដេនីន ( Adénine) បេតាអ៊ីន (Bétaïne)

-ប្រូតេអ៊ីន ( Protéïne 0,6% )

នៅក្នុងគ្រាប់ផ្លែមាន :

-ជាតិប្រេង និង ជាតិល្វីងមួយដែលគេមិនទាន់ស្គាល់

-នៅក្នុងឆ្នាំ ១៩៥០ នៅប្រទេសឥណ្ឌា គេបានស្រាវជ្រាវអំពី ជាតិប្រេង និង កាករបស់វា ( Chimical examination of Karla Plants )

៣. ការប្រើប្រាស់ និង គតិតប្រើដើម្បីព្យាបាល : -នៅក្នុងប្រទេសយើងក្រៅពីធ្វើបន្លែ "ស្ងោរជាមួយសាច់" ម្រះ បានត្រូវគេប្រើធ្វើជាថ្នាំកំចាត់ជម្ងឺគ្រុនក្ដៅ និង ក្អក ។ តាមការស្រាវជ្រាវបានអោយដឹងថា ម្រះ ពិតមែនតែមានជាតិល្វីង តែឥតមានជាតិពុលទេ ។ ក្នុងមួយថ្ងៃ គេហូបប្រហែលផ្លែពីរដោយយកគ្រាប់ចេញដួចស្ងោរ ។ បើប្រើគ្រាប់ គេយក ៦ ក្រទីនគ្រាប់ស្ងួត ដាំទឹកផឹក ។ នៅប្រទេសជាច្រើន នៅលើពិភពលោក គេច្រើនយកម្រះធ្វើជាថ្នាំ ។

-នៅប្រទេសឥណ្ឌា គេយកទឹករបស់ស្លឹកទៅធ្វើអោយក្អួត បញ្ចុះលាមក និង ទម្លាក់ព្រូន ។ នៅប្រទេសខ្លះ គេយករុក្ខជាតិទាំងមូលទៅព្យាបាលជម្ងឺទឹកនោមផ្អែម ។

-នៅប្រទេស ម៉ាឡាយូ គេយកផ្លែម្រះខ្ចីសំរាប់លើកកម្លាំង និង ធ្វើអោយត្រជាក់ស្រួលខ្លួន ។ ចំណែកឯផ្លែទុំវិញ សំរាប់បញ្ចុះលាមកដែលទល់ខ្លាំង ។

រូបមន្តមួយចំនួនដែលគេប្រើម្រះសំរាប់ព្យាបាលក្នុងចំណោមប្រជាជន :

-ព្យាបាលជម្ងឺស្រែងថ្ងៃ : -គេយកផ្លែម្រះ ២ ឬ ៣ ផ្លែទៅស្ងោរទឹក ដើម្បីងូតអោយកូនក្មេងដែលកើតជម្ងឺនេះ ក្នុងមួយថ្ងៃម្ដង ។

-ព្យាបាលក្អក : -គេយកម្រះពី ១ ទៅ ២ ផ្លែដាំទឹកផឹក ក្នុងមួយថ្ងៃ ២ ឬ ៣ ដង ។



www.budinst.gov.kh www.elibraryofcambodia.org

## 17 - ដើមក្របៅ

-ឈ្មោះជាកម្ពុជា : ដើមក្របៅ

-ឈ្មោះជាឡាតាំង : Hydnocarpus anthelmintica

-Famille : Flacourtiaceae

១. លក្ខណៈបូតានិក និង ភូមិសាស្ត្រដាំដុះ -ក្របៅគឺជាដើមឈើដុះត្រង់ឡើងលើ ហើយមានមែកធំៗ ព្រមទាំងមានសំបក សំបូរទៅដោយសរសៃជាច្រើន ។ ប្រវែងស្លឹកចាប់ពី ១០-៣០ ស-ម និង មានទទឹងពី ៣-៧ ស-ម ។ ស្លឹកនេះប្រកបទៅដោយទងខ្លីប្រវែងប្រហែលពី ១២-១៥ ស-ម ព្រមទាំងមានទ្រនុងស្លឹកទទឹងចំនួនពី ៨-១០ គូ ។ ផ្កាវាជាកញ្ចុំៗ មានចំនួនពី ២-៥ កញ្ចុំដុះចន្លោះដើម ឬមែក និង ស្លឹក ។ ផ្កានេះមានពណ៌កូឡាប ។



ផ្លែរាងមូល ។ ផ្លែនេះផ្ទុកទៅដោយគ្រាប់ចំនួនពី ៣០-៥០ គ្រាប់ ។ គ្រាប់នីមួយៗ មានជ្រុងជាច្រើន មានបណ្ដោយប្រវែង ២ ស-ម ទទឹងប្រវែង ១ ស-ម ហើយសំបូរទៅដោយសាច់គ្រាប់ណាស់ ។

គេសង្កេតឃើញដើមក្របៅ មានដុះពាសពេញក្នុងប្រទេសកម្ពុជា លាវ និង វៀតណាម នៅតាមវាលទំនាប ឬមាត់ទន្លេ ។

២. សមាសភាពគីមី :-

-ក្របៅមានជាតិប្រេងចំហុះប្រហែល

-ក្នុងគ្រាប់ផ្លែមានជាតិប្រេងដែរ

-ក្នុងផ្លែស្រស់មាន :

-គ្លុយកូស៊ីត (Glucoside) តែវាគ្មាននៅក្នុងផ្លែស្ងួត ឬ ចាស់ទេ ។

៣. -ឥទ្ធិពលថ្នាំ : -នៅពេលគេលាបទៅលើស្បែក ជាតិប្រេងធ្វើអោយស្បែកឡើងក្រហម ។គេច្រើនប្រើដើម្បីបំបាត់ជម្ងឺរមាស់លើស្បែក និង ឃ្លង់ ។ ពីមុន គេព្យាបាលឃ្លង់ដោយអោយអ្នកជម្ងឺលេបគ្រាប់ផ្លែក្របៅ ឬមួយអោយផឹកប្រេងកៀបចេញ ពីផ្លែក្របៅ ។ប៉ុន្តែក្រោយមកគេស្រាវជ្រាវ និង ចំរាញ់ចេញពីគ្រាប់ផ្លែក្របៅនូវជាតិខ្លាញ់ ( Acides gras) ដែលមានគុណភាពល្អជាងពីមុន ។

ប្រេងក្របៅមានឥទ្ធិពលអាចសម្លាប់មេរោគរបេង , ឃ្លង់ និង ប្រភេទមេរោគលើស្បែកមួយចំនួនធំ ។

៤. -ការប្រើប្រាស់ និង ករិតដែលត្រូវប្រើក្នុងការព្យាបាលជម្ងឺ : -គេយកប្រេងក្របៅលាយជាមួយប្រេងវ៉ាសឺលីន ( Vaseline ) ធ្វើជាថ្នាំលាប ( Pommade à 20 % ) សំរាប់ព្យាបាលជម្ងឺឃ្លង់ និង



www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីសើស្បែកផ្សេងៗ ឬ រោគលញ្ឆាផ្សេងៗ ប្រហាក់ប្រហែល ឃ្លង់ ។ការឆ្លាប្រលទាមទារពេលវេលាវែង និង មានឥទ្ធិពលខ្លាំងចំពោះដើម្បីនាំទីដែលត្រូវកើត ។

បើប្រើជាថ្នាំដំណក់វិញ គឺត្រូវចាប់ផ្ដើមពី ១០ ដល់ ១០០ ដំណក់ ។ កំរិតនេះត្រូវបង្កើនឡើងរហូតដល់ ២០០-៣០០ តែមិនអោយហួសពីកំរិតនេះឡើយ ។ បើប្រើហួសពីកំរិតនេះ អាចបណ្ដាលអោយមានផលវិបាកដល់ដម្លើក្រពះ និង បំពង់រំលាយអាហារ ។

ប្រើកបនឹងដម្លើ : ភមរមាស់ស្វាយប្រមេះ ឃ្លង់ "គេអ៊ក់ប្រេង ៤០ ក្រ លាយជាមួយវីយ៉ូឡេ សង់ស្យាន ១២០ ក្រ ( Violet de gentiane 120 g ) ដាក់អាល់កុល "។ បន្ទាប់មកគេលុញជាគ្រាប់គុលិកា ( Pilule ) ។គេលេបមួយថ្ងៃ ៥០ គ្រាប់ ក្នុងពេលព្រឹកព្រលឹម។

-ដម្លើប្រមុះក្រហម : -គេយកគ្រាប់ផ្លែក្រពៅបុកអោយម៉ត់លាយជាមួយប៊ឺត ។ គេយកក្រណាត់ស្ដើងស្អាតជ្រលក់លាបកន្លែងឈឺ ។ គេលាបពី ២-៣ ដងក្នុងមួយថ្ងៃ ក្នុងរយៈពេល ៣ ថ្ងៃ រួចឈប់មួយថ្ងៃ ។ គេអនុវត្តតាមរបៀបនេះជាទៀងទាត់រហូតជា ។ បើសិនជាគេប្រើក្នុង ពេល ៣ ថ្ងៃជាប់ ហើយឃើញរោគពិបាកទ្រាំបាន តែអាចឈប់មួយ ឬ ២ ថ្ងៃរួចលាបទៀត ។ គេធ្វើដូចនេះរហូតជាសះស្បើយ ។។

## 18 - ដើមរាក់ស-ក្រហម

-ឈ្មោះជាភាសាខ្មែរ : ដើមរាក់ស-ក្រហម

-ឈ្មោះជាបារាំង : Madar , Mercure végétal

-ឈ្មោះជាឡាតាំង : Calotropis gigantea

-Famille : Asclepiadaceae

១. លក្ខណៈបូតានិក និង ភូមិសាស្ត្រដាំដុះ -រាក់ស-ក្រហម គឺជាដើមរុក្ខជាតិ ដែលមានកំពស់ពី ៧-១០ ម ហើយដើម



វាអាចមានទំហំរហូតដល់ប៉ុនភ្លៅមនុស្ស ។ ដើមវាដុះត្រង់ឡើងលើ ។ ស្លឹកវាទល់ទង ធម្មតាលាត ហើយមានទងខ្លី ។ ស្លឹកមានរាងជាពងក្រពើ ។ ស្លឹកនេះមានបណ្ដោយប្រវែងពី ១២-២០ ស-ម និង មានទទឹងប្រវែងពី ៥-១១ ស-ម ។ ផ្ការាក់ស-ក្រហមមានពណ៌ស-ប្រផេះ ធំ និង ល្អ ដុះជាកញ្ចុំបែកខ្នែងទាំងសងខាងទងផ្កា ។

គ្រាប់ផ្លែមានចំនួនច្រើន ហើយគ្រាប់និមួយៗប្រវែងប្រហែល ២៣ ស-ម ។ ដើមរាក់ស-ក្រហម មានដុះតាមលក្ខណៈធម្មជាតិ ឬ គេដាំសំរាប់យកស្លឹកធ្វើជាថ្នាំ ។លក្ខណៈដាំដុះនេះគេសង្កេតឃើញនៅក្នុងប្រទេសឥណ្ឌូចិន ។ ស្លឹកវាគេបេះទៀងទាល់តែ ទាល់ផ្ការ ។ក្រោយពីបេះរួច គេយកក្រណាត់ស្អាតជូតអោយអស់ធូលី រួចហាលថ្ងៃអោយស្ងួតដើម្បីទុកប្រើ ឬ ប្រើតែម្ដង ។

២. សមាសភាពគីមី : - ក្នុងស្លឹក :



www.budinst.gov.kh www.elibraryofcambodia.org

-មានជាតិ កាឡូត្រូពីន ( Calotropine ) ។ គេអាចយកទឹកទៅបំបែកជាតិនេះអោយក្លាយទៅជាតិ មួយផ្សេងទៀតឈ្មោះ កាឡូត្រូប៉ាសេនីន ( Calotropagenine ) ។ជាតិ កាឡូត្រូពីននេះ មានឥទ្ធិពលប្រៀបប្រដូចទៅនឹងពួក គ្លុយកូស៊ីត កាកឌីយ៉ូតូនិក( Glucosides cardio-tonique ) ដែរ ប៉ុន្តែខ្សោយជាងបន្តិច ។

៣. -របៀបប្រើ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល :

ស្លឹក : -ព្យាបាលជម្ងឺហឺត ។គេបេះស្លឹកស្រស់ យកមកដុតពីងក្រណាត់សើម ដើម្បីអោយអស់ជាតិស្លឹក ។ គេហាន់អោយល្អិត ។ រួចហាលអោយស្រពាប់ ។

ក្នុងមួយថ្ងៃគេយកស្លឹក ១០ សន្លឹក ដាំជាមួយទឹកមួយចានកន្លះ រួចហើយស្ងោរអោយនៅសល់ ១ ចាន ។ នៅទីបញ្ចប់ គេលាយជាមួយស្ករសំរាប់ផឹកព្យាបាលតែម្តង ។ គេផឹកពី ៣ ទៅ ៤ ដងក្នុងមួយថ្ងៃ មុន ឬ ក្រោយពេលបាយហើយបន្តិច ។ ទឹកនេះមានជាតិល្វីង និង ធុំក្លិនក្រពុល ។ បើគេផឹកច្រើនក្នុងមួយពេលអាចបណ្តាលអោយក្អួត ។

ឥទ្ធិពលបន្ទាប់បន្សំ : - គេសង្កេតឃើញមាន :

-ចុកដំដែង - រាគ

ក្រោយពីប្រើថ្នាំនេះ ពី ៣ ថ្ងៃទៅមួយសប្តាហ៍ ។ពេលខ្លះ ឥទ្ធិពលនេះមានក្នុងរយៈពេល ១០ នាទីក្រោយពីផឹកថ្នាំនេះរួច ។

19 - ដើមក្រូចថ្លុង

-ឈ្មោះជាកម្ពុជា : ដើមក្រូចថ្លុង

-ឈ្មោះជាបារាំង : Pamplemoussier

-ឈ្មោះជាឡាតាំង : Citrus grandis (

_FAMILLE : Rutaceae

១. លក្ខណៈរុក្ខសាស្ត្រ និង ភូមិសាស្ត្រដាំដុះ -ក្រូចថ្លុងគឺជាដើមឈើហូបផ្លែ មានកំពស់ពី ១០ ទៅ ១៣ ម. ។ សំបកដើមពណ៌លឿងស្លេក ហើយមានបន្លាដុះស្រួចរត្រង់នៅដើម និង មែក ។ ស្លឹកខាងរាងពងក្រពើ មានពីរកន្លាក់ ។ ស្លឹកនេះមានបណ្តោយប្រវែងពី ១១-១២ ស-ម និង មានទទឹងប្រវែងពី ៤ ៥-៥,៥ ស-ម។

-ផ្កាក្រូចថ្លុងពណ៌សហើយដំព្រួចទាំងមានក្លិនក្រអូបផង ។ ផ្កានេះដុះជាកញ្ចុំមានពី ៦ ទៅ ១០ផ្កា។

-ផ្លែក្រូចថ្លុងរាងមូល មានទំហំប៉ុនក្បាលមនុស្ស ឬ អាចលើសពីនេះទៅទៀត ។ ផ្លែនេះមានសំបកក្រាស់ណាស់ ហើយមានពណ៌ប្រែប្រួលទៅតាមកន្លែងដាំដុះខុសៗគ្នា ។

គេសង្កេតឃើញ ដើមក្រូចថ្លុងមានដុះ និង ត្រូវគេដាំពាសពេញក្នុងប្រទេសចិន ។

២. សមាសភាពគីមី : -នៅក្នុងស្លឹក -ក្នុងផ្កា -សំបកផ្លែមាន ជាតិប្រេង

-នៅក្នុងសំបកផ្លែក្រូច ក្រៅពីជាតិប្រេងនៅមាន :

• -ជាតិ ប៉េចទីន ( Pectine )

• -ជាតិ គ្លុយកូស៊ីត ( Glucoside ) ឈ្មោះណារ៉ាំងស៊ីន ( Naringine )



www.budinst.gov.kh www.elibraryofcambodia.org

៣. ការប្រើប្រាស់ និង កម្រិតដែលត្រូវប្រើក្នុងការព្យាបាល : -គេយកស្លឹកក្រូចស្រស់ធ្វើជាមួយស្លឹកថ្នាំឯទៀត ដែលមានជាតិក្រអូបសំរាប់ស្ងោរក្នុងការព្យាបាល ដើម្បីបំបាត់ឈឺក្បាល ។ គេចំរាញ់យកជាតិប្រេង ពីសំបក



ផ្លែក្រូចថ្លុងសំរាប់ព្យាបាល ដើម្បីមិនរំលាយអាហារ - ឈឺពោះ-ក្អក ។ គេប្រើសំរាប់ធ្វើទឹកផឹក ក្នុងមួយថ្ងៃ ពី ៤-១២ ក្រ ។គេអាចចំរាញ់យកចេញពីផ្លែក្រូច នូវជាតិ ប៉េចទីន សំរាប់ធ្វើជាថ្នាំឃាត់រាគ ។ ម៉្យាងទៀតគេអាចចំរាញ់ នូវជាតិ អាស៊ីត ស៊ីទ្រិកធម្មតាពីរំក្លូបផ្លែក្រូច និង ធ្វើជាថ្នាំព្យាបាល ដើម្បី ទោះមកពីកង្វះជីវជាតិ សេ ( Vitamino C ) ។

ព្យាបាលបូសខ្ទុះ : - គេយកគ្រាប់ក្រូចថ្លុង បកសំបកវាចេញ ។ គេដាំតម្រាំជាផង្លាសនៅក្នុងខ្ទះស្ពាន់ ដុតកំដៅរហូតទៅជាធ្យូង ហើយបុកអោយល្អិត ។ បន្ទាប់មកគេលាងអោយស្អាត និង ទឹបញ្ចប់គេជូតអោយស្ងួត ។ គេយកម្សៅនេះ លាបទៅលើបូស មួយថ្ងៃ ពី ២ ទៅ ៣ដង ។ ។

20 - ក្រូចឆ្មារ

-ឈ្មោះជាកម្ពុជា : ក្រូចឆ្មារ

-ឈ្មោះជាបារាំង : Citronnier

-ឈ្មោះជាឡាតាំង : Citrus medica

-FAMILLE : Rutaceae

១, លក្ខណះដើមឈើ និង ភូមិសាស្ត្រធំាដុះ -ក្រូចឆ្មារគឺជាដើមរុក្ខជាតិម៉្យាងមានបន្លា ឬ ជួនកាលគ្មានបន្លា ។



បន្លានេះបើសិនជាមានដុះទទឹងត្រង់ទៅនឹងដើម ហើយចុងវាមានពណ៌ក្រហម ។ បន្លាទាំងមូលប្រវែងប្រហែល ៣៥ ម.ម ។ ស្លឹករាងពងក្រពើទ្រវែង បណ្ដោយប្រវែងពី ៥,៥-១១ ស-ម, ទទឹងប្រវែងពី ៣,៥-៦ ស-ម ។ ជុំវិញស្លឹកមានរាងជាធ្មេញរណារ ( Dentée en scie ) ។

ផ្កាក្រូចឆ្មារពណ៌ស ជួនកាលពណ៌ក្រហមឆោមជ្រូក ឬស្វាយ ហើយមានទំហំធំគួរសម ។ ផ្កានេះជួនកាលដុះតែឯង ឬ ជាកញ្ចុំដែលមានពី ២-៣កញ្ចុំតូចៗ ។ ផ្លែក្រូចឆ្មារតូចមធ្យម ពណ៌ខៀវនៅពេលខ្ចី ហើយក្លាយទៅជាពណ៌លឿងនៅពេលទុំ ។ ផ្លែនេះមានសំបកស្តើង និង រលោងព្រមទាំងមានពី ១០-១២ក្លែបៗ ក្លែបនិមួយៗផ្ទុកទៅដោយគ្រាប់រាងធំគួរសម ចំនួនពី ២-៣ គ្រាប់



www.budinst.gov.kh www.elibraryofcambodia.org

ដែលរំលែងបន្តិច ។ គេសង្កេតឃើញដើមក្រូចឆ្មារ មានប្រភពដើមចេញពីប្រទេសកម្ពុជា ដែលប្រជាជនយើងច្រើនដាំជាលក្ខណៈចំការដើម្បីទួលមិនលិចទឹក ។ រួចការដាំបានរីកសាយភាយរហូតទៅដល់ប្រទេសវៀតណាម និង ឡាវទៀត ។

២. សមាសភាពគីមី :- សំបក :-

-ជាតិប្រេង "៣០០០-៦០០០ ផ្លែ អាចផ្តល់បានជាតិប្រេង ១ លីត្រ " ។

-បើគេគៀបសំបកស្រស់របស់ផ្លែមួយ ហើយទៀវ អាចផ្តល់អោយជាតិប្រេងប្រហែល ១,៥ ម.ល ។

-ចំណែកសំបកស ខាងក្នុងមានជាតិ ប៉េចទីន ( Pectine ) ។

ជាតិប្រេងរបស់ក្រូចឆ្មារ ហើយរឿងទុំនាំ ធ្វើអោយក្រូចឆ្មារ ។ផលិតផលរបស់វាដែលថ្ងៃធ្វើអោយជាតិប្រេងរបស់ក្រូចឆ្មារងាយនឹងទៅជាជាតិល្វីង ។

ស្លឹកក្រូចឆ្មារ :-មានជាតិប្រេងធ្វើក្រអូបមានចំណុះផ្លាស់ប្តូរពី ០,៣៣-០,៥ ភាគរយ ។

-ផ្លែក្រូចឆ្មារ :-ក្នុង ៥០ ផ្លែនៃផ្លែក្រូចឆ្មារមធ្យម គេអាចទាញយកផលទឹកជាតិទាំង ១ លីត្រ ក្នុងនេះមាន :

. -ជាតិទឹក.................................... ៨០-៨២ %
. -ជាតិអាស៊ីតស៊ីទ្រិក ( Acide citrique )............. ៥-៧ %
. -ជាតិស៊ីត្រាតរបស់កាល់ស្យូម និង ប៉ូតាស្យូម................ ១-២ %

. -ស៊ីត្រាតអេទីល ( Citrate d'éthyle ) .......... តិចតួច
. -អាស៊ីតម៉ាលិក ( Acide malique ) ..........ប្រហែល ០,៤-០,៥ %
ក្រៅពីនេះនៅមាន :
. -ជាតិស្ករ អាំងវែរទី ( Interverti ) ......... ០,៤-០,៧៥%
. -សាក់ការ៉ូ ( Saccharose ) ............... ០,៥ %
. -ប្រូទីត ( Protide ) ...................... ០,៧៥-១%
. -វីតាមីនសេ ( Vitamine C ) .................. ៦៥ម.ក្រ / ១០០ក្រ
. -វីតាមីនបេ១ ( Vitamine $B_1$ )
. -វីតាមីនបេ២ ( Vitamine $B_2$ )

៣. -វិធីប្រើ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល :

ក -ទឹកក្រូចឆ្មារ :-"ផឹក" -កំរិតប្រើ ៣០-១២០ក្រក្នុងមួយថ្ងៃលាយជាមួយស្ករ ឬ ជាតិផ្អែមផ្សេងទៀត

-បញ្ចុះកំដៅ -បន្ទន់លាមក -ជម្ងឺស្លឹកស្រពន់ -ទោគខ្វះកោសិកាឈាមក្រហមរបស់ទារកកំពុងបៅដោះម្តាយ

-ប្រូគីវទីស ឈឺសន្លាក់ជើងធ្ងន់ធ្ងរ ( Rhumatisme articulaire aigu )
ឈឺបំពង់ក ( Angine )

-ពិសេសព្យាបាលជម្ងឺស្គក ប៊ុត ( Scorbut ) ដែលបណ្តាលមកពីខ្វះវីតាមីនសេ (Vita.C)

-ជាតិអំបិលក្រូចឆ្មារ ដាក់ជាមួយអំបិលសំរាប់ស្លរក្លូប ( NaCl ) សំរាប់យកមកព្យាបាលអ្នករលាកបំពង់ក ។



www.budinst.gov.kh www.elibraryofcambodia.org

ខ-ឫស : - "ដាំទឹកផឹក"

-ព្យាបាលក្អកដោយរួមផ្សំជាមួយឫសមន ។ កម្រិតប្រើ: ៦-១២ក្រ ក្នុងមួយថ្ងៃ

គ-សំបកដើម : - "ដាំទឹកផឹក"

-ថ្នាំកម្លាំង - ជំនួយក្នុងការរំលាយអាហារ ។ កម្រិតប្រើ: ៤-១០ ក្រ ក្នុងមួយថ្ងៃ

ឃ-សំបកផ្លែ : - "ផាតិប្រេង"

មានលក្ខណៈសំរាប់សម្លាប់មេរោគខ្លាំងបំផុត ។

-មេរោគរលាកស្រោមខួរក្បាល ( Méningocoque )

-មេរោគក្រុមពោះវៀន

-មេរោគខាន់ស្លាក់

ង-ស្លឹកក្រូចឆ្មារ : - "ត្រាំងផឹក"

បំបាត់ការពត់ប្រកាច់នៃសាច់ដុំ ឬ បណ្តាលអោយចុកចាប់ ( Antispasmodique )

ច-គ្រាប់ផ្លែ : -ប្រជាជនខ្លះ គាត់យកទៅធ្វើជាថ្នាំទំលាក់ព្រូន ( Anthelminthiques )

បណ្ណាល័យ
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
LIBRARY
BUDDHIST INSTITUTE

21 - ផ្កាឈូក

-ឈ្មោះជាកម្ពុជា : ផ្កាឈូក

-ឈ្មោះជាបារាំង : Lotus, Fève d'Egypte, Lis rose des Egyptiens

-ឈ្មោះជាឡាតាំង : Nelumbo nucifera

-FAMILLE : Nelumbonaceae )

១. លក្ខណៈរុក្ខសាស្ត្រ និង ភូមិសាស្ត្រដាំដុះ ឈូកជារុក្ខជាតិមួយ ដែលដុះតែនៅក្នុងទឹក ។ ដើមដុះចេញពីដីក្នុងទឹក ប្រវែង ១ ម ឬ អាចមានលើសពីនេះទៅទៀត ហើយលក្ខណៈស្ពោតពុ ។ ស្លឹកដុះឡើងពីក្នុងទឹកហើយឡើងបន្តពូតទៅដល់ទឹកលើផ្ទៃទឹក ។ ស្លឹកនេះមានទងវែងសំបូរទៅដោយបន្លាច្រើន ដក់កណ្តាលបន្តិចព្រមទាំងមានទំហំមាត្រ ៤០ ស-ម និងប្រទាំងជាច្រើន ។ ផ្កាវាដុះចេញផុតពីទឹក ។ ផ្កានេះមានស្រទាប់ចំនួនប្រហែលជាង ២០ ពណ៌ស-ផ្កាឈូកពណ៌ផ្កាឈូក ឬ ក្រហមបន្តិចពទ្ធពីផ្ទៃញ ។ ម្យ៉ាងទៀតផ្កាសំបូរទៅដោយលំអងណាស់ ជាហេតុធ្វើអោយមានក្លិនក្រអូបឈ្ងុយឈ្ងប់ ។



-NELUMBO-NUCIFERA

-NELUMBONACEAE

-ផ្លែមានរាងដូចដីទៀរ ហើយផ្ទុកទៅដោយប្រហោងដាក់គ្រាប់នៅក្នុងនោះ ។ បើគ្រាប់ផ្លែកាន់តែធំ ប្រហោងកាន់តែធំ ។

-គេសង្កេតឃើញ ដើមឈូកមានដុះនៅក្នុងត្រពាំង ឬ បឹង ឬ គេដាំសំរាប់យកផលម្តង ៗ នៅតំបន់អាស៊ី ប្រទេសកម្ពុជា ឃើញសំបូរជាងគេ ។



www.budinst.gov.kh www.elibraryofcambodia.org

២. សមាសភាពគីមី :- នៅក្នុងគ្រាប់មាន :

-ជាតិម្សៅ ( Amidon ) និង ស្ករ.................. ៦២ %

-ជាតិប្រូតេអ៊ីន ( Protéines ) ..................... ១៨ %

-ជាតិខ្លាញ់ ( Matières grasses)................. ២ %

-ទឹក ............................... ១២ %

នៅក្នុងឆ្នាំ ១៩៧០ លោក ដេ-គុយនីតូម៉ូ D. Cunitomo ) បានចំរាញ់ចេញពីស្លឹកឈូកនូវជាតិ :

-អាណូនីន ( ANONINE )

-ប្រូនុចស៊ីហ្វេរីន ( PRONUXIFERINE )

-អិន-នរនុចស៊ីហ្វេរីន ( N-NORNUXIFERINE )

-លីរីយ៉ូដឺនីន ( LIRIODENINE )

-ដេ អិន មេទីលកូក្លូរីន ( D.N. METYLCOCLAURINE )

-នុចស៊ីហ្វេរីន ( NUXIFERINE )

-អូ នរនុចស៊ីហ្វេរីន ( O. NORNUXIFERINE )

៣.-ឥទ្ធិពលថ្នាំ :

ក-ណេលុំប៊ីន ( NELUMBINE ) មានជាតិពុលចំពោះបេះដូង

ខ-ធ្វើកំលាំងកាមស្រកស្រុតចុះ អាចព្យាបាលជម្ងឺហូរទឹកកាម ( SPERMATORRHEE )

គ-ចំពោះពោះវៀន :-មានឥទ្ធិពលប្រឆាំង និង ការចាប់ដោយសារកន្ត្រាក់ ( ANTISPASMO-DIQUE ) ខ ការពិសោធន៍ទៅលើសត្វឆ្កែ បានធ្វើអោយសត្វនេះ មានកំរិតឈាមលើស និង ធ្វើអោយនោមតិច ( OLIGURIE ) ។

៤. ការប្រើប្រាស់ និង កំរិតប្រើ :-

ពន្លកបេះដូង :

-បង្ហាក់បេះដូងដើរលឿនខុសពីធម្មតា ( TACHYCARDIE )

-ញ័របេះដូង ( PALPITATION )

-ដេកមិនបាន ( INSOMNIE NERVEUSE )

-ខ្ទើរខ្ទាយ ក្នុងមួយថ្ងៃផឹកពី ៤-១០ ក្រ ។ ចំណែកជាតិបណ្ដូលនៃគ្រាប់ដាំទឹកផឹកមានឥទ្ធិពលបញ្ចុះកំដៅ ។

ក្រអៅឈូក :-នៅក្នុងក្រអៅឈូកមាន :

-អាស្ប៉ារ៉ាស៊ីន ( ASPARAGINE )

-អាកស៊ីនីន ............ ២ %

-ទ្រីហ្គោណេលីន ( TRIGONELINE )

-ទីរ៉ូស៊ីន ( TYROSINE )

-អាស៊ីតផូស្វរិក ( ACIDE - PHOSPHORIQUE )

-ជាតិស្ករ ( GLUCOSE )

-វីតាមីន សេ ( VITAMINE C )



www.budinst.gov.kh www.elibraryofcambodia.org

-ក្រអៅឈូកសំរាប់ព្យាបាលជម្ងឺ :

.ឃាត់ឈាម -ជម្ងឺឫសដូងបាត -នោមឈាម -ក្អួតឈាម -ឈាមប្រមុះ -ហូរឈាមក្នុងស្បូន ។

កំរិតប្រើ : -មួយថ្ងៃ ពី ៦-១២ ក្រ.ដាំទឹកផឹក ។

22 - ដើមល្ហុង

-ឈ្មោះជាភាសាខ្មែរ : ដើមល្ហុង

-ឈ្មោះជាបារាំង : Papayer

-ឈ្មោះជាឡាតាំង : Carica papaya Lin.

- FAMILLE : Papayaceae

១. លក្ខណៈបុគ្គលិក និង ភូមិសាស្ត្រផ្សេងៗ : ល្ហុងគឺជាដើមឈើដែលមានកំពស់ពី ៧ ទៅ ១០ ម ។ ដើមវាត្រង់ទាំងមូលហើយជួនកាលមានបែកមែកទៅខាងចុង ។ គេអាចសំគាល់ដើមវាបានដោយសារមានស្លាកស្នាមស្លឹកចាស់ដែលជ្រុះចោលតាំងពីគល់រហូតដល់ចុង ។ ស្លឹកល្ហុងធំៗហើយចែកញែកប្រកបទៅដោយទងរាងវែងប្រវែងពី ៣០-៥០ ស-ម ស្លឹកទុះជ្រុះធ្លាស់គ្នា ។ ឯទងស្លឹកមានភាពទៅគល់ទីកជាំ ហើយនៅចុង ។



ផ្កាល្ហុងពណ៌ស លាយលឿង ឬ ជួនកាលពណ៌ខៀវស្រគាប់ ។ ផ្កាឈ្មោលដុះចន្លោះដើម និង ស្លឹកប្រកបទៅដោយទងវែង ។ ផ្កាញីផ្ទុយទៅវិញ មានទងខ្លីហើយដុះនៅចន្លោះស្លឹក និង ដើមដូចគ្នា ។

ផ្លែល្ហុងមានរាងមិនដូចគ្នាទាំងអស់ទេ ខ្លះរាងមូល ខ្លះទៀតមានរាងមូលទ្រវែងដែលមានប្រវែងពី ២០-៣០ ស-ម ហើយមានជ្រុំជ្រុង ។ ជ្រុងនេះមិនទៀងទេ ខ្លះមានខ្លះទៀតអត់ ។ ផ្លែមានគ្រាប់ជាច្រើននៅខាងក្នុង ។ នៅពេលខ្ចីផ្លែមានពណ៌ខៀវៗ លុះដល់ពេលទុំ ផ្លែនេះប្រែពណ៌ទៅជាលឿងទុំ ។ ដើមល្ហុងត្រូវបានគេដាំពាសពេញក្នុងប្រទេសក្តៅ ជាពិសេស កម្ពុជា វៀតណាម ឡាវ ។

២. សមាសភាពគីមី : តាមការវិភាគនៃផ្លែល្ហុងដែលធ្វើឡើងដោយលោក សូ ឡាណូ សាលសេដូ (SOLANO SALCEDO ) នៅក្នុងប្រទេស កូឡុំប៊ី ( COLOMBIE ) នាឆ្នាំ១៩៤៦

គេឃើញមាន :

-ជាតិ អាស៊ីតទាំងអស់ ៧

-ជាតិ អាស៊ីតសេរី ១,៣

-ជាតិអាស៊ីតមិនសេរី...៦,១

-ជាតិទឹក..........៦៤ %

-ជាតិកាកសំណល់នៃកោសិកា.......... ០,៩-១,១%



www.budinst.gov.kh www.elibraryofcambodia.org

- ជាតិស្កររំលាយ ........................... ៤,៣-៧,៤%
- សារធាតុ អាស៊ូត ( N x 6,25 ) .......... ០,៦៤-០,៨៦%
- ប្រូតេអ៊ីនបន្សុទ្ធ ........................... ០,៣៥-០,៦៤%
- អាស៊ូតគ្មានជាតិប្រូតេអ៊ីន ........................ ០,០៣៥ %
- ប្រូតេអ៊ីនដែលអាចបរិភោគបាន .................០,៣៨-០,៤៧ %
- ផូស្វ័រ (PHOSPORE) ........................ ០,២២៣ %
- កាល់ស្យូម ( CALCIUM) ........................ ០,២៤៥ %
- ម៉ាញេស្យូម , ដែក - វីតាមីនប១ ( $B_1$ ) វីតាមីនប២ ( $VITAMINEB_2$ )
នីកូទីនិច - វីតាមីនសេ ( VITAMINE C ) ។

- នៅក្នុងជ័ររបស់ដើមមាន : - កៅស៊ូ.......... ១១ - ប៉ាប៉ាអ៊ីន ( PAPAINE ) ៣,៩៦ %
- នៅក្នុងជ័ររបស់ផ្លែ ក្រៅពីជាតិប៉ាប៉ាអ៊ីន ( PAPAINE ) មាន :

- កៅស៊ូ - ជាតិជ័ររេស៊ីន ( RESINE ) - ជាតិឡឺស៊ីន ( LEUCINE )-ទីរ៉ូស៊ីន ( TYROSINE ) - ជាតិខ្លាញ់ - អាស៊ីតម៉ាលិក( ACIDE MALIQUE ) និង មានជាតិហ្វែរម៉ង់ ( FERMENT ) សំរាប់រំលាយ ជាតិខ្លាញ់ ។

## ៣. ការប្រើប្រាស់ក្នុងការព្យាបាលជម្ងឺ :

សារធាតុសកម្មដែលអាចព្យាបាលជម្ងឺគឺ ប៉ាប៉ាអ៊ីន ( PAPAINE ) ។គេប្រើវាដូចជាតិប៉ិបស៊ីន ( PEPSINEនិង ទ្រីបស៊ីន TRYPSINE ដែលជាជំនួយក្នុងការរំលាយអាហារណាមានជាតិអាល់ប៊ុយមីន ( SUBSTANCES ALBUMINOIDES ) ។ វាអាចសម្លាប់មេរោគជាច្រើន ជាពិសេសមេរោគឈ្មោះ ស្តាភីឡូកុក ( STAPHYLOCOQUES ) និង មេរោគគ្រុនពោះវៀន ( BACILLE D'EBERTH ) ។

- នៅប្រទេសវៀតណាម គេអាចប្រើជាតិប៉ាប៉ាអ៊ីន ក្នុងការព្យាបាល ជម្ងឺប្រមេះទឹកបាយ។
- គេអាចប្រើជាតិជ័រ ( LATEX ) កបនិងជម្ងឺដូចខាងក្រោមនេះ :
  - ធ្វើអោយខាកចូរ ក្នុងកំរិត ១៥ ក្រ រាល់ពីរម៉ោងម្តង "ប្រើជាលក្ខណៈស៊ីរ៉ូ"
  - ទំលាក់ព្រូន ជាពិសេសព្រូនមូល , ទ្រីស៊ីន ( TRICHINE )និង តេវ៉ៀន OXYURE
  - ថ្នាំបញ្ចុះលាមក ក្នុងកំរិត ២ ក្រលាយក្នុង ៤ក្រទឹក ។
- គេអាចប្រើជាតិជ័រ ( LATEX ) សំរាប់ព្យាបាលជម្ងឺ :
  - ពាអក - និង ភ្លី ,ដោយប្រើរូបមន្តដូចខាងក្រោមនេះ :
  - ជាតិជ័រល្ហុង ( LATEX DE PAPAYE ) ............... ១ ក្រ
  - ជាតិម្សៅ បូរ៉ាក់ ( BORAX EN POUDRE ) ........៦០ ក្រ
  - ទឹក ..................................១៦ ក្រ

លាបមួយថ្ងៃពី ២ ទៅ ៣ ដងទៅលើមុខជម្ងឺ ។

- នៅក្នុងប្រទេសកម្ពុជាយើង គេប្រើឫសល្ហុងសំរាប់ដាំទឹកផឹក ក្នុងការព្យាបាលជម្ងឺហូរឈាម "ពាត់ឈាម"និង ក្នុងការព្យាបាលជម្ងឺហូរឈាមខ្លាំងនៅពេលមានរដូវ ។ បើគេប្រើលាយជាមួយម្នាស់នឹងធ្វើអោយនោមចូរក្នុងការព្យាបាល ការស្ទះផ្លូវនោម ។
- នៅក្នុងប្រទេស វៀតណាម គេអាចប្រើឫសល្ហុងក្នុងការព្យាបាលជម្ងឺប្រកាច់ ។



www.budinst.gov.kh www.elibraryofcambodia.org

# 23 - កញ្ជ្រាលទុយ

-ឈ្មោះជាកម្ពុជា : កញ្ជ្រាលទុយ

-ឈ្មោះជាបារាំង : Réglisse Viet-Namienne

-ឈ្មោះជាឡាតាំង : Scoparia dulcis

-FAMILLE : Scrofulariaceae

១. លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : -គឺជាប្រភេទស្មៅម៉្យាងដែលមានដើមរឹងដុះត្រង់ បែកមែកព្រមទាំងមានកំពស់ពី ៣ ទៅ ១០ ត.ម ។ ស្លឹកទល់ទង ឬ ដូចកាលដុះជុំវិញដើម ឬ មែក បង្កើតបានជាស្លឹក ៣ ទល់ទងគ្នា ។ ស្លឹកនេះមានគែមពន្ធ័ជុំវិញរាងជាធ្មេញរណារ ស្រួចៗ តែមិនសូវច្រើនទេ មានបណ្ដោយប្រវែងប្រហែល ២៥ម.ម និង មានទទឹងប្រវែងប្រហែល ៥ម.ម ។ផ្កាវាពណ៌ស តែមានចំនួនច្រើន ។ គេសង្កេតឃើញ ដើមកញ្ជ្រាលទុយមានដុះ និង ដាំពាសពេញក្នុងប្រទេសឥណ្ឌូចិន នៅប្រទេសឥណ្ឌា និង ម៉ាឡាយូ ។



២. សមាសភាពគីមី - ក្នុងដើមកញ្ជ្រាលទុយមាន :

អាស៊ីត ស៊ីលីស៊ីក ( ACIDE SILICIQUE )

អាល់កាឡូអ៊ីតមួយ ( UN ALCALOIDE ) ឈ្មោះ អាម៉ែល លីន ( AMELLINE ) ។

៣. ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល ជម្ងឺ :

-នៅប្រទេសវៀត ណាម គេប្រើដើមកញ្ជ្រាលទុយសំរាប់ព្យាបាល :

.គ្រុនក្ដៅ - ពុលថ្នាំឡេង "វាអាចជំនះជាតិពុលពីក្នុងខ្លួនបាន"

-កំរិតប្រើ : -៣០-១០០ ក្រដាំទឹកផឹក ឬ លាយជាមួយជាតិថ្នាំដទៃទៀត ។

-ឫស : "ស្ងោរផឹក" ព្យាបាល ជម្ងឺ

-ប្រមេះទឹកឫយ - និង បង្អន់ការហូរឈាមពិតរដូវច្រើន

-នៅប្រទេស ប្រេស៊ីល គេប្រើ :

-ទឹកដមរបស់ស្លឹក "ផឹកលាងបញ្ចុះ" សំរាប់ព្យាបាលជម្ងឺរាគមួល ។

-ឆុងផឹកលាយស្ករ សំរាប់ព្យាបាល ក្អក ។

-នៅប្រទេសម៉ា ឡាយូ គេប្រើសំរាប់អោយខាកធូរ បំបាត់ក្អក ។

-នៅប្រទេសឥណ្ឌា សារជាតិសកម្ម អាម៉ែល លីន ( AMELLINE ) ប្រើតាមមាត់សំរាប់ព្យាបាល ជម្ងឺទឹកនោមផ្អែម ។ ប៉ុន្តែតាមអ្នកស្រាវជ្រាវខ្លះបាន អោយដឹងថាគ្មានឥទ្ធិពលព្យាបាលជម្ងឺនេះទេ ។ ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវអំពីដើមនេះ ។ "ចប់"



www.budinst.gov.kh www.elibraryofcambodia.org

24 - ដើមកន្ទ្រាំងព្រាយ

- ឈ្មោះកម្ពុជា : ដើមកន្ទ្រាំងព្រាយ
- ឈ្មោះវិទ្យាសាស្ត្រ: Sida acuta
- FAMILLE : Malvaceae

១. លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : - ដើមកន្ទ្រាំងព្រាយមានកំពស់ពី ០,៨០ ទៅ ១ ម ។ ស្លឹកវាមាន ពណ៌បៃតងខ្ចី មូលទៅខាងគល់ ប៉ុន្តែស្រួចចុង ប្រកបទៅដោយជុំវិញស្លឹកមានរាងជាធ្មេញរណារស្រួចៗ ។ ស្លឹកនេះមានបណ្ដោយប្រវែងពី ២៥ - ៦០ ម.ម និង មានទទឹងប្រវែងពី ៥ -២០ ម.ម ។



ផ្កាពណ៌លឿងស្លេក ដុះចន្លោះដើម និង ស្លឹក ហើយមានដុះតែមួយម្ដងប្រកបទៅដោយទងវែង ។

ដើមកន្ទ្រាំងព្រាយ លមានដុះក្នុងលក្ខណៈជាធម្មជាតិ នៅក្នុងប្រទេសកម្ពុជា ,វៀតណាម ភាគខាងត្បូង ,ឥណ្ឌា និង ចិន ។

២. សមាសភាពគីមី : -មិនទាន់មានឯកសារស្រាវជ្រាវស្ដីពីសមាសភាពគីមីនៅក្នុងដើមកន្ទ្រាំងព្រាយ លនៅឡើយ ។ យើងខ្ញុំគ្រាន់តែដឹងថាមានជាតិអាល់កាឡូអ៊ីតនៅក្នុងស្លឹកតែប៉ុណ្ណោះ ។ចំណែកនៅក្នុងពួក Sida cordifolia មានជាតិ អេហ្វេដ្រីន ( éphédrine ) ដែលជាសារជាតិសកម្ម( Principe actif ) ។

៣. ការប្រើប្រាស់ និង កម្រិតដែលត្រូវប្រើក្នុងការព្យាបាល :

ស្លឹកស្រស់ ឬ ស្ងួត :

- ព្យាបាលបូស -បញ្ចុះលាមក -បញ្ចុះកំដៅ -បិទលើដំបៅសំរាប់ព្យាបាលដំបៅ ។

- កំរិតប្រើ : ចំពោះ
  - ដើមស្រស់ ឬ ស្លឹកស្រស់ : ៤០ ទៅ ៨០ ក្រ ក្នុងមួយថ្ងៃដោយដាំទឹកផឹក ។
  - ស្លឹកស្ងួត : ២០ ទៅ ៤០ ក្រ ក្នុងមួយថ្ងៃ ។
  - ឫស : "ស្ងោរផឹក ឬ លាងដំបៅ "
  - លាងដំបៅអោយជាសះស្បើយ "ប្រើខាងក្រៅខ្លួន "
  - ប៉ូវកំឡាំង និង ធ្វើអោយបញ្ចេញញើសស្រួលខ្លួន "ប្រើខាងក្នុងខ្លួន "
  - ព្យាបាលគ្រុនក្ដៅ ,ដើម្បីសរសៃប្រសាទ និង ដើម្បីតំរងនោម "បុកអោយទៅជាម្សៅលាយទឹកដោះគោ "។
  - ដើមឫសសំរាប់ជួតលាងដំបៅគ្រប់ប្រភេទ ។
  - ដើមនៃរុក្ខជាតិទាំងមូល សំរាប់ដើម្បីហូរទឹកកាម របស់បុរស ។
  - ប្រជាជនព័រទុយហ្គាល់ ( les portugais ) ប្រើឫសសំរាប់បញ្ចុះទឹកនោមនៃដើម្បីសន្លាក់ដៃសន្លាក់ជើង ។



www.budinst.gov.kh www.elibraryofcambodia.org

រូបមន្តមួយចំនួនដែលគេប្រើទៅក្នុងចំណោមប្រជាជន :

-ព្យាបាលបួស : -គេយកស្លឹកក្រខ្នាំងបួយសស្រស់ "មិនតិតកទិត "លាងអោយស្អាត បុកហើយបំពោកកន្លែងដែលហើមយើ ដើម្បីអោយឆាប់ធ្លាយខ្ទុះ ។ នៅទីបញ្ចាប់ គេយកស្លឹកដាំទឹកផឹកក្នុងមួយថ្ងៃពី ២០-៤០ក្រ ស្លឹកក្រៀម ។

-ព្យាបាលខ្ទួល : -គេយកដើមក្រខ្នាំងបួយ ដាំទឹកផឹក ដោយប្រើកទិតក្នុងមួយថ្ងៃពី ២០ ទៅ៤០ក្រ ទែនដើមក្រៀម ។

25 - ដើមងប់

-ឈ្មោះកម្ពុជា : ដើមងប់

-ឈ្មោះវិទ្យាសាស្ត្រ : Sauropus androgynus

- FAMILLE : Euphorbiaceae

១. លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រ : -ដើមងប់ជាប្រភេទដើមរុក្ខជាតិតូចៗ ដែលមានកំពស់ពី ០,៨០ - ២ ម មានមែកតូចស្តើង ... ស្លឹករាងពងក្រពើ និង គល់ ប៉ុន្តែចុងកណ្តាលមាន ... ប្រវែង ១១ ស.ម និង មានទទឹងប្រវែងប្រហែល ៣ ស.ម ។

ផ្កាពណ៌លឿង ឬ ក្រហមដុះជាកញ្ចុំនៅកមែក ។ ផ្លែរាងមូលមាន ... និង ... ប្រវែងពី ១០-១២ ម.ម និង មាន ... ប្រវែងពី ១៥-១៦ ម.ម ។ គ្រាប់ផ្លែរាង ៣ ជ្រុងពណ៌ក្រម៉ៅ ... ប្រវែងប្រហែល ៨ ម.ម និង មានទទឹងប្រវែងប្រហែល ៥ ម.ម ។



គេសង្កេតឃើញដើមងប់ មានដុះ និង ដាំពាសពេញក្នុង ប្រទេសកម្ពុជា ក្នុងប្រទេសឡាវ ប្រទេសចិន និង ហ្វីលីពីន ។

២. សមាសភាគគីមី : - នៅក្នុងស្លឹកមាន :

-ជាតិប្រូតីត ( Protides ) ................ ៥,៣ %

-ជាតិគ្លុស៊ីត ( Glucides ) ............... ៣,៤ %

-ជាតិកំបោរ ( $Ca(OH)_2$ ) ............. ២,៤%ក្នុងនោះ

មានកាល់ស្យូម ( Calcium ) ......... ១៦៥ ម.ក្រ % ។

-វីតាមីន សេ ( Vitamine C ) .................. ១៨៥ ម.ក្រ%



www.budinst.gov.kh www.elibraryofcambodia.org

-ផូស្វ័រ ( Phosphore )................. ៦៤,៥ ម.ក្រ%

នៅក្នុងស្លឹក ១០០ ក្រ មានសមាសភាព អាស៊ីត អាមីណេ (Acides aminés) ក្នុងអត្រាដូចតទៅ:

-លីស៊ីន ( Lysine ) .................... ០,១៦ ក្រ

-មេចូនីន ( Méthionine )............. ០,១៣ ក្រ

-ទ្រីបតូហ្វាន ( Tryptophane)............. ០,៥០ ក្រ

-ហ្វេនីលអាឡានីន ( Phénylalanine ) .... ០,២៥ ក្រ

-ត្រេអូនីន ( Thréonine ) .............. ០,៣៤ ក្រ

-វ៉ា លីន ( Valine ) .............. ០,១៧ ក្រ

-ឡឺស៊ីន ( Leucine ) .............. ០,២៤ ក្រ

-អ៊ីសូឡឺស៊ីន ( Isoleucine ) .............. ០,១៧ ក្រ

ក. -ឥទ្ធិពលថ្នាំ : -មិនទាន់មានឯកសារស្រាវជ្រាវអំពីដើមនេះនៅឡើយ ។

ខ. -ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើ : -ស្លឹកក្រៅពីស្ល ព្យាបាលជម្ងឺ "ជម្ងឺគ្រុនក្តៅរបស់ស្ត្រីក្នុងពេលសំរាលកូនជាពិសេសនៅពេលស្លុកឈ្លាក់មិនអស់" ។

-របៀបព្យាបាល : -គេយកស្លឹកស្រស់ ៤០ ក្រ លាងអោយស្អាតបុកអោយម៉ត់ បន្ថែមទឹកដាំពុះបន្តិច ទុកអោយត្រជាក់ ។ រួចច្របាច់យកទឹកវា ១០០ ម.ល ចែកចេញជាពីរដង ផឹកម្តងចន្លោះពេល ១០ នាទី ។ ក្រោយពីផឹករួច ១០ ទៅ ១៥ នាទី ស្លុកឈ្លាក់អស់ ។

-មានអ្នកខ្លះទៀត បុកវាយកទៅលាបច្បាស់ជើង ដើម្បីព្យាបាលជម្ងឺខាងលើដែរ ។

-របៀបព្យាបាលឈ្លក់ : -គេបុកស្លឹកឯបស្រស់ ច្របាច់យកទឹកបៀមដើម្បីព្យាបាល ឈ្លក់ ។

ឬស : -ព្យាបាលគ្រុនក្តៅ ហើចង្កះដោយសារគ្រុនពាង្រក់

-ជម្ងឺបណ្តាលអោយផ្លោកនោមរួមតូច

ស្លឹក និង ឫស : -ជំទប់ប្រមុះ "បុកលាប"

~ ចប់ ~

---

26 - ដើម ខ្នាញ់

-ឈ្មោះជាកម្ពុជា : ដើម ខ្នាញ់

-ឈ្មោះជាឡាតាំង : Eclipta erecta Lamk

- FAMILLE : Asteraceae



www.budinst.gov.kh www.elibraryofcambodia.org

១. លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : គឺជាប្រភេទដើមរុក្ខជាតិម៉្យាងដុះទាបពុំត្រង់ឡើងលើ ដែលមានកំពស់ប្រហែល ៨០ ស.ម ។ ស្លឹកដុះទល់ទង មានរោមទាំងផ្នែកខាងលើ និង ខាងក្រោម ។ ជុំវិញស្លឹកមានរាងជាធ្មេញរណារ តែមិនសូវស្រួចទេ ។ ស្លឹកនេះស្រួចចុង បណ្តោយប្រវែងពី ២ ទៅ ៨ស.ម និង មានទទឹងប្រវែងពី ៥-១៥ ម.ម ។

គេសង្កេតឃើញ ដើមខ្នាញ់មានដុះ និង ដាំពាសពេញក្នុងប្រទេសដែលមានធាតុអាកាសក្តៅ ហើយសើម ។

២. សមាសភាពគីមី : នៅក្នុងដើមខ្នាញ់មាន :

ជាតិប្រេង ជាតិជ័រ ជាតិល្វីង ជាតិ ការ៉ូទីន ( Carotine ) និង ជាតិអាល់កាឡូអ៊ីតម៉្យាងឈ្មោះ អេគ្លីបទីន ( Ecliptine) ខ្លះនិយាយថា អាល់កាឡូអ៊ីត(Alcaloïde) នេះជា នីកូទីន ( Nicotine ) ។



៣. ឥទ្ធិពលថ្នាំ : គេបានស្រាវជ្រាវនៅវិទ្យាល័យវេជ្ជសាស្ត្រ និង ឱសថសាស្ត្រក្រុងហាណូយ ហើយបានរកឃើញនូវឥទ្ធិពលឃាត់ឈាម ដូចខាងក្រោមនេះ :

. ឥទ្ធិពលឃាត់ឈាមរបស់ខ្នាញ់ : គេយកដើមខ្នាញ់ដែលហាលស្ងួតរួចដាំទឹក ដើម្បីធ្វើពិសោធទៅលើឆ្មា ដោយប្រើទឹកដាំក្នុង ៣ក្រ ក្នុង ១ គ.ក្រទម្ងន់របស់ឆ្មា ។ តាមការពិសោធនេះគេសង្កេតឃើញ អត្រា ប្រូត្រុមប៊ីន ( Prothrombine) កើនឡើងដូចឥទ្ធិពលរបស់ជីវជាតិ កា ( Vitamine K ) ដែរ ដែលប្រឆាំងនឹងឥទ្ធិពលរបស់ឌីគូម៉ារីន ( Dicoumarine ) ។ សូមបញ្ជាក់ថាជាតិ ឌីគូម៉ារីន ( Dicoumarine ) នេះ ចង់តែធ្វើអោយឈាមហូរ ។ ដូច្នេះគេអាចសន្និដ្ឋានថា ដើមខ្នាញ់គឺពិតជាមានឥទ្ធិពលឃាត់ឈាម ( Effet hémostatique ) មែន ។

-ក្រោយពីការប្រើទឹកដាំដើមខ្នាញ់នេះ ការពិសោធន៍ទៅលើឆ្មាបានបញ្ជាក់បន្ថែមថា ក្រោយពីប្រើ ពុំធ្វើអោយមានកំរិតឈាមឡើង ( Hypertension artérielle ) និងធ្វើអោយពីតសរសៃឈាមទេ ។

-ការពិសោធន៍មួយទៀត បានធ្វើទៅលើ :

- ស្ត្រីមានផ្ទៃពោះ ១ ខែ-២ ខែ
- និង ស្ត្រីគ្មានផ្ទៃពោះ

ដែរមានធ្លាក់ឈាមដូចគ្នា ។ ក្រោយពីព្យាបាលក្នុងកំរិត ២០ ក្រ ក្នុងមួយថ្ងៃ រយៈពេល ៣ ថ្ងៃ អ្នកជម្ងឺទាំងពីរប្រភេទនេះ បានជាសះស្បើយ ។

www.budinst.gov.kh www.elibraryofcambodia.org

៥. ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល :

-នៅប្រទេសឥណ្ឌូចិន : -រុក្ខជាតិទាំងមូល

.ព្យាបាលហឺត -រលាកទងសួត -រលាកបំពង់ក -ក្អករបេង -ឃាត់ឈាមពេលមានរដូវខ្លាំង ឬ ពេលមានឈាមហូរខ្លាំង ។

.កំរិតប្រើ : -៦ - ១២ ក្រ ក្នុងមួយថ្ងៃ ឬ លុញជាគ្រាប់

.ស្លឹកលើដីផងក៏ប្រើបាននៅពេលដែលមានការរលាកដោយសាររបួសរកំរបួស - ព្យាបាលជម្ងឺខាន់ស្លាក់ ព្យាបាលជម្ងឺកមរមាស់លើស្បែក - ធ្វើអោយដុះសក់ដោយរងាស់ ឬ គ្រាំក្នុងប្រេងដូង ។

-នៅប្រទេសអាហ្វ្រិក : -រុក្ខជាតិទាំងមូល

.បន្ទន់លាមក - បញ្ចុះលាមក - ធ្វើអោយក្អួត

-នៅប្រទេស ម៉ាឡេស៊ី : - ស្លាវ " ឫស " "

.សំរាប់ស្ត្រីក្រោយពេលសំរាលកូនរួច

=នៅប្រទេស ឥណ្ឌា : -រុក្ខជាតិទាំងមូល

.ព្យាបាលជម្ងឺលើស្បែក និង ឃ្លង់

ស្លឹក "បុកអោយម៉ត់ "សំរាប់ព្យាបាល

.ដំបៅហូរខ្ទុះ - ជម្ងឺស៊ាំទីរ៉ - ជម្ងឺឡើងពងទឹកលើមុខ ដូចមុន

-នៅប្រទេសមជ្ឈិមបូព៌ា : ស្លឹក "រងាស់ដឹក "

.ធ្វើអោយដុះសក់ឡើងវិញ

-នៅប្រទេសសិង្ហបុរី : ស្លឹក "គ្រាំក្នុងប្រេងដូង "

.លាបបំបាត់ការឈឺចាប់ ត្រង់កន្លែងដែលឈឺលើខ្លួនអ្នកជម្ងឺ

-នៅប្រទេសម៉ាឡាយូ : ស្លឹក "ដាំអោយពុះ "

.ដុសបំបាត់ការឈឺចាប់ នៅកន្លែងធ្មេញឈឺ ។

៚ ចប់ ៚

៚

27 - ដើមកាឆាយ

-ឈ្មោះជាកម្ពុជា : ដើមកាឆាយ

-ឈ្មោះជាឡាតាំង : Allium odorum

-FAMILLE : Liliaceae

១. លក្ខណះរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ

កាឆាយជារុក្ខជាតិម្យ៉ាងតូចដូចពួកខ្ទឹម ដែលគេដាំសំរាប់ធ្វើជាបន្លែ ។ ស្លឹកវាត្រង់ហើយសំប៉ែត ។ ផ្កា



www.budinst.gov.kh www.elibraryofcambodia.org

ពណ៌ស ធំបង្គួរប្រវែងពី ១០-១៥ ម.ម ។ កាដាយបានប្រជាជនដាំពាសពេញក្នុងប្រទេសវៀតណាមចិន ក្នុងលក្ខណះដាំបន្លែ ។

២. -សមាសភាពគីមី : -នៅក្នុងស្លឹក និង ឫស មានជាតិ :

-ជាតិ សាប៉ូនីន ( Saponine ) និង ជាតិ ល្វីង ។

-នៅឆ្នាំ ១៩៥៨ ប្រទេសចិន ឃើញការដាយមាន :

-ជាតិ អូដូរីន មិនសូវពុល ( Odorine peu toxique ) ដែលអាចប្រឆាំងនឹងមេរោគឈ្មោះ ស្តាហ្វីឡូកុកគុស និង បាស៊ីលុស កូលី ( Staphylococcus auréus et Bacillus coli ) ។

-នៅក្នុងគ្រាប់កាដាយ "នៅប្រទេសចិន "មាន :

-ជាតិ អាល់កាឡូអ៊ីត " ( Alcaloïde ) និង ជាតិ សាប៉ូនីន (Saponine)

៣. -ឥទ្ធិពលថ្នាំ : -ជាតិ អូដូរីន ( Odorine ) មានឥទ្ធិពលប្រឆាំង និង មេរោគឈ្មោះ ស្តាហ្វីឡូកុកគុស អូរេអ៊ុស និង បាស៊ីលុស កូលី ( Staphylococcus auréus-Bacillus coli ) ។



-នៅពេលថ្មីៗកន្លងទៅនេះ នៅខាងការិយាល័យថ្នាំបូរាណ បានរាយការណ៍ថាស្លឹកកាដាយស្រស់ គេច្របាច់យកទឹកមានជាតិប្រឆាំងនឹងមេរោគជាច្រើនដូចជា :

-ស្តាហ្វីឡូកុកគុស អូរេអ៊ុស ( Staphylococcus auréus ។

-សាល់ម៉ូណែលឡា ទីហ្វី Salmonella typhi ។

-ស៊ីហ្គែលឡា ហ្វ្លិចនើរី Shigella flexneri ។

សភាពប្រឆាំងជាមួយមេរោគដូចរៀបរាប់ខាងលើនេះ មានឥទ្ធិពលខ្លាំង ។ ជាតិទឹកច្របាច់ចេញពីស្លឹកកាដាយ មិនមានជាតិហិរ និង ក្តៅ ដូចខ្ទឹម សទេ ។ ដូច្នេះក្មេងអាចផឹកបាន ។

៤. -ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល :

-ជាតិទឹកស្លឹកកាដាយពួត : សំរាប់ព្យាបាលជម្ងឺ :

-ក្អកកូនក្មេង - រាគមួល - ជំនួយការរំលាយអាហារ

កំរិតប្រើ : -២០ -៣០ ក្នុងមួយថ្ងៃ

-ស្លឹកដាំទឹកផឹក : សំរាប់ព្យាបាលជំងឺ ព្រូន អៀន ( Oxyurose )

-គ្រាប់ផ្លែតូចៗរបស់កាដាយ :

-គ្រាប់ផ្លែនេះមានពណ៌ខ្មៅស្រអាប់ កិនអោយម៉ត់ទៅជាម្សៅ បន្ទាប់មកគេលាយនឹងទឹកក្តៅ បង្កើតបានជាទឹកសំរាប់លាងសំលាប់មេរោគ ក្នុងមាត់ ។ ទឹកលាងសំលាប់មេរោគនោះកាលណាគេយកទៅផុសធ្មេញដោយប្រើច្រាស អាចនឹងបំបាត់ពួក ប៉ារ៉ាស៊ីត នៅក្នុងមាត់បាន (Parasites buccaux ) ។

-អាចប្រើជាថ្នាំលើកកម្លាំងបានដែរ ។

-នៅក្នុងប្រទេសចិន : គេយក គ្រាប់ផ្លែ និង មើម

-សំរាប់ព្យាបាល លើកកម្លាំង - បន្សុតឈាម - និងព្យាបាលជម្ងឺរាគ "តាមការបញ្ជាក់របស់លោក រ៉ូអ៊ា " Roi" " ។



www.budinst.gov.kh www.elibraryofcambodia.org

សារធាតុសកម្មឈ្មោះ អូដូរីន ( Odorine ) ដែលលោកឃ្មី ឆៃ ស៊ិន Chi I Shen ចំរាញ់យកចេញពីមើមការណាយ មិនមានជាតិពុលខ្លាំងឡើយ ចំពោះប្រភេទមនុស្ស តែវាអាចសំលាប់មេរោគឈ្មោះ ស្តាភីឡូកុកគុស និង បាស៊ីលុស កូលី Staphylococcus auréus et Bacillus Coli ) ។

១៩៦១ ច ប់ ១៩៦១

១៩៦៣

## 28 – ដ ើ ម ឆ្អឹ ង ម ា ន់ ខ្មៅ

- ឈ្មោះជាកម្ពុជា : ដើមឆ្អឹងមាន់ខ្មៅ
- ឈ្មោះជាឡាតាំង : Gendarussa vulgaris Nees
- FAMILLE : Acanthaceae

១. លក្ខណៈភូមិសាស្ត្រ និង លក្ខណៈរុក្ខជាតិ : -ដើមឆ្អឹងមាន់ខ្មៅ គឺជារុក្ខជាតិមួយដែលលំបូរឡើងទៅដោយមែកឈើក្រហមចាស់ ឬ ទឹមតង ប៉ុន្តែមានសភាពរលោង ។ ស្លឹកវាវែងមានទងខ្លី ប៉ុន្តែមានរាងវែងស្រួចចុង ។ ផ្កាពណ៌ស លាយទឹមតងស្រអាប់ លាយក្រហមក្រមៅ ដុះចេញពីខាងចុងដើមរាងជាប់បន្តគ្នា ។ ផ្លែមានបណ្តោយប្រវែង ១២ ម.ម ផ្ទុកទៅដោយគ្រាប់ចំនួន ៤ នៅផ្នែកខាងក្រោម ។



ដើមឆ្អឹងមាន់ខ្មៅ ត្រូវបានគេដាំជាទូទៅក្នុងសួនសាធារណៈឬ តាមផ្ទះក្នុងលក្ខណៈបង្កើតសោភ័ណភាព ។ វាជារុក្ខជាតិមានលក្ខណៈស្រួលដុះ និង ស្រួលដាំគ្រប់ស្ថានភាពដី ។

២. សមាសភាពគីមី : -នៅក្នុងស្លឹក :

-មានសារធាតុសកម្ម Alcaloïde toxique ពុលឈ្មោះ យូស្ទីស៊ីន ( Justicine)

-ជាតិប្រេងតិចតួច................ 0,00១ %

-និង ជាតិអំបិល ប៉ូតាស្យូមជាច្រើនភាគរយ ( Sels de potassium ) ។

៣. -ការប្រើប្រាស់ និង.កំរិតដែលត្រូវប្រើក្នុងការព្យាបាល : -ប្រជាជនច្រើនប្រើយកដើមបុកបំពោកកន្លែងដែលហើម ឬ មួយដាំទឹកផឹក ។ នៅពេលដែលទឹកកំពុងក្តៅអ៊ុនៗ យកទៅស្អំ ការចុករោយ និង ស្ពឹកស្រពន់ តាមក្បួនឱសថបុរាណ ឫសរបស់ឆ្អឹងមាន់ខ្មៅមានជាតិល្វីងហឹរ ។ តាមការស្រាវជ្រាវនេះ បានអោយដឹងថា ជាតិវាមានឥទ្ធិពលធ្វើអោយ :

-មានការ[illegible]ទល់ -បង្អន់ការឈឺចាប់ - បញ្ចុះលាមក - ព្យាបាលជម្ងឺខាន់ស្លៀង និង គ្រុនក្តៅក្អក ។

កម្រិតប្រើ : មួយថ្ងៃ ពី ៦ទៅ ១២ក្រ ដាំទឹកផឹក ឬប្រើជាការ៉ ឬ ត្រាំស្រា ។

- នៅប្រទេសឥណ្ឌា ស្លឹកកិនអោយម៉ត់ដែលមានក្លិនឆ្អួលប្រហើរខ្លាំង ត្រូវបានយកទៅស្ងោរផឹកព្យាបាលជំងឺសន្លាក់ ដែលសន្លាក់ជើងរ៉ាំរ៉ៃ ហើយហើមទៀត ។

- ទឹកស្លឹកព្យាបាលក្អកកូនក្មេង

- សំបកដើមកថ្មី ដែលមានពណ៌ក្រហមក្រម៉ៅ ( Pourpre sombre ) ជាថ្នាំដែលគេប្រើនៅសាវ៉ា Java ធ្វើអោយក្អួត ។

- នៅប្រទេសឥណ្ឌា គេស្ងោររុក្ខជាតិទាំងមូល ដោយយកទឹកស្ងោរប្រើក្នុងកម្រិត ១ ពែង ពីរដងក្នុង ១ ថ្ងៃ ដើម្បីធ្វើអោយក្អួត ។

- នៅប្រទេសចិន ឬសដែលល្វីងខ្លាំង សំរាប់ប្រើព្យាបាល ជំងឺសន្លាក់ដៃ សន្លាក់ជើង ។

- រុក្ខជាតិទាំងមូល ត្រូវបានព្យាបាល ចុកពោះកូនក្មេង ។

- នៅអង់ទីយ៍ ( Antilles) គេប្រើរុក្ខជាតិទាំងមូលសំរាប់ព្យាបាលគ្រុន "ស្ងោរផឹក" ដោយប្រើ ៣០ក្រាម នៃរុក្ខជាតិដាក់ស្ងោរក្នុងទឹក ១ លីត្រ ។

- នៅប្រទេសឥណ្ឌាដដែល គេប្រើស្លឹកឆ្អឹងមាន់ខ្មៅដាក់ក្នុងអាវ ដើម្បីការពារពួកសត្វល្អិត កុំអោយខាំមករោម ។

- នៅក្នុងក្បួនឱសថចិន ដែលមានឈ្មោះថា "ស៊ីន - គីង"(Tsin-Kin) គេប្រើឆ្អឹងមាន់ខ្មៅដាំអោយពុះជាមួយទឹកដោះគោ សំរាប់ព្យាបាល :

- ជំងឺសន្លាក់ដៃជើង - រោមទាស់ - និង កើតលឿង ។

## 29 - ដើមមក្លឿ

- ឈ្មោះជាកម្ពុជា : ដើមមក្លឿ
- ឈ្មោះជាឡាតាំង : Diospyros mollis Griff
- FAMILLE : Ebenaceae

១ - លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : - គឺជាប្រភេទរុក្ខជាតិដែលមានទំហំមធ្យម ព្រមទាំងមានមែកសំបូរណ៍ដោយរោមខ្លីៗ និងតូចឆ្មារ ។

- ស្លឹកឆ្លាស់គ្នា រាងដូចពងក្រពើស្រួចចុង ហើយគ្មានរោម ។ស្លឹកនេះមានបណ្តោយប្រវែងពី ៥,៥ ទៅ ១៣ ស.ម ប្រកបទៅដោយទងមានរោមប្រវែងពី ៣-៦ ម.ម ។



- ផ្កាតូចពណ៌លឿងស្លេក ។ផ្កាប្រភេទឈ្មោលជាកញ្ចុំ ដែកមែកមានរោមខ្លីៗដុះចេញពីកន្លែងស្លឹកដុះចេញ ។ ផ្កាប្រភេទញីមានតែឯង ប៉ុន្តែដុះចេញពីស្លឹកនិងដើម ។

- ផ្លែរាងមូល ទំហំប៉ុនផ្លែទេរី ហើយមានគំរបនៅកន្លែងចុងឈ្នាប់ជាប់ផ្លែ ។ ផ្លែនេះមានគ្រាប់តែមួយគត់ ។

គេសង្កេតឃើញដើមមក្លឿមានដុះនិងដាំនៅក្នុងប្រទេសកម្ពុជា - ប្រទេសឡាវ - ភូមា - និង ថៃ ។

២ - សមាសភាពគីមី . -

នៅក្នុងផ្លែមាន :

www.budinst.gov.kh www.elibraryofcambodia.org

- សារធាតុគីមីមួយឈ្មោះ ឌីយ៉ូស្ពីរ៉ូគីណូន (Diospyroquinone) ដែលមានរូបមន្ត $C_{12}H_{12}O_2$
- ជាតិតាណាំង ................................១០ ភាគរយ នៃ Tanins Catéchiques
- ជាតិស្តេរ៉ូល ( Stérols )
- អាស៊ីតសរីរាង្គ ( Acide organique )
- សារធាតុគីមីអាប្រូហ្សែន ( Principes aphrogènes )
- ហ្វ៊ែរម៉ង់តិ៍ ( Ferments
  មាំងវែ៉ាកទីន ( Invertine ) និង អេមុលស៊ីន ( Emulsine )

ឥទ្ធិពលថ្នាំ :

ផ្លែមក្លឿពព្យាបាលព្រូន ដោយសារធាតុ ឌីយ៉ូស្ពីរ៉ូគីណូន ( Diospiroquinone )

- ការប្រើប្រាស់ និង កម្រិតដែលត្រូវប្រើក្នុងការព្យាបាល :
  - ផ្លែមក្លឿ ប្រើសំរាប់សំលាប់ព្រូន ពពួកតេនីញ៉ា Tœnécide ou vermicide ដោយសារសារធាតុគីមី ឌីយ៉ូស្ពីរ៉ូគីណូន ( Diospyroquinone )
  - កម្រិតប្រើ : ៦ ទៅ ១០ ក្រាប់ក្នុងមួយថ្ងៃ
  - លើសពីនេះទៅទៀតឌីយ៉ូស្ពីរ៉ូគីណូន (Diospyroquinone ) មានលក្ខណៈអង់ទីប៊ីយ៉ូទិកខ្សោយដែរ ( Antibiotique faible )

" La diospyroquinone possède également des propriétés antibiotiques faibles

"Au point de vue pharmacodynamique,le fruit est peu toxique.Nous avons pu vérifier d'autre part son action vermicide :elle est réelle et dûe à la diospyroquinone.Celle-ci possède également des propriétés antibiotiques faibles "

30 - ផ្កាម្លិះ

ឈ្មោះជាកម្ពុជា : ផ្កាម្លិះ

ឈ្មោះជាឡាតាំង : Jasminium sambac Ait : FAMILLE : Oleaceae

១- លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ . .

- ផ្កាម្លិះគឺជាប្រភេទដើមតូចៗ ។
- ស្លឹកទាងពងក្រពើ មានបណ្តោយប្រវែងពី ៣- ៧ ស.ម មានទទឹងប្រវែងពី ២០- ៣៥ម.ម រាង ភ្លឺរលោងទាំងផ្នែកស្លឹកខាងលើ និង ខាងក្រោម ប៉ុន្តែមានរោមនៅផ្នែកខាងក្រោម ។
- ផ្កាជាកញ្ចុំដុះនៅខាងចុងដើម ។

ផ្លែមានពីរថ្នាំង រាងមូល ហើយមានប្រវែងពីរម៉ីលីម៉ែត្រ ផ្លែនេះពណ៌ខ្មៅ ហើយពទ្ធ័ជុំវិញទៅដោយស្លឹកគ្របផ្លែ ។

គេសង្កេតឃើញដើមផ្កាម្លិះ មានដាំនៅក្នុងប្រទេសឥណ្ឌូចិន សំរាប់យកផ្កាប្រើប្រាស់ក្នុងកិច្ចការផ្សេងៗ ។

www.budinst.gov.kh www.elibraryofcambodia.org

២-សមាសភាពគីមី : -នៅក្នុងផ្កាមានជាតិប្រេង ក្រអូបប្រហែល ០,០៨ ភាគរយ ។សមាសភាពគីមីរបស់ជាតិក្រអូប នោះគឺ :



-ប៉ារ៉ាហ្វីន Paraffine អេស្ទែរ ហ្វ័រមិក ester formique អេស្ទែរ អាសេទិក ester acétique អេស្ទែរបង់ស៊ូអ៊ិក ester benzoïque លីណាលីល Linalyl

-អេស្ទែរ អង់ត្រានីលិក មេទីល និង អាំងដូល Ester anthranilique méthyl et indol ។

៣-ការប្រើប្រាស់ និង កំរិតត្រូវប្រើក្នុងការព្យាបាល :

ឥទ្ធិពល : -តាមឯកសារបុរាណ គេយកឫសផ្កាម្លិះ ចំនួន ៣ ស.ម ដាក់ត្រាំក្នុងស្រាពីក អាចធ្វើអោយសន្លប់មួយថ្ងៃ ។ឫសធ្វើអោយវង្វេង និង ស្រវឹង ។ ដើម្បីត្រូវបន្តការពិសោធន៍តទៅទៀត ។

-គេយកផ្កាដាំទឹក សំរាប់លាងភ្នែក ឬ មួយភាយដូចតែដាំទឹកផឹក សំរាប់ព្យាបាលខ្លួន ។

កំរិតប្រើ : ២-៤ ក្រាម ក្នុងមួយថ្ងៃ

-ពេលខ្លះគេយកស្លឹកបុកលាយជាមួយវ៉ាសិលីន ដាក់លើភ្នែក ព្យាបាលភ្នែកដាំ ឬ ដាំក្រហមភ្នែក ។

-នៅក្នុងតំបន់ Cap-St Jacques គេយករុក្ខជាតិទាំងមូលប្រើព្យាបាលចុកពោះ ចង្កោះដោយសារគ្រុនចាញ់ ។

-នៅប្រទេសកម្ពុជាយើង ផ្កាម្លិះយកមកលាយជាមួយថ្នាំដទៃទៀត ធ្វើជាទឹកលាងសំរាប់ព្យាបាល ភ្នែកឡើងស្លេក បណ្តាលមកពីគ្រុនដោយសារពងបែក ។ អាចធ្វើជាថ្នាំបន្សាបព្យាបាលជំងឺបូសមាត់របស់កូនក្មេង ។

-នៅប្រទេសម៉ាឡេ យកផ្កា សំរាប់ព្យាបាលបំបាត់ការចេញទឹកដោះ ។គេអាចយកស្លឹក ២ ឬ ៣ ក្តាប់បុកលាបលើដោះ ២ ឬ ៣ ដងក្នុងមួយថ្ងៃ ដើម្បីកុំអោយទឹកដោះចេញបានទៀត ។

-នៅប្រទេសហ្វីលីពីន ផ្កាស្ងោរទឹកផឹក ធ្វើជាថ្នាំដាក់ភ្នែក សំរាប់ព្យាបាលរលាកភ្នែកបណ្តាលអោយក្រហម។

-តាមការស្រាវជ្រាវថ្មីៗ នេះបានអោយដឹងថា ឫសផ្កាម្លិះត្រាំក្នុងស្រា ដើម្បីធ្វើជាថ្នាំស្ពឹកសំរាប់ដាក់ចំពោះអ្នកជំងឺកុំអោយឈឺខ្លាំងនៅពេលវះកាត់ ។

31 - ដើមស្នាយ

-ឈ្មោះកម្ពុជា : ដើមស្នាយ

-ឈ្មោះជាឡាតាំង: Streblus asper

- FAMILLE : Moraceae

១-លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : -គឺជាប្រភេទដើមឈើម៉្យាង នៅពេលដែលចាស់ភ្លាំ ដុះពន្លឺតែរលីងគ្នា បើពុំដែលទៅ ដោយមែកមានផ្កាផាប្រើន ដើមមានកំពស់ប្រហែលពី ៥ ទៅ ៨ ម ។ ស្លឹករាងពងក្រពើដួនកាលស្រួច ឬ ទាលចុង បណ្តោយប្រវែងពី ៣ ទៅ ៧ ស.ម និង មានទទឹងប្រវែងពី ១៦ ទៅ ៣៥ ម.ម ។ជុំវិញគែមស្លឹក មានរាងជាធ្មេញរណារ ។ផ្កាមានពីរភេទ គឺមានញីផង ឈ្មោលផង ។

-ផ្នែកផ្កាឈ្មោលរួមផ្តុំបញ្ចូលគ្នាដូចជាក្បាល របស់ចង្រួមបញ្ចូលគ្នា ។

-ផ្នែកផ្កាញី នៅដាច់ពីគេឯងៗម្នាក់ៗ ។ ផ្លែរាងមូលទទេ ពណ៌លឿងហើយមានទំហំប៉ុនផ្លែ

www.budinst.gov.kh www.elibraryofcambodia.org

អង្រ្កែមអង្រ្កែម ។ គេឃើញដើមស្វាយមានដុះនៅប្រទេសឥណ្ឌូចិន នៅផ្នែកភាគខាងត្បូងនៃប្រទេសចិន និង នៅហ្វីលីពីន ក្នុងស្ថានភាពដីទួល ឬ វាលទំនាប ។



២_សមាសភាពគីមី : _គេបានរកឃើញនៅក្នុងជ័រស្វាយមាន :

_ជាតិរេស៊ីន Résine ......... ៧៦ %

_ជាតិកៅស៊ូ Caoutchouc ......... ២៣ %

៣_ការប្រើប្រាស់ និង កិរិតដែលត្រូវប្រើក្នុងការព្យាបាល : _ប្រជាជនវៀត ណាម ប្រើជ័រស្វាយធ្វើជាកៅ យកសំរាប់បិតលើសៀត ផ្លា ព្យាបាលឈឺក្បាល ។

_នៅប្រទេសវៀត ណាម តំបន់ញ្ញាត្រាងភាគខាងត្បូង មែកស្វាយត្រូវគេកាត់ជាកំណាត់តូចៗ រួចហើយយកទៅស្ងោរហូប សំរាប់ព្យាបាលជម្ងឺ ពោះប៉ោងធំ ដែលគេហៅថាអាសស៊ីត ( Ascite) ។

_មែកនិងឫសវា ដាំទឹកផឹកសំរាប់ព្យាបាល :

- បព្ចោះឈាមក

- ហើមពោះ

- សំបក : ស្ងោរផឹក ធ្វើជាទឹកសំអាតមាត់ សំរាប់ព្យាបាលឈឺធ្មេញ ។

- យកទៅបៀមសំរាប់ព្យាបាលឈឺបំពង់ក ។

- នៅប្រទេសកម្ពុជាយើង ឬស្វាយផ្សំជាមួយថ្នាំផ្សេងៗទៀត សំរាប់ព្យាបាលជម្ងឺក្អក និង របេងរីងរៃ ។

- នៅប្រទេសឥណ្ឌា គេយកសំបកដាំទឹកផឹកសំរាប់ព្យាបាល : - គ្រុនក្តៅ និង រាគមួល ។ ទឹកស្ងោរដដែលនេះគេអាចលាបអោយស្ងួត កំទេចអោយម៉ត់ហើយរលាយក្នុងខ្យល់ព្យាបាលដូចដំនឹងខាងលើដែរ។គេអាចប្រើជាតិចម្រាញ់របស់ឫសដែរ ។

- នៅតំបន់ កាប់សាំងសាក់Cap St Jacques នៃប្រទេសវៀតណាមភាគខាងត្បូង ឫសស្ងោរសំរាប់ជំងឺខាន់ស្លាក់ ។

- ជាតិជ័រ ប្រើសំរាប់ព្យាបាល : ដំបៅដែកងជើង ប្រេះបបូរមាត់ និង ហើមកូនកណ្តុរ ។

- នៅសាវ៉ា JAVA ស្លឹកលាយជាមួយអំបិលបន្តិច ត្រូវបានស្ងោរផឹកសំរាប់ស្ត្រីក្រោយឆ្លងទន្លេរួច ដើម្បីអោយចេញទឹកដោះ ។

32 - ស្មៅទឹកដោះខ្លា

-ឈ្មោះជាកម្ពុជា : ស្មៅទឹកដោះខ្លា

-ឈ្មោះផ្សារទ្បាតាំង : Euphorbia hirta

- FAMILLE : Euphorbiaceae

១_លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដំដុះ : ._គឺជាប្រភេទស្មៅម៉្យាង ដែលមានដើមដុះត្រង់ឡើងលើ មានកំពស់ពី ៣០ ទៅ៤០ ស.ម។ដើមពណ៌ក្រហមព្រឿងៗ គ្រប ដណ្តប់ទៅដោយរោមពណ៌លឿងខ្ចី ជាពិសេសនៅចុងដើម ។ ស្លឹកពណ៌បៃតងស្រអាប់លាយក្រហម ។ស្លឹកនេះទល់ទង រាងពងក្រពើ មានបណ្តោយប្រវែងពី ៤ ទៅ ៥ស.ម និង មានទទឹងប្រវែងពី ៧ ទៅ ១៥ ម.ម ។គែមជុំវិញស្លឹករាងជាធ្មេញរណារ មានរោម និង គ្រាតគ្រាតព្រមទាំងមាន

www.budinst.gov.kh www.elibraryofcambodia.org

ទងខ្លីៗ ។ផ្កាវាតូចៗ ពណ៌ ស លាយក្រហមព្រឿងៗ ។ផ្កានេះដុះចេញពីចន្លោះដើម និង ស្លឹកមានសភាពដែលគ្ទន់ៗ



-ផ្លែវាមុនដំបូងពណ៌ក្រហម បន្ទាប់មកក្លាយទៅជាពណ៌ខៀវ និងនៅទីបញ្ចប់ក៏ក្លាយទៅជាពណ៌ឈាមជ្រូក នៅពេលដែលរុក្ខជាតិនោះឃ្លូត ។គ្រាប់ផ្លែមានពណ៌ក្រហមព្រឿង មានរាងស្រួច រាងមូនជ្រុងតូចៗ តែមានសភាពគ្រាតៗ ។ ស្មៅទឹកដោះខ្លា មានដុះនៅពាសពេញប្រទេសឥណ្ឌូចិន និង នៅក្នុងគ្រប់ប្រទេសក្តៅក្នុងលក្ខណៈជាធម្មជាតិ ។

២-សមាសភាពគីមី : -អាស៊ីតហ្គាលីក ( Acide gallique )
-កាក់ស៊ីទីន ( Quercitine )
-គ្លុយកូស៊ីតមួយពុលដែលគេមិនស្គាល់ ( Un glucoside toxique indéterminé )
-និងមានរេស៊ីនមួយ ( Une résine )

ប្រយត្ន័ : -សារជាតិសកម្មកាក់ស៊ីទីន ( Quercitine ) ពុលណាស់វាអាចសម្លាប់សត្វចតុប្បាទក្នុងកំរិតតិចបំផុត ។

៣-ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល :-

ឥទ្ធិពលថ្នាំ -ដើមមានជាតិពុល ចំពោះកណ្តុរ និង ត្រី ។

-នៅប្រទេស វៀតណាម គេប្រើសំរាប់ព្យាបាលរាគមួល

-កំរិតប្រើ : -កូនក្មេងពី ១៥-២០ ក្រ. ក្នុងមួយថ្ងៃ
-មនុស្សចាស់ពី ១០០-១៥០ ក្រក្នុងមួយថ្ងៃ

-ជាតិជ័រសំរាប់ព្យាបាលជំងឺរោគភ្នែកបណ្តាលអោយក្រហម ( Conjonctivite ) និង ដំបៅគរ័ណេ ( Ulcération de la cornée )

-នៅប្រទេសឥណ្ឌូនេស៊ី ជាតិថ្នាំទឹកចំរាញ់ចេញពីស្មៅទឹកដោះខ្លា សំរាប់ព្យាបាលជំងឺឈឺដើមទ្រូង និង ការហូរទឹករងឹង ។

-ជាតិទឹករបស់ស្មៅទឹកដោះខ្លា ប្រើទៅលើស្បែកអាចព្យាបាលជំងឺពងបែកនៅលើស្បែក ។

-តាមក្បួនថ្នាំឱសថនៃប្រទេសអឺរ៉ុប ( Pharmacopée européenne ) គេប្រើរុក្ខជាតិទាំងមូលសំរាប់ព្យាបាលហឺត ។

-ជំងឺរួមតូចនៃទងសួត
-និង ជំងឺរលាកទងសួតរ៉ាំរ៉ៃ ។

រូបមន្តថ្មី : -គេយកដើមរុក្ខជាតិទាំងមូល ៨០ក្រដាក់រំងោះក្នុងទឹក ២០០០ ម.ល ដោយប្រើក្នុងកំរិតពី ៣ ទៅ ៤ កែវក្នុងមួយថ្ងៃ ។ឯកំរិតដែលប្រើក្នុងការប្រើជាតិថ្នាំចំរាញ់ដោយដាក់ត្រាំស្រាវិញគឺ ១០ ស.ក្រ ក្នុងមួយថ្ងៃ និង ប្រើថ្នាំត្រាំស្រាកំរិតពី ១០-៣០ ដំណក់ ។

-ក្នុងរបៀបធ្វើនេះ ១ ក្រនៃជាតិថ្នាំត្រាំស្រាស្មើ នឹង ៥ ក្រនៃដើមរុក្ខជាតិ ។ ក្នុងរយះពេល ៨ ថ្ងៃនៃការព្យាបាលត្រូវឈប់ម្តង ពីព្រោះជាតិថ្នាំអាចបណ្តាលអោយរលាកក្រពះ ។ ក្នុងន័យនេះដែរ គេត្រូវតែពិសារមុនពេលបាយ ។ នៅប្រទេសផ្សេងៗទៀត គេយកស្មៅទឹកដោះខ្លាធ្វើជាថ្នាំសម្លាប់សត្វល្អិត ។៚

www.budinst.gov.kh www.elibraryofcambodia.org

# 33 - ស្មៅក្រវាញជ្រូក

ឈ្មោះជាកម្ពុជា : ស្មៅក្រវាញជ្រូក

ឈ្មោះជាឡាតាំង : Cyperus rotundus

ឈ្មោះជាបារាំង : Souchet rond

FAMILLE : Cyperaceae

១-លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : -គឺជាប្រភេទស្មៅម៉្យាងដែលមានមើម ។ ដើមដុះត្រង់ឡើងលើ ប្រវែងពី ១ ទៅ ៦ ដ-ម ។ស្លឹកដុះចេញពីគល់ រឹងសាងវែង លាត និង ស្រួច ។



-ផ្កាវាពណ៌ឈាមជ្រូក មានប្រវែងពី ២ ទៅ ៣ ស-ម ។ មើមរាងពងក្រពើ មានបណ្តោយប្រវែង ២ ស-ម និងមានទទឹងប្រវែង ១ ស-ម មើមមានពណ៌ខ្មៅស្លេកផ្នែកខាងក្រៅ ពណ៌ប្រផេះ និង ស្លាតផ្នែកខាងក្នុងមានរស់ជាតិល្វីង និង ក្លិនក្រអូប ។

-គេសង្កេតឃើញ ស្មៅក្រវាញជ្រូកមានដុះពាសពេញក្នុងប្រទេសឥណ្ឌូចិន និង នៅមជ្ឈិមបូព៌ាប្រទេស ជាពិសេសនៅកន្លែងដីខ្សាច់ ។

២-សមាសភាពគីមី : -តាមការស្រាវជ្រាវបានអោយដឹងថាក្នុងមើមក្រវាញជ្រូកមាន :

-អាមីដុង ( Amidon ) ដែលមានបរិមាណច្រើន ( Grande quantité ) ស្ករ ( Sucre ) ។

-ជាតិរេស៊ីន ( Matière résineuse )

-ជាតិប្រេងហើរ ( Huile volatile ) ប្រហែលពី 0,3 - 4,80 % និងមានជាតិសកម្មមួយ(1 alcaloïde)

៣-ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាលជំងឺ :

ក្រវាញជ្រូកជាថ្នាំមួយដែលប្រើប្រាស់ក្នុងចំណោមប្រជាជន ។ ក្នុងន័យនេះ មើមត្រូវបានប្រជាជនទំពារនៅសំរាប់អោយបាយឆ្ងាញ់ និង អោយដើរខ្យល់ធូរ ដើម្បីបំបាត់ភាពទល់លាមក ។ មើមក្រវាញជ្រូកសំរាប់ប្រើព្យាបាល :

-រដូវមិនទៀង -ឈឺពោះពេលមានរដូវ - ចុកពោះ -រលាកស្បូន -ជំងឺស្ត្រីភេទពេលមុននិងក្រោយសំរាលកូន - ជំងឺក្រពះដែលបណ្តាលមកពីសរសៃប្រសាទតឹងច្រើន - ជំនួយរំលាយអាហារដែលហូបចុកមិនរលាយ -ក្អួតចង្អោរ - ជំងឺរាគមួល ។

កំរិតប្រើ : -ជាម្សៅ ថ្នាំគ្រាប់ ត្រាំស្រា ឬ ដាំទឹកផឹក មួយថ្ងៃពី ៦-១២ ក្រាម ។

~ ចប់ ~

# 34 - ដើមពោត

-ឈ្មោះជាកម្ពុជា : ដើមពោត

-ឈ្មោះជាបារាំង : Maïs, Blé de Turquie

-ឈ្មោះជាឡាតាំង : Zea mays Lin.

-FAMILLE : Poaceae



១.លក្ខណៈរុក្ខជាតិ និងភូមិសាស្ត្រដាំដុះ : -ដើមពោតគឺជាប្រភេទរុក្ខជាតិស៊ីផ្លែម៉្យាងដែលមានកំពស់ពី ១,៥-២ម. ឬអាចមានកំពស់លើសពីនេះទៅទៀត ។ ដើមវាដុះត្រង់ឡើងលើ មានថ្នាំងមាំ និង ក្រាស់ព្រមទាំងមានថ្នាំងច្រើន ។ សាច់ក្នុងពេញប៉ុន្តែមានលក្ខណៈស្ពាញ់ ហើយទន់ ។ ស្លឹកមានប្រវែងពី ៣០-៦០ ស.ម សភាពលាតមានច្រនួតស្លឹកកណ្ដាលធំច្បាស់ និងនៅផ្នែកខាងគល់ស្លឹក មានរោមមួយកញ្ចុំពទ្ធ័ជុំវិញគល់ស្លឹក ។ ផ្កាឈ្មោលជាកញ្ចុំ ដុះនៅខាងចុងដើម ។ ផ្កាញីជាកញ្ចុំធំ ដុះនៅចន្លោះដើម និង ស្លឹក ។ ផ្កានេះជួនកាលពណ៌លឿង ជួនពណ៌ក្រហម ស្វាយ ឬ សទៅតាមពូជរុក្ខជាតិ ។ ដើមពោតត្រូវបានដាំនៅក្នុងប្រទេសកម្ពុជា និង នៅក្នុងតំបន់ប្រទេសក្ដៅនៃពិភពលោក សំរាប់យកគ្រាប់ផ្លែធ្វើជាចំណីសត្វពាហនៈ ដូចជា គោ ក្របី សេះ ជាដើម ។

២.សមាសភាពគីមី : -នៅក្នុងគ្រាប់ពោតមាន :

-អាមីដុង ( Amidon )................... 58%

-ជាតិខ្លាញ់ (Matières grasses )....... 5%

-នៅក្នុងដើមពោតមាន :

-ជាតិស៊ីតូស្តេរ៉ូល (Citostérol )

-ជាតិស្ទីម៉ាស្តេរ៉ូល ( Stigmastérol )

-ជាតិប្រេង សាប៉ូនីន ( Saponine )

-ជាតិគ្លុយកូស៊ីតល្វីង ( Glucoside amère ) -វីតាមីនសេ ( Vitamine C ) វីតាមីនកា ( VitamineK ហើយនិងជាតិរជ្ជងពុកទៀត ។

- ក្នុងមួយក្រាម ( 1g )ពោតមាន :

-វីតាមីនកា ( Vitamine K )................... 1.600 U.I

-អ៊ីណូស៊ីតុល ................................ មានអត្រាច្រើនបង្គួរដែរ

- ក្នុង២០ក្រាមពោតហាលអោយស្ងួតមាន :

-កាល់ស្យូម ( Calcium ) ...................... 0,28 g

-ប៉ូតាស្យ៉ូម ( Potassium )..................... 0,532 g

៨.ទ្ធិពលថ្នាំ : -ពោតធ្វើអោយបរិមាណទឹកនោមកើនឡើងពី ៣-៥ ដង ។ ពោតជីកចូលទៅធ្វើអោយទឹកប្រម៉ាត់បញ្ចេញច្រើន ។ ទឹកប្រម៉ាត់នេះរាវហើយមានទម្ងន់ស្រាលជាងធម្មតា ។ ឯចំណុះប៊ីលីរុយប៊ីន ( Bilirubine ) ក្នុងឈាមក៏ថយចុះដែរ ។ រីឯចំណុះប្រូត្រុមប៊ីន ( Prothrombine ) ក្នុងឈាមក៏កើនឡើងជាហេតុធ្វើអោយឈាមឆាប់កក ។

www.budinst.gov.kh www.elibraryofcambodia.org

៣-ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល :-

-សក់ពោតត្រូវបានគេយកមកប្រើជាភេសជ្ជៈថ្នាំសំរាប់ធ្វើអោយនោមធូរ

-នៅប្រទេសវៀតណាម , ឫសពោតយកមកស្ងោរផឹក សំរាប់ព្យាបាលជំងឺប្រមេះទឹកបាយ ។

កំរិតប្រើ : -កំរិតមិនកំណត់ អាចផឹកបានគ្រប់ពេលវេលា ។ នៅប្រទេសកម្ពុជាយើង តាមការស្រាវជ្រាវរបស់លោកវេជ្ជបណ្ឌិត បានអោយដឹងថា គ្រាប់ពោត បុកអោយម៉ត់លាយជាមួយផ្លែត្រសក់ សំរាប់ព្យាបាលឈឺបំពង់ក ( Angine ) -រលាកប្រម៉ាត់ -រលាកថ្លើម -និង សភាពធ្វើអោយរាក់រអួលទឹកប្រម៉ាត់ គេអាចប្រើលាយជាមួយជីវជាតិ កា ( Vitamine K ) ដើម្បីឃាត់ឈាម ។ ប្រើជាថ្នាំ :

បញ្ហារលាមក -បញ្ហាទឹកនោម -ព្យាបាលជំងឺរបេះដូង -ចុករោយ ។

គេប្រើជាឈ្នានថ្នាំដាំទឹកផឹក ឬ ប្រើជាការាវ ពី ១០-២០ ក្រ ក្នុងមួយថ្ងៃ ពោតគេអាចផ្សំថ្នាំដូចខាងក្រោមនេះ :

-គេយកពោត ១០ ក្រ បុកអោយខ្ទេចហើយដាក់ក្នុងឆ្នាំងដែលមានទឹក ២០០ម.ល ដាំអោយពុះ ។ រួចទុកអោយត្រជាក់សំរាប់ហូប ។ ៣-៤ ម៉ោងផឹកមួយស្លាបព្រាបាយ ។ ធ្វើជាការាវដាក់នៅក្នុងដបមួយចំណុះ ២០ ក្រ : មួយថ្ងៃផឹកពី ២-៣ ដង មួយដងពី ៣០-៤០ ដំណក់មុនពេលបាយ ។

~ ចប់ ~

35 - វល្លិសាវម៉ាវព្រៃ

-ឈ្មោះជាកម្ពុជា : វល្លិសាវម៉ាវព្រៃ

-ឈ្មោះជាឡាតាំង : Passiflora foetida Lin.

_FAMILLE : Passifloraceae

១.លក្ខណៈរុក្ខជាតិ និងភូមិសាស្ត្រដាំដុះ : -សាវម៉ាវគឺជាវល្លិមួយមានដើមទន់ ហើយសំបូរណ៍ទៅដោយរោមទន់ៗច្រើន ។ ស្លឹកវាទន់ហើយដុះឆ្លាស់គ្នា ។ ស្លឹកនេះរាងដូចបេះដូងប្រវែងពី ៦ទៅ ១០ ស.ម និង មានទទឹងពី ៥ ទៅ ៨ ស.ម ។ ជុំវិញស្លឹកមានរោម ។ ទងស្លឹកមានប្រវែងពី ៧-៨ស.មហើយរួញដូច រ៉េស័រ ( Ressort ) ។ ផ្កាវាមាន ជ្រែទាប់តូចៗ មានពណ៌ស ឬ ស្វាយស្លេក ។ ផ្លែវារាងដូចស៊ុតប្រវែងពី ២-៣ស.ម ផ្លូវផ្កាចាប់មានឡើងពីខែ ៤ ដល់ខែ ៥ ។ឯផ្លូវផ្លែវិញគឺពីខែ ៥ ដល់ខែ ៧ ។ គេសង្កេតឃើញវល្លិសាវម៉ាវមានដុះគ្រប់ស្ថានភាពដី ក្នុងប្រទេសឥណ្ឌូចិន ។



២.សមាសភាពគីមី : -គ្មានឯកសារស្រាវជ្រាវអំពីវល្លិសាវម៉ាវនៅឡើយ ។ តាមលោក ( QUESLAND Agr. J ) ក្នុងឆ្នាំ ១៩៣០ បានបង្ហាញអោយដឹងថា ក្នុងផ្លែទុំមានជាតិ អាស៊ីត ស៊ីយ៉ានីទ្រិក ប៉ុន្តែក្មេងបេះហូបគ្មានពុលទេ ។

www.budinst.gov.kh www.elibraryofcambodia.org

៣-ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល :-នៅក្នុងមន្ទីរពេទ្យ និង រោងចក្រផលិតឱសថនៃប្រទេស វៀតណាម គេយកដើមសាវម៉ាវដំរីជាថ្នាំធ្វើអោយឯងុយដេក និង ញាក់បេះដូង ។ ប៉ុន្តែក្នុងការជំងឺគេជំនួសប្រើនមុខដូចជា :

-ដើមល្មូក -ស្លឹកមន ពេលខ្លះគេថែម ប្រូមួរ ( Bromure ) ទៀត ហេតុដូច្នេះហើយបានជាគេពិបាកស្គាល់ឥទ្ធិពលរបស់វាច្បាស់ ។ ប៉ុន្តែមានអ្នកខ្លះទៀត គេយកដើមសាវម៉ាវទ្រៃពពាំទឹកផឹកធ្វើអោយសំរានលក់ស្រួល ។ ដូច្នេះយើងទាំងអស់គ្នា គួរតែចំយកចិត្តទុកដាក់ស្រាវជ្រាវអំពីវល្លិសាវម៉ាវទ្រៃនេះ ។

-រូបមន្តធ្វើអោយងងុយដេក និង ព្យាបាលបេះដូងដើរញាប់ :

-សាវម៉ាវទ្រៃ .................................. ៥០ ក្រ
-ស្លឹកល្ហុងខ្ចង .................................. ៣០ ក្រ
-ស្លឹកម៉ន .................................. ១០ ក្រ
-ល្មូក .................................. ២,២ ក្រ
-ស្ករ .................................. ៩០ ក្រ
-ទឹក .................................. ១០០ ម.ល

-អាស៊ីតបង់ស្សូអ៊ិក ( Acide benzoïque ) ដើម្បីថែរក្សា ( Conservateur )
-អាល់កុលល្មម ដើម្បីអោយរលាយ អាស៊ីតបង់ស្សូអ៊ិក ( Acide benzoïque ) ។

កំរិតប្រើ : -មនុស្សចាស់ : ២-៤ ស្លាបព្រាបាយ ក្នុងមួយថ្ងៃ
-កូនក្មេង : ១-២ ស្លាបព្រាកាហ្វេក្នុងមួយថ្ងៃ

-ផឹកមុនពេលចូលដេក ធ្វើអោយងងុយដេក និង បេះដូងមិនសូវញាប់ ។ រុក្ខជាតិទាំងមូល គេអាចយកទៅព្យាបាល រមាស់បានដែរ ដោយសារមានជាតិ អាស៊ីតស៊ីយ៉ានីទ្រិក ( Acide cyanhydrique )។

## 36 - ដើមទៀបស្រុក

-ឈ្មោះជាកម្ពុជា : ដើមទៀបស្រុក
-ឈ្មោះជាបារាំង : Pomme cannelle
-ឈ្មោះជាឡាតាំង : Anona squamosa Lin.
_FAMILLE : Anónaceae



១-លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ :-ដើមទៀបគឺជាប្រភេទដើមរុក្ខជាតិស៊ីផ្លែ ដែលមានកំពស់ពី ២ ទៅ ៨ .ម ។ ស្លឹករាងទ្រវែងស្រួចចុង គ្មានរោម ទន់ប្រវែងបណ្ដោយប្រវែង ១០ ស.ម និង មានទទឹងប្រវែងប្រហែល ៤ ស.ម ។ ផ្កាវាតូចៗពណ៌បៃតងលាយ សផ្នែកខាងក្នុង ដើយដុះចេញមុខជាមួយស្លឹក ។ ផ្លែវារាងមូលសឹងតែទាំងអស់ មានអង្កត់ផ្ចិតពី ៧ ទៅ ១០ ស.ម ។ សំបកផ្លែមានរាងជាក្រឡាៗ ជួនកាលទ្រវែង ។ផ្លែនេះ មានសំបកពណ៌បៃតងចាស់បន្តិច ។

-គ្រាប់ផ្លែពណ៌ សប្រផេះនៅពេលខ្ចី ហើយក្លាយទៅជាពណ៌

ខ្មៅរលោងនៅពេលទុំ ឃ្លាចផ្លែទន់ សំបកវាទៅជាពណ៌ជាតិទឹកផ្ទុមនៅពេលទុំតាមសភាព ទំហំធំ ឬ តូច និង ចំនួន តិច ឬ ច្រើនរបស់គ្រាប់ ។ ផ្លែមានរសជាតិផ្អែម មានលក្ខណៈដូចក្លិន និង រសជាតិ កាណែល (Cannelle)ដែរ។

-គេសង្កេតឃើញដើមទៀប មានដាំនៅប្រទេសឥណ្ឌូចិន ក្នុងលក្ខណៈជាចំការ នៅតាមទឹកដីភូមិករ របស់ប្រជាជន ។

២- សមាសភាពគីមី : -នៅក្នុងផ្លែទុំមាន :

-គ្លុយកូស ( Glucose ) ៧២ % , សាកការូស ( Saccharose ) ១៤,៧២%,

-ជាតិរម្សៅ ១,៣០% , ជាតិសាច់ ( Protide ) ២,៣ %

-នៅក្នុងស្លឹក : -មានអាល់កាឡូអ៊ីតមួយ ដែលគ្មានគ្លុយកូស៊ីត ( Glucoside )

-នៅក្នុងគ្រាប់ផ្លែមាន : -ជាតិប្រេង ៣៩,៥-៤២ % ( Glycéride)ក្នុងនោះគឺ :

-អាស៊ីតមីរីស្ទិក ( Acide myristique )

-អាស៊ីត ប៉ាល់មីទិក ( Acide Palmitique )

-អាស៊ីត ស្តេអារិក( Acide Stéarique )

-អាស៊ីត អារ៉ាស៊ីឌិក ( Acide Arachidique )

-អាស៊ីត ហេចសាដេកាណូអ៊ិក ( Acide Hexadécanoïque )

-អាស៊ីត អូលេអ៊ិក ( Acide Oléïque )

-អាល់កាឡូអ៊ីតមួយ ( 1 alcaloïde)ដែលគេហៅថា អាណូណាអ៊ីន(Anonaïne ) ។ ឯកំរិតរលាយរបស់វាគឺ ១២២-១២៣ អង្សា។

-នៅក្នុងគ្រាប់ និង ឫស ទៀបមាន :

-ជាតិពុលម៉្យាងដែលគេសាកល្បងថា អាស៊ីត គ្លីសេរិក (Acide Glycérique) និង អាស៊ីតមាម៉ូលេគុលធំ( Acides à molécule élevée )។បណ្ដាអ្នកស្រាវជ្រាវថ្នាក់ធ្វើការស្រាវជ្រាវរកជាតិពុលរបស់ជាតិនេះដោយសារការពិសោធដ៏ទៅលើសត្វជំនិតដូច្នេះ ។

៣-ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល : -ក្រៅពីយកផ្លែទាប និង ចំណែកផ្សេងៗទៀតរបស់ដើមទៀប ត្រូវបានប្រជាជនប្រើយកទៅព្យាបាលរោគមួយចំនួន ។

ស្លឹក : -ព្យាបាលជំងឺគ្រុនចាញ់ ក្នុងន័យនេះគេជ្រើសរើសយកស្លឹកដែលស្អាតគ្មានដង្កូវស៊ី ច្របាច់យកទឹកស្រស់ ឬ ដាំទឹកផឹក ។

កំរិតប្រើ : -មនុស្សចាស់ ២០ សន្លឹក

-ក្មេង ១០ សន្លឹក

បុកអោយខ្ទេចលាយទឹកបន្តិច រួចច្របាច់ច្រោះយកទឹកផឹក ២ ម៉ោងមុនពេលគ្រុនក្តៅ ។ មួយថ្ងៃពីរដងក្នុងរយៈពេល ៣ ឬ ៤ ថ្ងៃ ។

នៅប្រទេសឥណ្ឌា ស្លឹកព្យាបាល "ឫស"

នៅ ចាវ៉ា ( JAVA ) ស្លឹកព្យាបាល "មោស់ស៊ើស្បែក" ។ ជាតិប្រេងរបស់គ្រាប់ផ្លែ ត្រូវបានគេប្រើនៅតំបន់ជាច្រើនសំរាប់បំផ្លាញពួកសត្វល្អិតប៉ារ៉ាស៊ីត ( Parasites)ចង្រៃមានពួកសង្កើច ចៃ ជាដើម ។ ការប្រើសំរាប់សំលាប់សត្វនេះ ទាមទារនូវការប្រុងប្រយត្ន័ជានិច្ច ពីព្រោះគ្រាប់ម្សៅនៃផ្លែនេះ បើសិនជាធ្លាក់ចូលក្នុងភ្នែក និង បណ្ដាលអោយឈឺចាប់ជាខ្លាំង និង បណ្ដាលអោយខ្វាក់ភ្នែកបាន ។

-ឫស ប្រើជាថ្នាំបញ្ចុះ ក្នុងសភាពទល់ខ្លាំង

-នៅហ្វីលីពីន គេប្រើទៀបខ្ចីក្នុងលក្ខណៈជាថ្នាំផឹក លាង (Lavement)សំរាប់ព្យាបាលរាគ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅប្រទេសកម្ពុជាយើងៈ សំបកដើមទៀប សំរាប់ព្យាបាល រាគ ដោយប្រើតែឯង ឬ លាយជាមួយថ្នាំង ទៀត ។ បើគេប្រើវាតែឯងគេយកសំបកទៀបមួយចំណិតតូចដែលមានបណ្ដោយប្រវែងពី ៦-៧ ស.ម និង ទទឹង ២ ស.ម ទៅកិននឹងត្បាល់ដោយលាយជាបណ្ដើរពុទ្ធអាល់ កុលពី ១០០-១៥០ស.ល ។ គេត្រាំវាក្នុងរយៈពេល ២ ឬ ៣ ម៉ោងរួចគេច្រោះទឹកត្រាំស្រានេះ និង ក្រណាត់ ហើយនៅទីបញ្ចប់គេពិសាទឹកច្រោះបាននេះ បន្តិចម្ដងៗរហូតមានឥទ្ធិពលបណ្ដាលអោយជាតែម្ដង ។

-គ្រាប់ទៀបគេបុកកំទេចយកទៅព្យាបាលសត្វចៃ ។ "គេយកគ្រាប់បុកកំទេចលាំទឹកកក់សក់ ឬ ច្បាក់ខោអាវ ។ គេត្រូវប្រុងប្រយត្ន័មិនអោយទឹកគ្រាប់ទៀបចូលភ្នែកទេ ពីព្រោះវាអាចបណ្ដាលអោយខ្វាក់ភ្នែកបាន "។ ឃ្លុយគ្រាប់មានជាតិពុលច្រើន គេគ្រាន់តែលិតបន្តិចក៏ឃើញពិបាកក្នុងខ្លួន ។ ប៉ុន្តែបើយើងហូបផ្លែហើយលេបចូលគ្រាប់មិនអាចមានហេតុផលអ្វីកើតឡើងទេ ពីព្រោះមកពីសំបកគ្រាប់វាក្រាស់ ។ គេអាចយកគ្រាប់ទៀបទៅត្រាំស្រាផឹក ។

## 37 - ដើមត្នោត

-ឈ្មោះជាកម្ពុជា : ដើមត្នោតឈ្មោល - ញី

-ឈ្មោះជាបារាំង : Palmier à sucre , Rondier

-ឈ្មោះជាឡាតាំង : (Borassus flabellifer mâle )
Borassus gomutus Lour femelle

_FAMILLE : Palmeae

១-លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : -ដើមត្នោតគឺជារុក្ខជាតិមួយ ដែលមានដើមរាងមូលវែងខ្ពស់រហូតដល់ ៣០ម ។ ស្លឹកវារាងដូចផ្លិតដែកពុះចុង ព្រមទាំងមានធាងវែងអមទៅដោយបន្លានៅសងខាង ។ ដើមត្នោតចែកចេញជាពីរប្រភេទគឺ :



-ប្រភេទឈ្មោល

-ប្រភេទញី

ស្លឹកត្នោតពួកប្រភេទឈ្មោលមានរាងធំ និង មានចំនួនច្រើនជាងប្រភេទញី ។ ចំណែកពួកប្រភេទឈ្មោលផ្ទុយទៅវិញគ្មានផ្លែទេ គឺមានតែផ្កា ។ផ្កាវាជាចង្កោមរាងមូលវែងប្រវែងប្រហែល ៤០-៥០ ស.ម និង មានវិជ្ជមាត្រប្រហែលពី ៣-៥ស-មដែលគេអាចគាបយកជាតិទឹកស្ករផ្អែម ទៅរំងាះធ្វើជាស្ករបាន ។

នៅប្រទេសកម្ពុជាយើង ដើមត្នោតគឺជាសម្បត្តិធម្មជាតិ និង ជាផ្នែកសេដ្ឋកិច្ចមួយដ៏សំខាន់ខាងផ្នែកផលិតស្ករត្នោត ។ សឹងនៅគ្រប់ទីកន្លែងទាំងអស់នៃប្រទេសយើងជាពិសេសគេសង្កេតឃើញមានដុះ និង ដាំនៅកៀនវាលនៅស្មាន នៅ តាមផ្លូវ ផ្លូវ និង នៅតាមដីស្រែ ។

www.budinst.gov.kh www.elibraryofcambodia.org

២-សមាសភាពគីមី : -នៅក្នុងទឹកផ្កា និង ទឹកផ្លែមានជាតិស្ករ ក្នុងអត្រាខ្ពស់បង្គួរ ជាពិសេស សាក់ការ៉ូស (Saccharose)......... ១០-១៥ %

៣-ការប្រើប្រាស់ និង កម្រិតដែលត្រូវប្រើក្នុងការព្យាបាល :

ទងផ្កា : -ព្យាបាលគ្រុនក្តៅ និង បញ្ចុះទឹកនោម គេយកទងផ្កាហាន់ជាចំណិតតូចៗចំនួន ១០០ ក្រ រួចថែមទឹក ៦០០ ក្រ ដាំអោយពុះក្នុង ១៥នាទី ផឹកជាច្រើនដងក្នុងមួយថ្ងៃ ។

-ទំលាក់ព្រូន គេយកទងផ្កាទៅដុតអោយក្តៅទន់ រួចពូតយកទឹកអោយបានចំនួន ១០០ ម.ល ផឹកជាបន្តបន្ទាប់ក្នុងពេលព្រឹក អាចទំលាក់ព្រូនបាន ។

-គេយកទឹកត្នោតផឹកដើម្បីសំរាប់បន្ទន់លាមក ។

ស្ករត្នោត : ក្រៅពីធ្វើអោយផ្អែម ប្រជាជនកម្ពុជាយើងបានប្រើស្ករត្នោត ដើម្បីបន្សាបជាតិពុលដោយសារគ្រាប់ស្លែង ។

ឫសត្នោត និង ដើមតូចៗ : -គេប្រើដាំទឹកផឹកដើម្បីបញ្ចុះទឹកនោម ក្នុងមួយថ្ងៃពី ៥០-៦០ ក្រ ។

ចំណែកផ្សេងៗទៀតរបស់ដើមត្នោត : -គេប្រើប្រាស់ក្នុងផ្នែកសំណង់តូចធំផ្សេងៗ ។

## 38 - ដើមទទឹម

-ឈ្មោះជាកម្ពុជា : ដើមទទឹម

-ឈ្មោះជាបារាំង : Grenadier

-ឈ្មោះជាឡាតាំង : Punica granatum

-FAMILLE : Punicaceae

១-លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : -ដើមទទឹមគឺជាប្រភេទរុក្ខជាតិម្យ៉ាងដែលបែកមែកច្រើន ហើយអាចក្លាយទៅជាបន្លា ។ ស្លឹកវាធម្មតាដូនកាលដុះឆ្លាស់គ្នា ឬ ដូនកាលសឹងតែទល់ទងទាំងអស់ ។ស្លឹកនេះមានរាងតូចវែង និង មានទងស្លឹកខ្លី ។ផ្កាពណ៌ក្រហមស្រស់ មានដុះតែមួយ ឬ បែកជាខ្នែង ដុះចេញពីចន្លោះស្លឹកទាំងសងខាង ។ ផ្លែមានសំបកក្រាស់ និង រឹង មាន៨ ក្លែប ចែកចេញជាពីរជាន់ ។ជាន់ខាងលើមាន ៥ ក្លែប និងជាន់ខាងក្រោមមាន ៣ ក្លែប ។



គ្រាប់ផ្លែមានជាច្រើន រាងមូលពងក្រពើ ឬ ដូនកាលមានជ្រុងជាច្រើនមិនសូវឃើញច្បាស់ ។ ដើមទទឹមជាដើមមួយ ដែលគេសង្កេតឃើញនៅពាសពេញក្នុងប្រទេសឥណ្ឌូចិន ក្នុងលក្ខណៈដាំជាចំការ ឬ លំអផ្ទះសំបែង ។

២-សមាសភាពគីមី : -

សំបកឫស ដើម មែក : -មានជាតិ :

www.budinst.gov.kh www.elibraryofcambodia.org

-តាណាំង ( Tannin) ............២៥% (acide galactannique ou digalique et acide punicotannique ) ។ ក្រៅពីនោះនៅមានជាតិអាល់កាឡូអ៊ីត alcaloïdes ៤ យ៉ាង :

-ប៉េលលេទីយេរីន ( Pelletiérine ) $C_8H_{15}ON$

-អ៊ីសូប៉េលលេទីយេរីន( Isopelletiérine ) $C_8H_{15}ON$

-មេទីលប៉េលលេទីយេរីន ( Méthylpelletiérine ) $C_8H_{14}(CH_3)ON$

-ប៉ស៊ួដូប៉េលលេទីយេរីន ( Pseudopelletiérine ) $C_9H_{15}ON$



Pelletiérine



Isopelletiérine



Pseudopelletiérine



Méthylpelletiérine

-អត្រាខាងលើនេះ មានច្រើន ឬ តិចទៅតាមមធ្យោបាយយកផល និង វិធីរក្សាគ្រប់គ្រង ។ នៅក្នុងអាល់កាឡូអ៊ីត (Alcaloïde) ខាងលើមានតែ (Pelletiérine) និង(Isopelletiérine) ទេ ដែលមានឥទ្ធិពលព្យាបាលព្រូន ។ តាមឯកសារថ្មីៗបញ្ជាក់ថា គេមិនទទួលស្គាល់ថាមាន (Pelletiérine ) ទេ ប៉ុន្តែមាន(Isopelletiérine-Pseudopelletiérine និង (Méthylisopelletiérine) ប៉ុណ្ណោះ ។

៣-ឥទ្ធិពលថ្នាំ :

ក -តាណាំង(Tannin) ជាជាតិមួយមានឥទ្ធិពលសម្លាប់មេរោគ ។

ខ -ប៉េលលេទីយេរីន (Pelletiérine) សំរាប់បំពុលព្រូន ។ ជាតិទី ២ នេះអាចធ្វើអោយស្លឹកព្រូន ។ ថា ធ្វើអោយស្លឹកប្រពន់ទៅលើប្រព័ន្ធសរសៃប្រសាទ មណ្ឌលអោយដកដង្ហើមមិនរួច ពេលគឺស្លាប់តែម្តង ។ ចំពោះមនុស្សវិញ ធ្វើអោយខ្ញើចសាច់ដុំក្នុងករណីគេប្រើ ០,៥០-០,៦០ ក្រ ប៉េលលេទីយេរីន (Pelletiérine ) ។

អត្រាអាល់កាឡូអ៊ីត (alcaloïde) មធ្យមគិតតាមសណ្ឋានស៊ុលហ្វាត(Sulfate ) ក្នុងមួយគីឡូក្រាម ( 1 Kg) ទីនសំបកគឺ :

-ប៉េលលេទីយេរីនស៊ុលហ្វាត(Pelletiérine sulfate)............. ០,៧-១ ក្រ

-អ៊ីសូប៉េលលេទីយេរីនស៊ុលហ្វាត(Isopelletiérine sulfate)......... ១,៣-១,៥ក្រ

-ប៉ស៊ួដូប៉េលលេទីយេរីនស៊ុលហ្វាត(Pseudopelletiérine sulfate)......១,៥-២ ក្រ

-មេទីលអ៊ីសូប៉េលលេទីយេរីនស៊ុលហ្វាត (Méthylisopelletiérine sulfate០,០៤ ក្រ

គេមិនអាចប្រើប៉េលលេទីយេរីន (Pelletiérine ) ទៅលើកូនក្មេង និង ស្ត្រីមានផ្ទៃពោះបានទេ ។

ការពិសោធន៍ទៅលើសត្វមានជីវិត : -បាន អោយឃើញថា ជាតិប៉េលលេទីយេរីន(Pelletiérine) មានឥទ្ធិពលសម្លាប់តេនីញ៉ា ( Ténia ) និង អង់គីឡូស្តូម ( Ankylostome ) ។

www.budinst.gov.kh www.elibraryofcambodia.org

គ-របៀបប្រើ និង កម្រិតដែលត្រូវប្រើក្នុងការព្យាបាល : សំបកឫសទទឹមសំរាប់ទំលាក់ព្រូន តេនីយ៉ា (Ténia) ដោយសារសារធាតុសកម្មឈ្មោះ ប៉ែលលេទៀរីន (Pelletiérine) និង អ៊ីសូប៉ែលលេទៀរីន (Isopelletiérine) តែគេហាមឃាត់មិនអោយប្រើចំពោះស្ត្រីមានផ្ទៃពោះ និង កូនក្មេង ពីព្រោះជាតិប៉ែល លេ ទៀរីនមានឥទ្ធិពលពុលខ្លាំង ។ គេច្រើនយកសំបកឫសស្រស់ដែលទើបតែគាស់ឡើងថ្មី មានប្រសិទ្ធភាពជាងដោយនៅមានជាតិអាល់កាឡូអ៊ីតច្រើន ។ ពេលប្រើសំបកស្ងួត ត្រូវយកទៅត្រាំទឹកមុននឹងយកទៅលាយផ្សំថ្នាំ វានៅតែមានឥទ្ធិពលបំបាត់ព្រូនដដែល ។ លោក Souberpan J.E de Vrij បានរក្សាសំបកទទឹមទុកបាន ១៣ ឆ្នាំក្នុងលក្ខណៈផ្សេងៗ ហើយមានប្រសិទ្ធភាពដូចសំបកស្រស់ដែរ ។ គេប្រើជាតិប៉ែលលេទៀរីនដែលចំរាញ់ចេញពីសំបកទទឹម ដោយប្រើកម្រិត ប៉ែលលេទៀរីនស៊ុលហ្វាតធម្មតា ០,៣០ក្រាលាយនិង ០,៤០ក្រ ជាតិតាណាំង ។ មានអ្នកនិពន្ធខ្លះយល់ថាឥទ្ធិពលរបស់ជាតិ ប៉ែលលេទៀរីនមិនហ៊ឹងពូកែដោយហេតុជាតិប៉ែលលេទៀរីនមានឥទ្ធិពលទៅតែដល់ ៥០-៦០% Pseudopelletiérine ដែលគ្មានឥទ្ធិពល ។ក្នុងករណីនេះ កម្រិតប្រើត្រូវកើនឡើងពី ០,៣០-០,៥០ក្រ ក្នុង ២៤ម៉ោ ។ ប៉ុន្តែត្រូវប្រុងប្រយ័ត្នក្នុងពេលប្រើប្រាស់ដូនកាលប្រើក្នុងកម្រិតធម្មតា នៅតែមានជាតិពុលបណ្តាលអោយស្លាប់បាន ។

<u>រូបមន្តព្យាបាលព្រូន :</u>

ក-តាមរបៀបបុរាណ គេយកសំបកស្ងួតកំទេចអោយល្អម ៦០ ក្រ រួចត្រាំក្នុងទឹកសុទ្ធ ៧៥០ក្រចំនួន ៦ ម៉ោង ក្រោយពីនេះគេចំរាញ់អោយនៅសល់ ៥០០ក្ររួចគេច្រោះ ។

របៀបប្រើ : -ព្រលឹមឡើងផឹកថ្នាំនេះ ហើយចែកចេញជា ២ ឬ ៣ ផងក្នុងកន្លះម៉ោងផឹកម្តង ។ ក្រោយពីបានផឹកលើកចុងក្រោយបង្អស់ បានរយៈពេល ២ ម៉ោង ផឹកថ្នាំបញ្ចុះបន្ថែមទៀត ។ ពេលផឹកថ្នាំនេះ ត្រូវដេកសំរាកបិទភ្នែក ដើម្បីកុំអោយហត់ពេក ។

ខ-ដោយរួមផ្សំ នឹងថ្នាំបញ្ចុះ :

- សំបកទទឹម ........................... ៤០ ក្រ
- Rheum officinale ............ ៤ ក្រ
- ផ្កាស្លា ........................... ៤ ក្រ
- ទឹក ...............................៧៥០ ក្រ

គេចំរាញ់អោយនៅសល់តែ ៣០០ ម.ល ។ មុននឹងប្រើថ្នាំនេះ គឺអត់អាហាររយៈពេលមួយយប់ ទើបព្រលឹមឡើងផឹកថ្នាំនេះ ហើយចែកចេញជា ២ ឬ ៣ ផង ។ ក្នុងពេលផឹកត្រូវដេកសំរាក ហើយពេលណារមួលពោះដើរទៅបត់ជើងធំរួចអង្គុយត្រាំនៅក្នុងទឹកក្តៅឧណ្ហៗ ដើម្បីអោយព្រូនវារចេញអស់ ។

- ផ្កា និង សំបកដើម "ស្ងោរផឹក" សំរាប់ព្យាបាល រាគ និង រាគ មួល ។
- សំបកផ្លែទទឹម "ស្ងោរផឹក" សំរាប់ព្យាបាល : ជំងឺ រាគ មួលរ៉ាំរ៉ៃ-ជំងឺធ្លាក់ស និង ជំងឺប្រុសផ្លូវបាត ។ប៉ុន្តែបើមានភាពក្រហល់ក្រហាយក្នុងក្រពះ សាលតូចចង់តែបត់ជើងធំនោះត្រូវបញ្ឈប់ការប្រើភ្លាម ។

<u>រូបមន្តព្យាបាល ជំងឺ រាគ មួលរ៉ាំរ៉ៃ ធ្លាក់ស និង ប្រុសផ្លូវបាត :</u>

- សំបកផ្លែកិនអោយម៉ត់ ..................... ៦០ ក្រ
- ទឹក ...............................៦០០ ក្រ

គេយកទៅស្ងោរអោយពុះចំនួន ១៥ នាទីនៅក្នុងឆ្នាំងមួយចំហរគ្របបន្ទាប់មកគេច្រោះ ហើយចាក់ទឹកថែមអោយគ្រប់ ១ លីត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

កំរិតប្រើ : -មួយថ្ងៃពី ៣០ -៦០ ក្រ ។ គេអាចប្រើជាលក្ខណៈ ទឹកខ្ពុរមាត់សម្លាប់មេរោគដែរ ។

-ស្លឹក "ស្ងោរផឹក" សំរាប់ជាទឹកខ្ពុរមាត់ និង លាងដំបៅមាត់ ។ នៅប្រទេសកម្ពុជាយើងគេប្រើ ឫស សំបក និង ផ្លែ :

-សំបកវាចាស់គេប្រើត្រាំស្រា ឬ ឆុងទឹកក្ដៅដូចតែ

-ឫសមួយកាប់ជាដុំកំទេចល្មមតូច ដាំឆុងក្នុងទឹកក្ដៅដូចតែ សំរាប់ព្យាបាល ចុក រោគ

-ផ្លែ សំរាប់ព្យាបាល រោគ ។ ឯរបៀបធ្វើថ្នាំ រោគ ជំពូកដោយផ្លែ មានដូចតទៅ : គេយកផ្លែទុំមួយ ញាត់អាភៀន មួយដុំតូចក្នុងនោះ ។ គេដុតនៅលើភ្លើងកុំអោយក្ដៅពេក ។ កាលណាផ្លែនេះឆេះ គេកាត់វារួចដាក់ដាំអោយពុះក្នុងទឹកមួយចានគោម "ទឹក ៣យកទឹក១" នៅទីបញ្ចប់គេផឹកតែម្ដង ដើម្បីព្យាបាល រោគ ។

## 39 - ដើមប្រជលង់

-ឈ្មោះជាកម្ពុជា : ដើមប្រជលង់

-ឈ្មោះជាបារាំង : Baselle, Epinard de Chine, Epinard de Malabar.

-ឈ្មោះជាវិទ្យាសាស្ត្រ : Basella rubra Lin.

-FAMILLE : Basellaceae

១ -លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : -គឺជារុក្ខជាតិវារដែលមានដើម វារពត់ពេនដូចកន្ទ្រាំងវិញដើម រុក្ខជាតិផ្សេងទៀត បណ្ដើតទៅជាប្រមទើយមានប្រវែងពី ១,៥០មទៅ ២ម. ។ ស្លឹកប្រកបទៅដោយទងវែងៗ ។ ស្លឹកនេះក្រាស់ទទេស្អាត ពណ៌ក្រហមស្លេកទើយលាត ។ ផ្កាប្រជលង់តូចពុំពណ៌ ស ឬជួនកាលពណ៌ស្វាយលាយក្រហមស្លេក ដុះជាកញ្ចុំៗនៅចន្លោះដើម និង ស្លឹក ប៉ុន្តែផ្នែកខាងលើតូចហើយវែងជាងគេ ។ ផ្លែវាទទេ រាងតូចពណ៌ខ្មៅ ឬ ជួនកាលពណ៌ចាំងស្លេកៗ នឹងពន្លឺថ្ងៃ មានក្លែប ៤ នៅខាងចុង ប៉ុន្តែមាន ២ក្លែប នៅសងខាងហើយតូចជាងគេ ។ គ្រាប់ផ្លែពណ៌ស្លេកៗ ។



ដើមប្រជលង់មានប្រភពចេញពីទ្វីប អាស៊ី និង ទ្វីបអាហ្វ្រិកតំបន់ក្ដៅ ។ នៅតំបន់ឥណ្ឌូចិន គេសង្កេតឃើញដើមប្រជលង់មានដុះឯងៗតែម្ដង និង គេដាំក្នុងសួនហើយគេអាចការពារនិង បំរួលការលូតលាស់របស់វា ។

២ -សមាសភាពគីមី : -តាមការស្រាវជ្រាវរបស់លោក (READ) ក្នុងឆ្នាំ ១៩៣៦បានអោយដឹងថាក្នុងស្លឹកប្រជលង់មាន :

-វីតាមីន $A_3$ -វីតាមីន $B_3$ - ជាតិ សាប៉ូនីន ( Saponine ) -ជាតិរអិល និង ជាតិដែក ។

៣ -ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាលជំងឺ : -ក្នុងចំណោមប្រជាជន គេច្រើនយកស្លឹកប្រជលង់ទៅស្លហូប គេមិនសូវយកធ្វើជាថ្នាំទេ ។ ប៉ុន្តែនៅក្នុងឯកសារ បូរាណ គេឃើញថា ដើមប្រជលង់មានជាតិជូរ ប៉ុន្តែគ្មានជាតិពុល ហើយអាចមានឥទ្ធិពល សំរាប់បញ្ចុះកំដៅ និង បន្ទន់លាមក ។

www.budinst.gov.kh www.elibraryofcambodia.org

-នៅប្រទេសឥណ្ឌូណេស៊ី គេយករុក្ខជាតិទាំងមូល ឬ ស្លឹកសំរាប់ព្យាបាល :
-ទល់លាមកកូនក្មេង -និង នារីកើតកូនពិបាក

-នៅ "ឡាវ" ទឹកផ្លែរបស់ប្រភេទប្រជលង់ក្រហម ធ្វើជាថ្នាំសំរាប់ព្យាបាលឈឺភ្នែកក្រហមដែលបណ្តាលមកពីរលាកភ្នែក ។

-នៅប្រទេសចិន គេយកស្លឹកប្រជលង់ដើមីឡបំពោកលើដោះហើម ។ គេអាចប្រើទឹកផ្លែប្រជលង់ ដើម្បីអោយឡើងពណ៌ក្រហមនៅលើដំណាប់ផ្លែឈើ ។ បើគេបន្ថែមទឹកក្រូចឆ្មារទៀត ពណ៌នេះកាន់តែឡើងក្រហមខ្លាំងថែមទៀត ប៉ុន្តែគេហាមឃាត់មិនអោយប្រើច្រើនទេ ។

40 - ដើមប្រចត់ស៊ី

-ឈ្មោះជាកម្ពុជា : ដើមប្រចត់ស៊ី ឬ កំប៉ុញ

-ឈ្មោះជាឡាតាំង: *Aglaonema siamense* Engl.

_FAMILLE : Araceae

១-លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : -គឺជាដើមរុក្ខជាតិម៉្យាងដែលគេចាត់ចូលទៅក្នុងពពួកប្រភេទស្មៅ ។ ស្មៅនេះមានកំពស់ពី ៣៥-៤០ ស.ម ហើយមានកំរាស់ពី ១-១,៥ ស.ម ។ ស្លឹករាងមូលទ្រវែងស្រួចចុង និងរីកមូលនៅខាងគល់ស្លឹក ។ ស្លឹកនេះមានបណ្តោយប្រវែងពី ១៥-២០ ស.ម និង មានទទឹងប្រវែងពី ៥-៧ ស.ម ។ ទ្រនុងស្លឹកទាំងសងខាងមានលក្ខណៈជិតច្បាស់ ។ ទងស្លឹកមានប្រវែងពី ៦-១០ ស.ម ។ ផ្កាជាកញ្ចុំពុដុះនៅខាងចុងដើម ឬ សងខាងដើម ។ ផ្កាឈ្មោលខាន់ចេញកណ្តាតឆ្ងាយពីផ្កាញី ដោយសារស្តាមីណូត ( les Staminodes ) ។ ផ្លែរាងមូលទ្រវែងពណ៌សអុចៗ មានបណ្តោយប្រវែងពី ១២-១៨ ស.ម និង មានទទឹងប្រវែងពី ៧-១០ ម.ម ។ គេសង្កេតឃើញដើមប្រចត់ស៊ី មាននៅក្នុងប្រទេសឥណ្ឌូចិន និង នៅក្នុងប្រទេសថៃ ។ ជួនកាលគេដាំដើមនេះសំរាប់លំអ ។



២-សមាសភាពគីមី : -មិនទាន់មានឯកសារស្រាវជ្រាវនៅឡើយ អំពីរុក្ខជាតិនេះ ។

៣-ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល : -គេយករុក្ខជាតិទាំងមូលមកស្ងោរផឹកសំរាប់ព្យាបាល : បញ្ចុះលាមក -ព្យាបាលពស់ចឹក -ហើមឈឺបំពង់ក ។

កំរិតប្រើ : គេយករុក្ខជាតិទាំងមូលពី ២០-៤០ ក្រាម ក្នុងមួយថ្ងៃ ។ គេអាចយកដើមស្រស់ប្រចាំជាមួយទឹក ៣០០ ម.ល ផឹកក្នុងមួយថ្ងៃ ។ គេយករុក្ខជាតិទាំងមូលមកបុកកិច ហើយបំពោក សំរាប់ព្យាបាល "បូស" ដែរដោយឥតគិតកំរិត ។

www.budinst.gov.kh www.elibraryofcambodia.org

# ដើមជន្លាត់ទឹង

-ឈ្មោះជាកម្ពុជា : ដើមជន្លាត់ទឹង

-ឈ្មោះជាឡាតាំង : Euphorbia antiquorum Lin.

- FAMILLE : Euphorbiaceae

១.លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ :-ដើមជន្លាត់ទឹងគឺជារុក្ខជាតិមួយមានរាង ៣ ជ្រុងប្រកបទៅបន្លាស្អកស្ទុះ និង មានបែកមែកច្រើន ។ ដើមនេះមានកំពស់ប្រហែល ៨ ម ។ស្លឹករាងមូលទ្រវែង ដូនកាលមូល ។ ស្លឹកនេះគ្មានទងទេ ហើយមានសភាពទន់ទោធ្លាក់មកដី ។ ផ្កាមានឈ្មោះជាកញ្ចុំនៅលើស្លឹក ហើយស្ថិតនៅក្នុងចន្លោះផ្នែកខាងជ្រុងនៃដើម ។ គេសង្កេតឃើញដើមជន្លាត់ទឹង មានដុះ និង ដាំនៅក្នុងប្រទេសឥណ្ឌូចិន ប្រទេសអេហ្ស៊ីប ប្រទេសឥណ្ឌា និង ប្រទេសឥណ្ឌូនេស៊ី ។



២. សមាសភាពគីមី :-មិនទាន់មានឯកសារស្រាវជ្រាវស្តីអំពីសមាសភាពគីមីនៅក្នុងដើមជន្លាត់ទឹងនៅឡើយ ។

៣. ការប្រើប្រាស់ និង កិរិតដែលត្រូវប្រើក្នុងការព្យាបាល: ជ័ររបស់ដើមជន្លាត់ទឹងមានជាតិពុល ។ ដូច្នេះពេលប្រើគេត្រូវប្រយ័ត្នកុំអោយចូលភ្នែក ។ ប្រជាជនច្រើនប្រើដើមជន្លាត់ទឹងសំរាប់ព្យាបាលឈឺពោះប៉ុន្តែត្រូវតែលាយផ្សំជាមួយថ្នាំផ្សេងៗទៀត ដើម្បីកុំអោយមានឥទ្ធិពលខ្លាំងពេក ។ ប្រើខាងក្រៅសំរាប់ព្យាបាល :

ឈឺធ្មេញ និង សម្លាប់សត្វល្អិត ។ សូមបញ្ជាក់ថាដើមនេះមានជាតិពុលច្រើន ពេលប្រើត្រូវមានការពិសោធន៍អោយបានម៉ត់ចត់ ។

រូបមន្តព្យាបាលឈឺធ្មេញ :- គេកាត់យកដើមជន្លាត់ទឹង ១ ចំណិតសកយកបន្លាចេញ ។ គេយកទៅដុតអោយទន់ បុកអោយម៉ត់ ពូតយកកាកចេញ ហើយថែមអំបិលបន្តិចយកទៅបៀមពេលដែលឈឺធ្មេញ "ប៉ុន្តែហាមមិនអោយលេបចូល" ។

កិរិតប្រើ :-របៀបប្រើគឺបៀមពី ៣ ទៅ ៤ ដងក្នុងមួយថ្ងៃបន្ទាប់ពីបៀមត្រូវខ្ពុរមាត់អោយស្អាត។

ជ័ររបស់ដើមប្រើសំរាប់ : ធ្វើអោយក្អួត-បញ្ចុះលាមក ។ តាមការស្រាវជ្រាវរបស់លោកវេជ្ជបណ្ឌិត ម៉ឺណូ (Dr. MENAUT ) គាត់ប្រើជ័រដើមជន្លាត់ទឹងលាយជាមួយពងទា រួចចៀនជាមួយខ្លាញ់ ដើម្បីព្យាបាលធ្វើក្អួត ។ នៅប្រទេសកម្ពុជាយើង តាមការស្រាវជ្រាវរបស់លោកវេជ្ជបណ្ឌិត ម៉ឺណូ គេប្រើសំរាប់ព្យាបាល :

-គ្រុនពាក់ -និង រាគ មួល

• -បើគេព្យាបាលគ្រុនពាក់ គេយកដើមជន្លាត់ទឹងលាយជាមួយថ្នាំផ្សេងៗទៀត ។

• -បើព្យាបាល រាគ មួល គេដុសវាជាមួយអំបែងត្រាតពុំ ធ្វើជាថ្នាំផឹក ។

www.budinst.gov.kh www.elibraryofcambodia.org

# វល្លិបណ្ដូលពេជ្រ

- ឈ្មោះជាកម្ពុជា : វល្លិបណ្ដូលពេជ្រ
- ឈ្មោះជាបារាំង : LIANE QUININE
- ឈ្មោះជាឡាតាំង : Tinospora crispa Miers
- FAMILLE : Menispermaceae

១. លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ : វល្លិបណ្ដូលពេជ្រគឺជាប្រភេទវល្លិ ដែលមានដើមកពីកកំពកធ្វើអោយមានសភាពគ្រោតគ្រាតដូចដើមដំឡូងឈើ ។ រសជាតិដើមល្វីងខ្លាំងប្រហាក់ប្រហែលនឹងរសជាតិល្វីងរបស់ "គីនីន" ។ ស៊ុំកប្រកបទៅដោយទងវែង ស្លឹកនេះរាងមូលពងក្រពើ ស្រួចចុងបន្តិច មានបណ្ដោយប្រវែង ៨ស.ម ។ ទងស្លឹករាងតូចឆ្មារ ប៉ុន្តែមានប្រវែងខ្លីជាងស្លឹក ។ ផ្កាជាកញ្ចុំពុ ចែកជា ៣ ទៅ ៤កញ្ចុំតូចក្នុងនេះ ១ ឬ ២ កញ្ចុំតូចពុំ ដុះចេញពីចន្លោះដើម និង ស្លឹកៗ ផ្លែពណ៌ក្រហមរាងមូលដូចស៊ុត មានប្រវែង ១២ម.ម ។ ផ្លែនេះមានគ្រាប់តែមួយគត់ ។ គេសង្កេតឃើញវល្លិបណ្ដូលពេជ្រមានដុះ និង ដាំនៅក្នុងប្រទេសឥណ្ឌូចិន និងនៅក្នុងទ្វីបអាស៊ីតំបន់ក្ដៅ ។



២. សមាសភាពគីមី : ក្នុងដើមលោក អិល បូកែសនី (L.BEAUQUESNE ) បានរកឃើញ អាល់កាឡូអ៊ីតមួយដែលអ្នកស្រាវជ្រាវដទៃទៀត អោយឈ្មោះថា ប៊ែរ ប៊េរីន ។ ប៉ុន្តែតាមលោក អិលបូកែសនីគាត់អោយឈ្មោះជាតិនេះថា ប៉ង់ម៉ាទីន ( Panmatine ) ។ ក្រៅអំពីអាល់កាឡូអ៊ីត លោក អិល បូកែសនី បានចំរាញ់នូវជាតិ ល្វីងមួយក្នុងអត្រាពី ០,៦០-០,៨០ ភាគរយ ដោយគិតលើវល្លិបណ្ដូលពេជ្រស្ងួត ។ ជាតិល្វីងនេះបានកំណត់ថាជាជាតិ ( Glucoside ) មួយមានជាតិស្ករហៅថា មេ ទីលប៉ង់តូស Méthylpentose) ។ ក្នុងឫស : អាល់កាឡូអ៊ីតមួយឈ្មោះ ប៊ែរ ប៊េរីន ( Berbérine )

- ជាតិល្វីងឈ្មោះ កូ លុមប៊ីន ( Columbine ) ប្រហែល.......,..២,២%
- និង ជាតិ អេតេរ៉ូស៊ីត (hétéroside) មួយឈ្មោះ ពីក្រូរេទីន ឬ ពីក្រូរេទីណូស៊ីត ( picrorétinoside )។

៣. ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល : ពិតមែនតែគេហៅថាវល្លិ គីនីន តែវល្លិនេះគ្មានជាតិគីនីន ( Quinine ) ទេ។ក្នុងចំណោមប្រជាជនគេយកវល្លិបណ្ដូលពេជ្រធ្វើជាថ្នាំ :

- ព្យាបាលគ្រុនក្ដៅ - ថ្នាំកម្លាំង - ជំនួយការរំលាយអាហារ - និង ធ្វើអោយពិសារបាយឆ្ងាញ់ក្នុងលក្ខណជាការ ឬ ជាម្សៅសំរាប់វាយជាគ្រាប់បាន ។

កំរិតប្រើ:
- ជាគ្រាប់ ពី ០,៥០-១,៥០ ក្រ ក្នុងមួយថ្ងៃ
- ជាស្រាថ្នាំ ពី ៤ -៨ ក្រ ក្នុងមួយថ្ងៃ
- ម្សៅថ្នាំ ដឹកពី ២-៣ ក្រ ក្នុងមួយថ្ងៃ

www.budinst.gov.kh www.elibraryofcambodia.org

ប្រជាជនវៀតណាម ប្រើវល្លិបណ្ដូលពេជ្រ សំរាប់ព្យាបាលគ្រុនក្ដៅ ដោយជំរុះដូចតទៅ ៖

-គេយកវល្លិបណ្ដូលពេជ្រកាត់ជាកំណាត់តូចៗរួចកិនអោយទៅជាម្សៅ ឆុងក្នុងទឹកក្ដៅ ទុកអោយត្រជាក់ និង នៅទីបញ្ចប់ផឹកព្យាបាលតែម្ដង ។ ស្លឹកសំរាប់ព្យាបាលគ្រុនក្ដៅ ដោយបុកអោយម៉ត់ រួចបំពោកនៅលើស្បែក ធ្វើដូចនេះច្រើនដងទើបបាត់គ្រុន ។ នៅក្នុងប្រទេសកម្ពុជាយើង តាមការស្រាវជ្រាវរបស់លោកវេជ្ជបណ្ឌិត ម៉ឺណូ (Dr. MENAUT) វល្លិបណ្ដូលពេជ្រត្រូវបានប្រជាជនយើងយកមកសំរាប់ព្យាបាល ៖

-គ្រុនក្ដៅ -ជំនួយកម្លាំង -ជំនួយការរំលាយអាហារ -និង ធ្វើអោយពិសារបាយឆ្ងាញ់

គេប្រើឆុងទឹកក្ដៅដូចតែ ។ បើពិសារមុនពេលបាយគឺសំរាប់ធ្វើអោយបាយឆ្ងាញ់ ។ បើពិសារក្រោយពេលបាយគឺសំរាប់ជំនួយរំលាយអាហារ ។

-គេអាចជំនួសវល្លិបណ្ដូលពេជ្រជាមួយថ្នាំផ្សេងទៀត សំរាប់ព្យាបាលជំងឺឈឺសន្លាក់ដៃ សន្លាក់ជើង និង គ្រុនក្ដៅ ។ ចំណែកឫសនៃវល្លិបណ្ដូលពេជ្រសំរាប់ព្យាបាលគ្រុនក្ដៅបានដែរ ។

-នៅប្រទេសវៀតណាម ភាគខាងត្បូង គេយករុក្ខជាតិទាំងមូលប្រើសំរាប់ព្យាបាលជំងឺតេតាណូស (Tétanos)(Liste des plantes médicinales existant au Cap.St Jacques,envoyée à l'Institut par le Résident - maire )

-នៅប្រទេសឥណ្ឌា និង នៅម៉ាឡេស៊ី គេយកវល្លិបណ្ដូលពេជ្រទៅដាំទឹកសំរាប់លាងដំបៅស្វាយប្រមេះ និង ស្លឹកកិនអោយម៉ត់បំពោកទៅលើរបួស និង កមរមាស់ ។

## ជីវ៉ាន់ស៊ុយ

-ឈ្មោះជាកម្ពុជា : ជីវ៉ាន់ស៊ុយ

-ឈ្មោះជាបារាំង : CORIANDRE

-ឈ្មោះជាឡាតាំង : Coriandrum sativum

-FAMILLE : Apiaceae

១. លក្ខណៈរុក្ខជាតិ និង ភូមិសាស្ត្រដាំដុះ -ជីវ៉ាន់ស៊ុយគឺជាប្រភេទជីម្យ៉ាងដែលមានដើមដុះត្រង់ឡើងលើ រាងមូលទលោងមានកំពស់ពី ៣៥-៥០ស.ម ហើយបែកមែកនៅផ្នែកខាងលើ ។ ស្លឹកដុះចេញពីគែរឫស ហើយមានទងវែង ស្លឹកនេះ មានទំហំធំបង្គួរ ហើយបែកពុះនៅជុំវិញស្លឹក ។ផ្កាពណ៌ស ឬ ផ្កាកាលពណ៌ស្វាយខ្ចីរាបបន្តិច មានសភាពជាកញ្ចុំពុំដែលមានពី ៣ ទៅ ៥ផ្កាតូចៗ ។ ផ្លែរាងមូលទ្រវែងមានបណ្ដោយប្រវែងពី ២,៥-៤ ម.ម ហើយរលោង ។ គេសង្កេតឃើញជីប្រភេទនេះមានដាំជាលក្ខណៈបន្លែនៅក្នុងប្រទេសឥណ្ឌូចិន តំបន់ មេឌីទែរ៉ាណេ ( méditerranéenne) តំបន់អាស៊ីប៉ែកខាងកើត នៅប្រទេសឥណ្ឌា នៅប្រទេសចិន និង នៅប្រទេសជប៉ុន ។



២. សមាសភាពគីមី : -នៅក្នុងផ្លែមាន :

-ជាតិប្រេងហោងសខាន់ ម្យ៉ាងមានក្លិនក្រអូប........,...០,៨០-៩

-ជាតិខ្លាញ់...................... ........ ១៣-២០ ៩

-ជាតិប្រូតេអ៊ីន.............................. ១៦-១៨ %

-ជាតិសែលុយឡូស ................... ៣ ,៨ %

-ជាតិដែលគ្មានអាស៊ូត.............................. ១៣%

នៅក្នុងជាតិប្រេងមានជាតិដែលសំខាន់ជាងគេគឺពី ៧០-៩០ % linalol លីណាឡុល ឬ គេអាចហៅម៉្យាងទៀតថា កូរីយ៉ង់ដ្រូល (Coriandrol) ។ នៅក្នុងស្លឹក និង ដើមមានជាតិប្រេងប្រហែល ១ ភាគរយ ។

៣. ការប្រើប្រាស់ និង កំរិតដែលត្រូវប្រើក្នុងការព្យាបាល : -នៅក្នុងប្រទេសឥណ្ឌូចិន :

-ស្លឹកជីវ៉ាន់ស៊ុយត្រូវបានប្រើលាយជាមួយម្ហូបអាហារដើម្បីយកក្លិន និង បំបាត់ក្លិនឆ្អាប ។

-ផ្លែគេប្រើក្នុងលក្ខណៈជាថ្នាំបុរាណ និង សម័យថ្មីផងដែរ សំរាប់ :

-បញ្ឈប់ការនោម -ជំនួយរំលាយអាហារ -យកក្លិនក្នុងអាហារ -ព្យាបាលក្អក -បន្ថយទឹកដោះ

កំរិតប្រើ : -ពី ៥ ទៅ ១០ ក្រ ក្នុងមួយថ្ងៃ ឬ ១០ ទៅ ២០ ក្រ ក្នុងមួយថ្ងៃដាំទឹកផឹក ឬ ត្រាំស្រា

រូបមន្តសំរាប់ព្យាបាលដើម្បីអោយកញ្ច្រិលកូនក្មេងចេញអស់ :

-ផ្លែកិនអោយម៉ត់.............................. ៨០ ក្រាម

-ស្រា.....................................១០០ ម.ល

-ទឹក......................................១០០ ម.ល

ដាំអោយពុះបិទអោយជិតដើម្បីកុំអោយហើរចំហាយ ហើយត្រងទាំងយកកាកចោល ។ បន្ទាប់មកដាក់អ្នកជំងឺអោយត្រូវចំហាយ តែកុំអោយត្រូវភ្នែក ។ ធ្វើដូចនេះកញ្ច្រិលនឹងហើរចេញអស់ ។

រូបមន្តកុំអោយកញ្ច្រិលចេញច្រើន :

-ផ្លែកិនអោយម៉ត់.............................. ៦ ក្រាម

-ទឹក...................................... ១០០ ម.ល

ដាំអោយពុះចំនួន ១៥ នាទីហើយចែកចេញជាពីរចំណែក មួយថ្ងៃផឹក ២ ដង ។

រូបមន្តសំរាប់ព្យាបាលមុខអាចម៍រុយ :

-ផ្លែច្របាច់យកទឹក លុបមុខ.......(បំបាត់ម្តងបន្តិចៗ) ។

-ស្លឹក និង ឫស បុកអោយម៉ត់ទៅជាម្សៅ រួចត្រាំស្រាសំរាប់លាបលើកន្លែង កន្ទួលនៃកញ្ច្រិលរបស់កូនក្មេង ។

-ផ្លែខាងលោកខាងលិចគេប្រើសំរាប់ :

-ធ្វើអោយដើរខ្យល់ស្រួលក្នុងបំពង់រំលាយអាហារ

-ធ្វើអោយសំរាន្តលក់

-ធ្វើអោយមានរសជាតិទៀងទាត់

-សំរាប់បំបាត់ក្លិនឆ្អាបក្នុងអាហារ ។

នៅប្រទេសអឺរ៉ុប គេប្រើផ្លែជីវ៉ាន់ស៊ុយក្នុងលក្ខណៈជាភេសជ្ជៈព្យាបាលរោគដោយផ្សេងៗ :

-១០ ក្រាមនៃជីវ៉ាន់ស៊ុយលាយជាមួយទឹកក្តៅដាំពុះ ១០០០ ក្រាម

-ជាថ្នាំត្រាំស្រា 1/5

-ជាថ្នាំត្រាំស្រាពិត (alcoolat) ក្នុងសមាសភាព :

.................., -ជីវ៉ាន់ស៊ុយ ១ ក្រាម + លាយជាមួយស្រា ៨០អង្សា ៨ក្រាម ។ រៀបចុងក្រោយនេះគេត្រាំស្រាទុកក្នុងរយៈពេល ២-ថ្ងៃ ។ បន្ទាប់មកគេចំហុយទូតទៅឈើ ៧ ក្រាម ។ ឯកំរិតប្រើវិញ គឺ ១ ថ្ងៃពី ៥ ទៅ ២០ ក្រាមនៃទឹកស្រាដែលបានមក ។ ។ ។

www.budinst.gov.kh www.elibraryofcambodia.org

## មាតិការឿង


| ល-រ | ឈ្មោះរុក្ខជាតិឱសថ | ទំព័រ | ល-រ | ឈ្មោះរុក្ខជាតិឱសថ | ទំព័រ |
|---|---|---|---|---|---|
| 1 | ដើមរង្គៀត | ១ | 22 | ដើម ល្ហុង | ២៩ |
| 2 | ផ្កាកំពីងពួយគោក | ៣ | 23 | ដើមក្បាលទុយ | ៣១ |
| 3 | ផ្កាទំយោល | ៤ | 24 | ដើមកន្ទ្រំឯបាយស | ៣២ |
| 4 | ដើមស្លា | ៥ | 25 | ដើមងប់ | ៣៣ |
| 5 | វល្លិកន្ទ្រំធាទី | ៧ | 26 | ដើមខ្ទាញ់ | ៣៤ |
| 6 | ដើមស្លែង | ៨ | 27 | ដើមកាឆាយ | ៣៦ |
| 7 | ដើមត្របែក | ១០ | 28 | ដើមឆ្អឹងមាន់ខ្មៅ | ៣៨ |
| 8 | ដើមស្រម៉ | ១១ | 29 | ដើមមក្លឿ | ៣៩ |
| 9 | ដើមញញូធំ | ១៣ | 30 | ផ្កាម្លិះ | ៤០ |
| 10 | ដើមកន្ទំថេត | ១៤ | 31 | ដើមស្វាយ | ៤១ |
| 11 | ដើមត្រចៀកក្រាញ់ព្រៃ | ១៥ | 32 | ស្មៅទឹកដោះខ្លា | ៤២ |
| 12 | វល្លិក្មារន្ធពប្រជុំកន្ទ្រំធាទី | ១៦ | 33 | ស្មៅក្រវាញជ្រូក | ៤៤ |
| 13 | ក្តាតទោរា | ១៧ | 34 | ដើមពោធ | ៤៥ |
| 14 | ដើមត្បាល់កិន | ១៨ | 35 | វល្លិសាវម៉ាវព្រៃ | ៤៦ |
| 15 | ដើមស្លាក់ | ១៩ | 36 | ដើមទៀបស្រុក | ៤៧ |
| 16 | វល្លិប្រមះ | ២០ | 37 | ដើមត្នោត | ៤៩ |
| 17 | ដើមក្រទៅ | ២២ | 38 | ដើមទទឹម | ៥០ |
| 18 | ដើមទាក់ស-ទាក់ក្រហម | ២៣ | 39 | ដើមជ្រលង់ | ៥៣ |
| 19 | ក្រូចថ្លុង | ២៤ | 40 | ដើមប្រទាល់ឥសី ឬ កំប៉ុញ | ៥៤ |
| 20 | ក្រូចឆ្មារ | ២៥ | 41 | ដើមជន្លាត់ទឹក | ៥៥ |
| 21 | ដើមឈូក | ២៧ | 42 | វល្លិបណ្ដូលពេជ្រ | ៥៦ |
| | | | 43 | ជីរវ៉ាន់ស៊ុយ | ៥៧ |


§§§§§§§ F I N §§§§§§

www.budinst.gov.kh www.elibraryofcambodia.org